ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- តើគួរអនុញ្ញាតឱ្យចុងចោទនៅក្រៅឃុំ?
- ទឹកដីនៃការផ្សះផ្សា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៣៥ ខែមីនា ឆ្នាំ២០១១

# ស្វែងរកការពិត

លេខ១៣៥ ខែមីនា ឆ្នាំ២០១១

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ឪព្រះវិហារថែមស៍ .......................................................................១

◆តើគួរអនុញ្ញាតឲ្យចុងចោទនៅក្រៅឃុំ ..................................................៣

### ផ្នែកឯកសារ

◆ភាពភ័យខ្លាចដែលបន្សល់ពីរបបខ្មែរក្រហម ........................................៤

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ទឹកដីនៃការផ្សះផ្សា ៖ កសាងសន្តិភាពនិងការអប់រំ .......................៨

◆ដំណើរជីវិតរបស់ សែ វួចនី ......................................................៣៣

### ផ្នែកច្បាប់

◆តើអ្វីជាអំពើប្រល័យពូជសាសន៍..............................................៣៤

### វេទិកាពិភាក្សាសាធារណៈ

◆ការសន្មតទុកជាមុនថាមានការសម្លាត់នៅ ...................................៣៩

◆ការពិតនិងការចងចាំ..............................................................៤៥

◆ការអង្កេតទៅលើការប្រកាសសាលក្រម ឌុច ............................៤៨

◆បិសាចមនុស្សជាតិ ៖ តើមេដឹកនាំខ្មែរក្រហមអាចទទួលបាន ........៥២

◆ថ្ងៃ៧មករាជាថ្ងៃរំដោះ .......................................................៥៤

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆រឿងរ៉ាវជីវិតរបស់ម្តាយខ្ញុំ..................................................៥៧



ប្រាសាទព្រះវិហារ

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាដៃលេខនេះ ៖** វ៉ាន់ថាន់ ពោដារ៉ា, អ៊ុំប ប៉ុន, ចេស៊ីកា គៀសាន់, អេង កុកថាយ, សារ៉ា ចូនឌីកឃិន, លន់ ដាលីន, វីល្លៀម សាបាស់, គ្រីស្តា នែលសុន, ចេន អានហ៊ើល, ដូឌី ឡេដើរ៉ូដ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា **អ្នកបកប្រែ ៖** ជា ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

# ឌីព្រះវិហារថៃមស៍ :

## កាសែតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ក្នុងឆ្នាំ២០១១នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្តើមដំណើរការបោះពុម្ពផ្សាយកាសែតប្រចាំសប្តាហ៍ដែលមានឈ្មោះថា *ឌីព្រះវិហារថៃមស៍* ។

### សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ២០០០មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពទស្សនាវដ្តី *ស្វែងរកការពិត* ដើម្បីអប់រំសាធារណជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ជំរុញឲ្យមានការពិភាក្សាស្តីពីបញ្ហាទាក់ទងនឹងខ្មែរក្រហម និងជំរុញឲ្យមានភាពយុត្តិធម៌និងការផ្សះផ្សានៅកម្ពុជា ។

ទស្សនាវដ្តី *ស្វែងរកការពិត* មានគោលដៅផ្សព្វផ្សាយដល់អ្នកដែលនៅរស់រានដីវិតពីរបបខ្មែរក្រហម ទាំងអ្នកដែលរស់នៅទីក្រុង និងអ្នកដែលរស់នៅទីជនបទ ។ អំឡុងពេលនៃការបង្កើតឲ្យមានសាលាក្តីពិសេសខ្មែរក្រហម និងការកាត់ទោសប្រធានមន្ទីរស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទស្សនាវដ្តី *ស្វែងរកការពិត* បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានស៊ីជម្រៅ និងទាន់ហេតុការណ៍ទាក់ទងនឹងដំណើរការរបស់សាលាក្តីខ្មែរក្រហមនេះ ។

ទស្សនាវដ្តី *ស្វែងរកការពិត* ជាភាសាខ្មែរ ត្រូវបានចែកចាយដោយឥតគិតថ្លៃដល់ស្ថាប័នរដ្ឋាភិបាលមួយចំនួន (រួមមានសាលាឃុំចំនួន១៧០០ទូទាំងប្រទេស) ការិយាល័យស្រុក-ខេត្ត មន្ទីរ-ក្រសួង រដ្ឋសភា អគ្គការក្រៅរដ្ឋាភិបាល បណ្ណាល័យសាកលវិទ្យាល័យនានានិងចែកជូនដល់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលរស់នៅទីដាច់ស្រយាល ។ ទស្សនាវដ្តី *ស្វែងរកការពិត* ជាភាសាអង់គ្លេសត្រូវបានបោះពុម្ពផ្សាយរៀងរាល់ត្រីមាសនិងចែកចាយដល់ស្ថានទូត សាកលវិទ្យាល័យនិងស្ថាប័ននានាទាំងក្នុងនិងក្រៅប្រទេស ។ ទស្សនាវដ្តីជាភាសាអង់គ្លេសមួយចំនួនត្រូវបានដាក់លក់ក្នុងទីផ្សារ ដើម្បីយកថវិកាមកទ្រទ្រង់ការបោះពុម្ពផ្សាយជាភាសាខ្មែរ ។

ទស្សនាវដ្តីទាំងពីរភាសាត្រូវបានបង្ហោះតាមប្រព័ន្ធអ៊ីនធឺណែតដើម្បីផ្តល់ឱកាសឲ្យអ្នកដែលរស់នៅបរទេសអាចអានបាន ។

ដប់មួយឆ្នាំបន្ទាប់ពីទស្សនាវដ្តី *ស្វែងរការពិត* ត្រូវបានបង្កើតឡើង មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្តើមដំណើរការបោះពុម្ពផ្សាយកាសែត *ឌីព្រះវិហារថៃមស៍* ដែលនឹងត្រូវបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស ។ កាសែតនេះនឹងត្រូវបោះពុម្ពជាក្រដាសដើម្បីរក្សានូវទំនៀមទម្លាប់នៃការអាននិងបង្ហោះនៅលើប្រព័ន្ធអ៊ីនធឺណែតដើម្បីឲ្យស្របទៅនឹងបច្ចេកវិទ្យាថ្មីៗនាពេលបច្ចុប្បន្ននិងដើម្បីទាក់ទាញទស្សនិកជនគ្រប់មជ្ឈដ្ឋាន ។ *ឌីព្រះវិហារថៃមស៍* គឺជាកាសែតមួយក្នុងចំណោមកាសែតមួយចំនួនតូចនៅក្នុងប្រទេសកម្ពុជាដែលបោះពុម្ពជាភាសាអង់គ្លេសនិងជាកាសែតមួយដែលដំណើរការដោយកម្ពុជាផ្ទាល់ ។ កាសែតនេះនឹងផ្តោតទៅលើហេតុការណ៍និងព័ត៌មានដែលពាក់ព័ន្ធនឹងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) និងដើម្បីប្រកួតប្រជែងជាមួយកាសែតផ្សេងទៀតនៅតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសគឺកាសែតបាងកកប៉ុស្តិ៍ និង ឌីណេសិន របស់ថៃ ។

ការចាប់ផ្តើមដំណើរការកាសែត *ឌីព្រះវិហារថៃមស៍* ស្របនឹងពេលធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក និងការកើនឡើងនៃឥទ្ធិពលរបស់សារព័ត៌មាននៅលើប្រព័ន្ធអ៊ីនធឺណែត ។ ខណៈពេលដែលកាសែតមួយចំនួនកំពុងផ្អាកដំណើរការរបស់ខ្លួន កាសែត *ឌីព្រះវិហារថៃមស៍* នឹងលេចចេញជារូបរាងឡើងដើម្បីបង្កើនការយល់ដឹងដល់សាធារណៈជនទាក់ទងនឹងបញ្ហានៅក្នុងស្រុកនិងនៅក្នុងតំបន់ ជាពិសេសបញ្ហាដែលទាក់ទងនឹងជម្លោះនិងអំពើប្រល័យពូជសាសន៍ ។ នៅពេលសង្គមជួបនូវបញ្ហា ជាការសំខាន់ណាស់ដែលយើងត្រូវតទល់ជាមួយនឹងបញ្ហាទាំងនោះ ហើយនិងធ្វើឲ្យ

*សន្តមប្រសើរឡើងវិញ ។ ជាមួយគ្នានោះដែរ ពេលសន្តមកំពុងតែមានភាពច្របូកច្របល់ សាធារណជនរឹតតែចង់ដឹងបន្ថែមពីអ្វីដែលកំពុងតែកើតឡើង ។*

## ***ហេតុអ្វីបានជាត្រូវប្រើឈ្មោះ «ព្រះវិហារ» ?***

*ព្រះវិហារគឺជាខេត្តដាច់ស្រយាលមួយនៅក្នុងប្រទេសកម្ពុជា ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ និងជាខេត្តមួយដែលមិនសូវមានប្រជាជនកម្ពុជាទៅទស្សនាប៉ុន្មានទេ ។ ប្រាសាទព្រះវិហារដែលត្រូវបានសាងសង់ឡើងនៅសតវត្សរ៍ទី១២ មានទីតាំងឋិតនៅលើជម្រាលភ្នំដងរែកនៃព្រំប្រទល់ប្រទេសថៃ និងកម្ពុជា ។ ក្នុងខែកក្កដា ឆ្នាំ២០០៨ ប្រាសាទនេះត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូ ដែលធ្វើឲ្យរដ្ឋាភិបាលថៃមានការខឹងសម្បា និងបន្តទាមទារប្រាសាទនេះថាជាទ្រព្យសម្បត្តិរួម បើទោះបីជាមានសេចក្តីសម្រេចកាលពីឆ្នាំ ១៩៦២ ដោយតុលាការយុត្តិធម៌អន្តរជាតិនៅទីក្រុងឡាអេថា កម្ពុជាជាអ្នកគ្រប់គ្រងប្រាសាទនេះក៏ដោយ ។ ខណៈពេលដែលប្រទេសថៃជួបប្រទះនូវអស្ថិរភាពផ្នែកនយោបាយ បញ្ហាប្រាសាទព្រះវិហារបានជំរុញឲ្យមានជម្លោះនៅតាមព្រំដែន បណ្តាលឲ្យមានការវាយប្រយុទ្ធគ្នារវាងប្រទេសទាំងពីរបីបួនលើករួចមកហើយ ដែលជាហេតុធ្វើឲ្យទាហានទាំងសងខាងមួយចំនួនស្លាប់បាត់បង់ជីវិតនិងរបួស ។ ភាពតានតឹងបានបន្តទៅក្នុងតំបន់នោះ ដែលធ្វើឲ្យមានការដាក់ពង្រាយទ័ពនៅតាមព្រំដែននៃប្រទេសទាំងពីរ ។ ជម្លោះស្តីពីប្រាសាទព្រះវិហារនេះបានធ្វើឲ្យមានការព្រួយបារម្ភដល់ប្រទេសនានាដែលជាសមាជិកអាស៊ាននិងបានក្លាយទៅជារបៀបវារៈដ៏សំខាន់របស់សមាគមអាស៊ានទាំងមូល ។ អាស្រ័យហេតុនេះ ក្នុងនាមជានិមិត្តរូបមួយនៃកេរដំណែលកម្ពុជា ព្រះវិហារគឺជាឧទាហរណ៍មួយប្រភេទនៃជម្លោះក្នុងតំបន់ដែលកាសែត ឌឺព្រះវិហារថៃមស៍ នឹងផ្តោតជាសំខាន់ទៅលើ ។ ឈ្មោះ «ព្រះវិហារ» ត្រូវបានជ្រើសរើសយកមកប្រើប្រាស់ដោយហេតុផលខាងលើនេះ ។*

## ***គោលបំណង***

*កាសែត ឌឺព្រះវិហារថៃមស៍ នឹងផ្តោតទៅលើរឿងរ៉ាវនិងហេតុការណ៍សំខាន់ៗនៅប្រទេសកម្ពុជា និងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលកាសែតផ្សេងទៀតមិនបានឬមិនអាចធ្វើបានដោយហេតុផលនយោបាយនិងហិរញ្ញវត្ថុ ។ កាសែត ឌឺព្រះវិហារថៃមស៍ នឹងផ្តោតទៅលើប្រធានបទសំខាន់ពីរគឺ ៖*

### ***១) ផ្តល់ការយល់ដឹងពីអំពើប្រល័យពូជសាសន៍ឬជម្លោះទូទាំងតំបន់អាស៊ីអាគ្នេយ៍ ៖***

*នៅក្នុងប្រទេសកម្ពុជា ទោះបីជាជម្លោះទើបតែបញ្ចប់ទៅជាងមួយទសវត្សរ៍ក៏ដោយ ក៏ការយល់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមមិនសូវមានភាពទូលំទូលាយដែរ ។ ជាងនេះទៅទៀត អំពើប្រល័យពូជសាសន៍និងជម្លោះផ្សេងៗមិនត្រឹមតែបានកើតឡើងនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ តែថែមទាំងកើតមាននៅតំបន់ផ្សេងៗទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ដូចជា ភូមា ឥណ្ឌូនេស៊ី និងថៃជាដើម ។ ឌឺព្រះវិហារថៃមស៍ នឹងគ្របដណ្តប់ព័ត៌មានអំពីរឿងរ៉ាវជម្លោះនិងអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលនឹងជួយជំរុញឲ្យមានការយល់ដឹងពីឫសគល់និងមូលហេតុនៃជម្លោះ ក្នុងគោលបំណងទប់ស្កាត់មិនឲ្យមានការប្រព្រឹត្តកំហុសដដែលនេះម្តងទៀត ។*

*អាស្រ័យហេតុនេះ ឌឺព្រះវិហារថៃមស៍ នឹងដើរតួនាទីជាយន្តការមួយក្នុងការចែករំលែកនូវបញ្ហាដែលប្រទេសកម្ពុជាបានប្រឈមមុខនឹងកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងការស្វែងការផ្សះផ្សា ។ ឌឺព្រះវិហារថៃមស៍ ក៏នឹងផ្តោតជាពិសេសទៅលើការវិវឌ្ឍរបស់សាលាក្តីខ្មែរក្រហមទាក់ទងនឹងការកាត់សេចក្តីករណី ០០២ នៃមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងបួនរូប ដើម្បីធានាថាព័ត៌មានស្តីអំពីការកាត់ទោសនេះបានចែកចាយទៅដល់សាធារណជនទាន់ពេលវេលា ។*

### ***២) ផ្តល់ការយល់ដឹងពីព័ត៌មាន និងហេតុការណ៍ដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន***

*បន្ថែមទៅលើជម្លោះនិងអំពើប្រល័យពូជសាសន៍ ឌឺព្រះវិហារថៃមស៍ នឹងគ្របដណ្តប់ព័ត៌មានទាក់ទងនឹងបញ្ហាសំខាន់ៗដែលកំពុងកើតឡើងនៅកម្ពុជានិងតំបន់ផ្សេងទៀតដែលអាចបង្កឲ្យមានជម្លោះ ។ អត្ថបទនៅក្នុងកាសែត ឌឺព្រះវិហារថៃមស៍ នេះក៏នឹងរៀបរាប់ពីការគ្រប់គ្រងធនធានដីនិងធម្មជាតិផងដែរ ។*

**ឆាំង យុ**

# តើគួរអនុញ្ញាតឱ្យចុងចោទនៅក្រៅឃុំ?

## ការស្ទាបស្ទង់មតិជាមួយប្រជាជនកម្ពុជា

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចបើកសវនាការសួរដេញដោលភ្លាម កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ លើសំណើសុំបន្ទាន់របស់មេធាវីចុងចោទសុំដោះលែងឲ្យនៅក្រៅឃុំចំពោះចុងចោទចំនួនបីរូបគឺ នួន ជា, ខៀវ សំផន និងអៀង ធីរិទ្ធ ។

យោងតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ តុលាការបានចោទប្រកាន់ចុងចោទទាំងបីខាងលើពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។ ចុងចោទទាំងបីខាងលើ ត្រូវបានតុលាការនាំខ្លួនយកមកឃុំបណ្តោះអាសន្ននៅឯមន្ទីរឃុំឃាំងរបស់សាលាក្តីខ្មែរក្រហមកាលឆ្នាំ២០០៧ ។




នៅពេលឡើងថ្លែងនៅចំពោះមុខចៅក្រម មូលហេតុចម្បងរបស់មេធាវីចុងចោទ ដែលស្នើសុំឲ្យកូនក្តីរបស់ខ្លួននៅក្រៅឃុំគឺទាក់ទិននឹងការឃុំខ្លួនកូនក្តីរបស់ខ្លួនហួសរយៈពេលកំណត់ដែលមានចែងនៅក្នុងវិធាន៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាការឆ្លើយតបនឹងសំណើរបស់មេធាវីចុងចោទ សហព្រះរាជអាជ្ញាបានលើកសម្អាងហេតុជាច្រើនដែលឆ្លុះបញ្ចាំងឲ្យឃើញថា ការដោះលែងឲ្យនៅក្រៅឃុំមិនគួរត្រូវបានធ្វើឡើងតាមសំណើទេ ដោយយល់ថា មានហេតុផលជាច្រើនដែលចុងចោទនឹងរត់គេចខ្លួន ហើយរដ្ឋអំណាចពុំទាន់ធានាបានច្បាស់លាស់នៅឡើយអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់ចុងចោទប្រសិនបើដោះលែងឲ្យនៅក្រៅឃុំ ។

ក្រោយពីអង្គជំនុំជម្រះបញ្ចប់សវនាការសួរដេញដោលភ្លាម មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទាបស្ទង់មតិទៅលើពលរដ្ឋកម្ពុជាចំនួន១៥៣នាក់ ក្នុងនោះមានសិស្ស-និស្សិត គ្រូបង្រៀន មន្ត្រីរដ្ឋាភិបាល មន្ត្រីអង្គការក្រៅរដ្ឋាភិបាលនិងក្រុមហ៊ុនឯកជន អតីតកម្មាភិបាលខ្មែរក្រហម ថ្នាក់ដឹកនាំភូមិ-ឃុំ ព្រះសង្ឃ ដូនជី ហាគីម ទួន ។ លទ្ធផលនៃការស្ទាបស្ទង់មតិបានបង្ហាញថា ៦៥ភាគរយនៃចំនួនប្រជាជនទាំង១៥៣នាក់ មិនយល់ព្រមឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោះលែងចុងចោទទាំងបីនាក់ឲ្យនៅក្រៅឃុំទេ ។ អ្នកទាំងនេះយល់ឃើញថា ចុងចោទទាំងបីនាក់បានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ធ្ងរចំពោះប្រជាជននិងប្រទេសជាតិទាំងមូលកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ហើយការបន្តឃុំឃាំងចុងចោទទាំងបី គឺជារឿងចាំបាច់បំផុតដើម្បីធានាថាចុងចោទមានវត្តមាននៅក្នុងបន្ទប់សវនាការពេលសាលាក្តីខ្មែរក្រហមបើកអង្គជំនុំជម្រះ ។ ចំណែកឯ២១ភាគរយយល់ឃើញថា ចុងចោទគួរតែត្រូវបានដោះលែងឲ្យនៅក្រៅឃុំ ក៏ប៉ុន្តែត្រូវទទួលការការពារពីកងសន្តិសុខឲ្យបានត្រឹមត្រូវដើម្បីធានាបានថាចុងចោទមិនអាចគេចខ្លួនបាន ។ អ្នកទាំងនេះយល់ឃើញទៀតថាចុងចោទទាំងបីមានវ័យចំណាស់ទៅហើយ ហើយគួរតែមានឱកាសនឹងធ្វើបុណ្យទានខ្លះ ។ អ្នកដែលត្រូវបានស្ទាបស្ទង់មតិចំនួន១១ភាគរយ មិនមានយោបល់អ្វីទាំងអស់ទាក់ទងទៅនឹងសំណួរថាតើគួរដោះលែងឬមិនដោះលែងឲ្យនៅក្រៅឃុំ ។ អ្នកទាំងនេះមានជំនឿលើតុលាការខ្មែរក្រហម ហើយចង់ឲ្យតុលាការនេះធ្វើការសម្រេចចិត្តដោយខ្លួនឯងអំពីថាតើគួរឃុំខ្លួនមេដឹកនាំខ្មែរក្រហមបន្តទៀតឬយ៉ាងណា ។ ៣ភាគរយនៃអ្នកដែលត្រូវបានធ្វើការស្ទាបស្ទង់មតិមិនមានយោបល់អ្វីទាំងអស់ទាក់ទងទៅនឹងសំណួរសួរថាតើគួរដោះលែង ឬមិនដោះលែងចុងចោទឲ្យនៅក្រៅឃុំ ។

**ទ៉ាន់ថាន់ ពៅដារ៉ា**

# ភាពភ័យខ្លាចដែលបន្សល់ពីរបបខ្មែរក្រហម

សារ៉េត សារី ហៅ សុខសោម សុផានី សព្វថ្ងៃរស់នៅខេត្តកណ្តាលគឺជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនដែលទទួលរងនូវការប៉ះទង្គិចផ្លូវចិត្តដោយសាររបបខ្មែរក្រហម ក្រោយពីរបបនេះដួលរលំទៅ ។ សារី បានឃើញខ្មែរក្រហមសម្លាប់មនុស្សយ៉ាងសាហាវនៅចំពោះមុខ ព្រមទាំងហេតុការណ៍ដែលយកឪពុករបស់គាត់ទៅសម្លាប់បានធ្វើឲ្យ សារី ចេះតែស្រមើស្រមៃឃើញការធ្វើទារុណកម្មលើឪពុករបស់គាត់និងមានជំងឺភ្លេចភ្លាំងច្រើនរហូតដល់សព្វថ្ងៃនេះ ។

នៅសម័យសង្គមរាស្ត្រនិយម ឪពុករបស់ សារី ធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧០ ពេលដែលមានការវាយប្រយុទ្ធគ្នាខ្លាំង ម្តាយរបស់ សារី ដែលទើបតែឆ្លងទន្លេបានកូនភ្លោះពីរក៏បានធ្លាក់ខ្លួនឈឺ ។ ក្រោយមកដោយឃើញស្ថានភាពច្របូកច្របល់ខ្លាំង គ្រួសាររបស់ សារី ក៏បានរត់ភៀសខ្លួនទៅរស់នៅភូមិផ្សេងវិញ ។ ប៉ុន្តែធ្វើដំណើរបានពាក់កណ្តាលផ្លូវម្តាយរបស់ សារី ក៏បានស្លាប់ដោយសាកសពរបស់គាត់កប់នៅមុខវត្តពោធិ៍បាន ។ បន្ទាប់មកឪពុករបស់ សារី បាននាំប្រពន្ធនិងកូនៗមករស់នៅភូមិជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ជាមួយប្អូនស្រីរបស់គាត់វិញ ចំណែកគាត់ត្រឡប់ទៅធ្វើគ្រូបង្រៀននៅសាលាជ្រោយតាកែវដោយពេលទំនេរពីការងារទើបមកលេងកូនៗនៅកៀនស្វាយ ។ ថ្ងៃមួយពេលមកដល់ស្រុកកៀនស្វាយ ឪពុករបស់ សារី ត្រូវបានទាហាន លន់ នល់ ចាប់គាត់យកទៅដាក់គុកនៅព្រៃសដោយចោទថាជាមេខ្មែរក្រហម ។ ឪពុក សារី ជាប់គុកនៅទីនោះអស់រយៈពេលជិតមួយឆ្នាំទើបបងប្រុសរបស់គាត់ដែលធ្វើជាប៉ូលិសរត់ការសុំដោះលែងគាត់ឲ្យមានសេរីភាពវិញ ។ ក្រោយចេញពីគុកមក ឪពុករបស់ សារី ក៏នៅតែបន្តអាជីពជាគ្រូបង្រៀនផងដែរ ។

នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ គឺជារដូវបុណ្យចូលឆ្នាំខ្មែរប្រជាជននៅក្នុងភូមិជ្រោយអំពិល នាំគ្នាធ្វើម្ហូបអាហារយកទៅប្រគេនព្រះសង្ឃនៅឯវត្ត ដូចឆ្នាំមុនៗដែរ និងអ្នកខ្លះទៀតនាំគ្នាលេងល្បែងប្រជាប្រិយនៅតាមដងផ្លូវហើយថែមទាំងសើចហ៊ោកញ្ជ្រៀវយ៉ាងអឺងកង ។ ប៉ុន្តែមិនយូរប៉ុន្មានសំឡេងសើចទាំងនោះបានជំនួសដោយសំឡេងយំស្រែកពេញភូមិដោយខ្លះនាំគ្នាពួនសម្ងំលាក់ខ្លួនប្លុក៏ចាកចេញពីលំនៅដ្ឋានរៀងៗខ្លួន ព្រោះតែស្នូរគ្រាប់កាំភ្លើងផ្ទុះកាន់តែខិតជិតមកដល់ ។ មួយសន្ទុះក្រោយមក សារី បានឃើញយោធាខ្មែរក្រហមប្រដាប់ដោយអាវុធប្រកាសប្រាប់ប្រជាជនឲ្យចេញពីទីក្រុងទៅកាន់ទីជនបទ ។ ពេលនោះ សារី បានលួចសម្លឹងមើលមុខយោធាខ្មែរក្រហមយ៉ាងភ័យតក់ស្លុតជាទីបំផុត ។ ថ្ងៃនោះគាត់បានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់បុរសចំណាស់ម្នាក់ដែលកំពុងតែអង្គុយនៅក្នុងអង្រឹងខណៈដែលកម្មាភិបាលទាំងនេះសុំគោរបស់គាត់មកកាប់ហូប តែគាត់បដិសេធមិនព្រមឲ្យ ។ ក្រោយមកទៀត នៅពេលយប់



សារ៉េត សារី ហៅ សុខសោម សុផានី (បច្ចុប្បន្ន)



សារ៉េត សារី សុផានី (១៩៧៥)

មួយពូជីដូនមួយរបស់ សារី ចំនួនបួននាក់ដែលរស់នៅខាងក្រោយផ្ទះរបស់ សារី ក៏ត្រូវខ្មែរក្រហមបាញ់សម្លាប់ដែរ ដោយសារតែជាប់និន្នាការកាលពីរបប លន់ នល់ ។ ដោយសារមានការភ័យខ្លាចថាខ្មែរក្រហមស៊ើបដឹងថាឪពុកគាត់ក៏ធ្វើជាគ្រូបង្រៀនដែរ សារី ក៏បបួលឪពុកទៅរស់នៅស្រុកកំណើតខាងម្តាយនៅកោះធំវិញ ។

សារី និងក្រុមគ្រួសារបានធ្វើដំណើរតាមផ្លូវជាតិលេខ១ រហូតដល់ឃុំគគីធំដែលជាស្រុកកំណើតរបស់ប្រពន្ធឪពុកមាគាត់ ហើយបានឈប់សម្រាកនៅទីនោះមួយថ្ងៃទើបបន្តដំណើរទៅមុខទៀត ។ ប៉ុន្តែពេលដែលមកដល់ផ្ទះ សារី បែរជាឃើញខ្មែរក្រហមយកផ្ទះរបស់គាត់ធ្វើជារោងម៉ាស៊ីនកិនស្រូវទៅវិញ ។ ឃើញដូច្នេះ សារី បានធ្វើដំណើរសំដៅទៅរកផ្ទះម្តាយធំបង្កើតរបស់គាត់វិញ ។

នៅឆ្នាំ១៩៧៦ ឪពុករបស់ សារី ក៏បាននាំកូនៗមករស់នៅភូមិដើមពោធិ៍ ឃុំជ្រោយតាកែវ ស្រុកកោះធំទាំងអស់គ្នា ។

នៅទីនោះ អង្គការបានចាត់តាំងឲ្យឪពុក សារី ធ្វើការនៅក្នុងកងបុរសមានភារកិច្ចជីកប្រឡាយ លើកទំនប់ និងធ្វើស្ពានតាំងពីព្រឹកព្រលឹមដល់ព្រលប់ ។ ក្រោយមក អង្គការបាន ផ្លាស់ឪពុក សារី ឲ្យដើររែកលាមកមនុស្សយកទៅធ្វើជី ធម្មជាតិដើម្បីយកទៅបាចក្នុងស្រែវិញ ។ ចំណែក សារី និងប្អូនៗចេញទៅធ្វើការនៅកងផ្សេងពីគ្នាដោយត្រឡប់មកស្នាក់នៅជុំគ្នាវិញនៅពេលយប់ ។

មិនយូរប៉ុន្មាន អង្គការក៏បានបំបែកប្អូនៗបីនាក់របស់ សារី ឲ្យទៅនៅកងនារី ចំណែកគាត់ដែលខស្យាហ៍ឈឺច្រើនស្ថិតនៅក្នុងកងចល័តឃុំ ។ ដោយសារតែ សារី មានជំងឺគ្រុនចាញ់ដែលធ្វើឲ្យក្តៅញាក់ ក្រោយមកអង្គការបានបញ្ជូនគាត់ឲ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។ មន្ទីរពេទ្យនេះមានពេទ្យជាច្រើននាក់ ប៉ុន្តែសុទ្ធតែជាពេទ្យក្មេងៗដែលគ្មានជំនាញពេទ្យច្បាស់លាស់ទេ ។ ចំណែកថ្នាំសម្រាប់ព្យាបាលជំងឺគឺមានតែថ្នាំបុរាណផ្សំពីឫសឈើយកទៅដាំផឹកតែប៉ុណ្ណោះ ។

ក្រោយពីជាសះស្បើយពីជំងឺ អង្គការបានបញ្ជូន សារី ឲ្យទៅធ្វើការនៅក្នុងកងនារីវិញ ។ ថ្ងៃមួយស្រាប់តែមានអ្នកភូមិម្នាក់មកប្រាប់ សារី ថា ឪពុកគាត់ឈឺធ្ងន់ណាស់នៅផ្ទះ ។ ដូច្នេះ សារី ក៏បានទៅសុំប្រធានកងឈ្មោះ ស្រ៊ាង ដើម្បីទៅមើលឪពុក ។ ប៉ុន្តែប្រធានកងមិនត្រឹមតែមិនអនុញ្ញាតឲ្យទៅនោះទេ ថែមទាំងស្រែកសំឡុតដាក់គាត់ទៀតថា «មិត្តទៅមើលឪពុកមិត្តឯងបានជាពីជំងឺឬ? មិត្តឯងមិនមែនពេទ្យទេ» ។ ទោះបីទទួលបានការស្តីបន្ទោសយ៉ាងណាក៏ដោយ ក៏



ឪពុករបស់ សារ៉ែត សារី ថតឆ្នាំ១៩៧៣

សារី នៅតែព្យាយាមទទូចសុំប្រធានកងរហូតទាល់តែគាត់អនុញ្ញាត ដោយសន្យាថា «ខ្ញុំសុំចេញនៅពេលល្ងាចម៉ោង៤ទៀបភ្លឺនឹងត្រឡប់មកធ្វើការឲ្យទាន់ពេលវេលា» ។ នៅវេលាម៉ោងប្រហែលជា៦ល្ងាច ក្រោយពីបញ្ចប់ការងាររួច សារី រត់ពីកន្លែងធ្វើការនៅទួលរំលេច សំដៅទៅរកឪពុក ។ ប៉ុន្តែរត់មកដល់ពាក់កណ្ដាលផ្លូវ សារី ស្រាប់តែឃើញមនុស្សប្រុសម្នាក់ដើរមកពីខាងមុខគាត់ដោយមានលីកាំបិតផ្គាក់នៅលើស្មា ។ ពេលនោះ សារី បានរត់ទៅពួននៅកន្លែងស្ងាត់មួយលុះត្រាតែបាត់ស្រមោលមនុស្សប្រុសម្នាក់នោះ ទើបគាត់បន្តដំណើរទៅមុខទៀត ។ ពេលមកដល់ព្រៃដើមជ្រៃស្ថិតក្នុងភូមិលេខ៩ សារី ក៏ប្រទះឃើញខ្មែរក្រហមកំពុងតែជុតសាកសពដែលទើបនឹងស្លាប់ថ្មីៗដែលធ្វើឲ្យគាត់កាន់តែភ័យខ្លាចខ្លាំងឡើង ព្រមទាំងបារម្ភពីឪពុករបស់គាត់ទៀត ។ មកដល់ផ្ទះ សារី បានឃើញរាងកាយរបស់ឪពុកទ្រុឌទ្រោមយ៉ាងខ្លាំងដោយគាត់បានសម្លឹងមើលមុខឪពុកហើយបង្ហូរទឹកភ្នែកដោយមិនដឹងខ្លួន ។ សារី អាណិតឪពុកយ៉ាងខ្លាំងព្រោះគាត់ធ្លាប់តែធ្វើជាគ្រូបង្រៀនស្លៀកពាក់ស្អាតបាតនិងហូបចុកគ្រប់គ្រាន់ ប៉ុន្តែពេលនេះអ្វីៗខុសប្លែកពីមុនទាំងស្រុង ។ សារី រៀបរាប់ថា «ដៃប៉ាដែលធ្លាប់តែកាន់ប៊ិច កាន់សៀវភៅ ពេលនេះដៃប៉ាកាន់ចប កាន់បង្គីឡើងក្រិនទាំងអស់» ។ មួយសន្ទុះក្រោយមក ទើបឪពុក សារី បានប្រាប់គាត់ឲ្យដើររកមើមសាគូត្រចៀកក្រាញ់និងជន្លេនមកធ្វើថ្នាំឲ្យគាត់ហូប ។ ដោយសារតែជំងឺរបស់ឪពុក សារី មិនទាន់ជាសះស្បើយ គាត់ក៏ទៅសុំប្រធាននារីភូមិឈ្មោះ គន្ធ ជួយកិនអង្ករ បុកអង្ករ និងស្រិតអង្ករជាមួយស្ត្រីវ័យចាស់ម្នាក់មួយរយៈ ។ ក្រោយពីទទួលបានការអនុញ្ញាត សារី នៅជួយកិនអង្ករនៅក្នុងភូមិជាមួយកងយាយៗ លុះពេលរសៀលទើបត្រឡប់មកផ្ទះវិញ ។ ដោយឪពុករបស់គាត់មិនមានអ្វីហូបដូច្នេះ សារី បានចូលទៅក្នុងរោងបាយដើម្បីសុំអង្ករពីបុរសម្នាក់ឈ្មោះ មោក ដែលជាកូនអតីតសិស្សឪពុកគាត់ ។ ដោយសារតែក្ដីអាណិត មោក បានលួចវេចខ្ចប់អង្ករឲ្យ សារី ប្រហែលជាពីរកំប៉ុង ។ ពេលបានអង្ករដាំបាយ ហើយ សារី ក៏បានទៅលួចស្ទូចត្រីយកមកធ្វើម្ហូបឲ្យឪពុករបស់គាត់ហូបទៀត ។ ប៉ុន្តែពេលនោះស្រាប់ស្ត្រីម្នាក់ឈ្មោះ សែម ដែលរស់នៅជិតផ្ទះ ឃើញហើយបានទៅរាយការណ៍ប្រាប់ប្រធានភូមិឈ្មោះ ភុំ ឲ្យមកហៅគាត់ទៅកសាង ។ ភុំ បានព្រមានថា «មិត្តឯងហ៊ានលួចស្ទូចត្រីក្បត់អង្គការប្រយ័ត្នបាត់ខ្លួន បើមិត្តឯងមិនឈប់ទេ ប្រយ័ត្នខ្ញុំឲ្យទៅស្ទូចត្រីចិញ្ចឹមមួយសហករណ៍» ។ សារី នៅមើលថែទាំឪពុកបានរយៈពេលប្រហែលជា១០ថ្ងៃ ក៏សុំលាឪពុកទៅធ្វើការនៅក្នុងអង្គភាពវិញ ។ នៅថ្ងៃនោះស្រាប់តែ សារី ឃើញកូនសិស្សរបស់ឪពុកគាត់ឈ្មោះ ម៉ុន ជិះកង់មក ហើយនិយាយថា «អង្គការមើលឃើញថាលោកគ្រូនៅឈឺនៅឡើយដូច្នេះឲ្យលោកគ្រូទៅព្យាបាលនៅមន្ទីរពេទ្យសិន» ។ បន្ទាប់មក ឪពុករបស់ សារី បានប្រាប់ទៅ ម៉ុន វិញថា «ពីរ-បីថ្ងៃទៀតខ្ញុំនឹងទៅធ្វើការវិញព្រោះឥឡូវខ្ញុំបានធូរច្រើនហើយ» ។ ប៉ុន្តែ ម៉ុន បន្តទៀតថា មិនបានទេត្រូវតែទៅដេកពេទ្យបន្តិចទៀតនឹងឲ្យគេយកកង់មកឌុប ។ សារី បាននិយាយទាំងអួលដើមកទៅកាន់ឪពុកថា «ប៉ាអើយ! អ្នកដែលគេហៅទៅពេទ្យគឺហៅទៅមន្ទីរអប់រំមិនដែលឃើញត្រឡប់មកវិញទេ ហើយប្រហែលជាគេយកប៉ាទៅសម្លាប់ហើយ» ។ សារី នៅចាំបានថា ពេលនោះគឺនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ ដែលជាថ្ងៃគាត់បានឃើញឪពុកគាត់ជាលើកចុងក្រោយដោយគាត់បានស្រក់ទឹកភ្នែកហើយបានផ្ដាំថា «ប៉ាទៅមិនស្លាប់ទេ កូនឯងបងគេ ត្រូវនៅមើលថែប្អូនៗ» ។ មួយសន្ទុះក្រោយមក មោក នៅខាងរោងបាយដែល សារី ធ្លាប់សុំអង្ករបានមកឌុបឪពុកគាត់យកទៅ ។ ពេលត្រឡប់មកអង្គភាពវិញប្រធានកងឈ្មោះ ស្រ៊ាង ក៏បានសើចចំអកឲ្យគាត់ទៀត ក្រោយពីដឹងថាអង្គការយកឪពុកគាត់ទៅដេកពេទ្យ» ។

នៅឆ្នាំ១៩៧៨ អង្គការបានផ្លាស់ សារី និងមិត្តភក្តិម្នាក់ទៀតរបស់គាត់ឈ្មោះ រស់ ច័ន្ទមុនី ឲ្យទៅធ្វើការនៅអង្គភាពថ្មីជាមួយគ្នា ។ ពេលទៅដល់ទីនោះ គាត់ទាំងពីរនាក់បានជួបនឹងគ្រោះទឹកជំនន់យ៉ាងខ្លាំង ។ ដូច្នេះដើម្បីគេចពីគ្រោះថ្នាក់នេះគាត់ទាំងពីរនាក់ក៏នាំគ្នារត់មកនៅក្នុងកងច្រូតស្រូវវិញ ។ ធ្វើការបានមួយរយៈ អង្គការបានកោះហៅប្រជាជនទាំងអស់ឲ្យចូលរួមធ្វើមីទ្ទីង១០ថ្ងៃម្ដងដោយមានចែកបបរស្ករត្នោតឲ្យហូបព្រមទាំងអនុញ្ញាតឲ្យត្រឡប់មកលេងផ្ទះ១០រៀងរាល់ថ្ងៃម្ដងផង ។ ពេលនោះ សារី និងសមាជិកទាំងអស់មានចិត្តសប្បាយរីករាយយ៉ាងខ្លាំងពីព្រោះថាកម្រនឹងមានឱកាសបានជួបជុំក្រុមគ្រួសារណាស់ ។ ប៉ុន្តែ សារី

បានមកលេងផ្ទះតែម្តងប៉ុណ្ណោះពីព្រោះខ្មែរក្រហមបានរុះរើផ្ទះរបស់គាត់ចោលអស់ហើយម្យ៉ាងទៀតដោយសារតែឪពុករបស់គាត់បានបាត់ខ្លួន ហើយនិងបងប្អូននៅធ្វើការតាមកងផ្សេងៗគ្នា ។

នៅដើមឆ្នាំ១៩៧៩ពេលដែលកងទ័ពវៀតណាមចូលមកដល់ទន្លេមេគង្គ មិត្តភក្តិដែលធ្វើការនៅអគ្គភាពជាមួយគ្នាក៏មានជំងឺធ្ងន់ ។ ពេលនោះអង្គការចាត់តាំងគាត់ឲ្យយកកង់មកដឹកមិត្តភក្តិគាត់ទៅព្យាបាលនៅមន្ទីរពេទ្យនៅជ្រោយតាកែវ ។ នៅពេលត្រឡប់មកវិញ សារី បានជួយនាំកូនក្មេងឡើងលើទូកដើម្បីឆ្លងទៅត្រើយម្ខាងរហូតទល់ភ្លឺ ។ ក្រោយមកដោយសារតែមានកំហឹងជាមួយយោធាខ្មែរក្រហម សារី បានបបួលមិត្តភក្តិរបស់គាត់ចូលធ្វើទាហានមួយកងទ័ពវៀតណាមដើម្បីប្រយុទ្ធជាមួយខ្មែរក្រហម ។ នៅទីនោះ សារី បានជួបប្អូនស្រីរបស់គាត់ សុខសោម ច័ន្ទដល្លា ដែលត្រូវខ្មែរក្រហមចាប់យកទៅដាក់គុកនៅពោធិ៍ទន្លេកាលពីឆ្នាំ១៩៧៧ ។ សារី សប្បាយចិត្តជាខ្លាំងព្រោះមិននឹកស្មានថា ដល្លា នៅរស់រានមានជីវិតនោះទេ ។ ដល្លា បានរៀបរាប់ប្រាប់ សារី ថា ខ្មែរក្រហមបានឃុំគាត់ទៅលើផ្ទះដាក់អ្នកទោសមួយដោយអ្នកទោសទាំងអស់សុទ្ធតែត្រូវបានដាក់ខ្នោះដៃនិងជើង ពេលថ្ងៃទើបបណ្តើរឲ្យទៅធ្វើការនៅកន្លែងផ្សេងៗពីគ្នា ។ចំណែកវិធីសួរចម្លើយវិញគឺវាយនឹងដែករនាំងផ្ទះនិងស្នូកកាំភ្លើង ។ នៅទីនោះ ឪពុករបស់ សារី ក៏ជាប់ឃុំជាមួយ ដល្លា ដែរ ប៉ុន្តែអ្នកទាំងពីរធ្វើជាមិនស្គាល់គ្នា ។ ដល្លា បន្តថា «ខ្ញុំបានឃើញឪពុករបស់យើងមានស្នាមដាំខ្មៅពេញខ្លួន ។ ក្រោយមកមិនយូរប៉ុន្មាន ពេលអង្គការបានស៊ើបដឹងថាយើងទាំងពីរនាក់ត្រូវជាឪពុកនឹងកូន ខ្មែរក្រហមក៏បានចាប់ចងដៃចងជើងឪពុកយើង រួចសែងទម្លាក់ចូលទៅក្នុងកាណូតបញ្ជូនមកដាក់នៅមន្ទីរ១៥នៅកោះថ្មីវិញ ។ ចាប់តាំងពីពេលនោះមកខ្ញុំលែងបានទទួលដំណឹងពីគាត់រហូត» ។

នៅពេលដែលវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩ សារី បានតាមស៊ើបសួរអ្នកភូមិកោះថ្មីពីដំណឹងឪពុករបស់គាត់ ។ ពេលនោះដំណឹងដែលទទួលបានគឺថា ឃើញខ្មែរក្រហមបណ្តើរឪពុកគាត់ទៅធ្វើការដោយមានដាក់ច្រវាក់ជើងនិងយប់ឡើងទើបបណ្តើរយកទៅដាក់គុកវិញ ។ ក្រោយមក ក៏ឮដំណឹងថាខ្មែរក្រហមបានបាញ់សម្លាប់គាត់ចោលហើយ ។

សព្វថ្ងៃនេះ ទោះបីជាឪពុករបស់ សារី បានស្លាប់ទៅអស់រយៈពេលជាង៣០ឆ្នាំហើយក៏ដោយ ក៏រឿងនេះនៅតែដក់ជាប់នៅក្នុងចិត្តរបស់ សារី ជានិច្ច ។ សារី តែងតែនឹកឃើញពីអំពើព្រៃផ្សៃដែលខ្មែរក្រហមធ្វើមកលើឪពុកគាត់រហូតដល់ពេលខ្លះបណ្តាលឲ្យគាត់យល់សប្តិផង ។

**អ៊ិច ប៊ុន**

# ដំណឹងស្វែងរកប្អូនស្រី

នាងខ្ញុំឈ្មោះ ឌៀង ស៊ីផានី សព្វថ្ងៃនេះរស់នៅផ្ទះលេខ២០អា ផ្លូវលេខ៣៣៦ ក្រុមទី៥២ ភូមិទី៧ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។ ឪពុករបស់ខ្ញុំឈ្មោះ ឌៀង សាម និងម្តាយខ្ញុំឈ្មោះ ម៉ៃយ កាន និងមានបងប្អូនចំនួន៧នាក់ ១) ខ្ញុំ, ២) ប្អូនប្រុស ឌៀង សុផាត, ៣) ប្អូនប្រុស ឌៀង សាមចន្ទ្រាវុធ, ៤) ប្អូនប្រុស ឌៀង តារ៉ា, ៥) ប្អូនប្រុស ឌៀង សំសុផន, ៦) ប្អូនស្រី ឌៀង សុផល ហៅ ម៉ៅ និង ៧) ប្អូនស្រី ពៅ ឌៀង វណ្ណារី ។ នាងខ្ញុំសូមប្រកាសស្វែងរកប្អូនស្រីឈ្មោះ ឌៀង សុផល ហៅ ម៉ៅ ដែលបានបែកគ្នានៅឆ្នាំ១៩៧៨ នៅខេត្តបាត់ដំបង ។ មុនពេលបែកគ្នា សុផល ហៅ ម៉ៅ បានមកលេងផ្ទះដែលខ្ញុំស្នាក់នៅសហករណ៍ខេត្តបាត់ដំបង «ភូមិតាគង់ស្រុកភ្នំស្រុក» បានរយៈពេលមួយយប់ ទើបត្រឡប់ទៅកងចល័តបន្ទាយរំចេក «កងចល័តកុមារឈានមុខ» វិញ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងពីប្អូនស្រីឈ្មោះ សុផល ហៅ ម៉ៅ ឡើយ ។

ប្រសិនបើបងប្អូនណាស្គាល់ឈ្មោះ ឌៀង សុផល ហៅ ម៉ៅ ខាងលើនេះ សូមទំនាក់ទំនងមកទូរស័ព្ទលេខ ០ ១ ១ ២៧៨ ០៦៦ ឬ០ ១ ១ ៩ ១ ៤ ៥ ៥ ២ ឬក៏ទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរសព្ទលេខ ០២៣ ២១១ ៨៧៥ ។

**សូមអរគុណ**



# ទឹកដីនៃការផ្សះផ្សា កសាងសង្គមសន្តិភាព តាមរយៈការអប់រំ

***សេចក្តីសង្ខេប***

*ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១០ គ្រូបង្រៀនជាង២០០នាក់មកពីទូទាំងខេត្តនៃព្រះរាជាណាចក្រកម្ពុជា បានមកជួបជុំគ្នានៅខេត្តព្រះវិហារដើម្បីចូលរួមសិក្ខាសាលាគ្រូបង្រៀន និងក្រុមការងារ «ចងក្រងប្រវត្តិសាស្ត្រកម្ពុជា» ប្រចាំឆ្នាំលើកទីបីដែលជាផ្នែកមួយនៃគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំយុវជន និង កីឡា ។ សិក្ខាសាលានេះមានការចូលរួមពីសំណាក់គ្រូបង្រៀនដែលបានទទួលវគ្គបណ្តុះបណ្តាលស្តីអំពីកម្មវិធីនិងវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាលពីពាក់កណ្តាលនិងចុងឆ្នាំ២០០៩ ដែលជាផ្នែកមួយនៃការផ្តល់សិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តកម្មវិធីអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមថ្នាក់វិទ្យាល័យនិងសកលវិទ្យាល័យទាំងអស់នៅទូទាំងប្រទេសកម្ពុជាឲ្យបាននៅក្នុងបំណាច់ឆ្នាំ២០១៣ខាងមុខនេះ ។ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យធ្វើការប្រើប្រាស់សៀវភៅរបស់លោក ឌី ខាំបូលី ដែលមានចំណងជើងថា «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» អមជាមួយសៀវភៅណែនាំគ្រូបង្រៀននិងសៀវភៅលំហាត់សម្រាប់សិស្សដែលរៀបរៀងដោយបណ្ឌិត ផា ផល្លា និង លោក គ្រីស្តូហ្វឺ ឌៀរីង ។*

*សិក្ខាកាមសម្រាប់សិក្ខាសាលានៅខេត្តព្រះវិហារទាំងអស់បានចំណាយពេលនៅទីរួមខេត្តព្រះវិហាររយៈពេលមួយថ្ងៃដើម្បីស្តាប់បទបង្ហាញជាច្រើនរបស់វាគ្មិនជាតិនិងអន្តរជាតិព្រមទាំងការពិភាក្សារបស់គ្រូបង្គោលថ្នាក់ជាតិនិងអ្នកសម្របសម្រួលគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាមួយចំនួនដូចជា ការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការផ្សះផ្សា*

ជាតិ ទស្សនៈខុសប្លែកគ្នាស្តីពីការអត់ឱនទោសនិងសារសំខាន់នៃការចងក្រងប្រវត្តិសាស្ត្រ ។ នៅថ្ងៃទីពីរនៃសិក្ខាសាលានេះ គ្រូបង្រៀនទាំងអស់បានធ្វើដំណើរទៅទស្សនាប្រាសាទព្រះវិហារ ដែលជាប្រាសាទបុរាណដ៏ធំស្កឹមស្កៃមួយកសាងឡើងនៅក្នុងសម័យអង្គរហើយដែលមានសារសំខាន់សម្រាប់សង្គមកម្ពុជាសព្វថ្ងៃនេះ ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណង ៖

១) ពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈដល់គ្រូបង្រៀនថ្នាក់ជាតិនិងថ្នាក់ខេត្តដែលគ្រូបង្រៀនទាំងអស់នេះនឹងត្រូវផ្តល់វគ្គបណ្តុះបណ្តាលបន្តដល់ «គ្រូបង្រៀនថ្នាក់មូលដ្ឋាន» នៅក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់មូលដ្ឋាននាពេលខាងមុខនេះ ។

២) ត្រួតពិនិត្យឡើងវិញពីប្រសិទ្ធភាពស្តីពីយុត្តិសាស្ត្របង្រៀនថ្មីៗ

៣) ផ្តល់ការណែនាំសម្រាប់ការវិវឌ្ឍទៅមុខ និង

៤) ពិភាក្សាពីទស្សនវិស័យស្តីពីយុទ្ធសាស្ត្រនិងការគ្រប់គ្រងផ្នែកភ័ស្តុភាររបស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅប៉ុន្មានឆ្នាំខាងមុខនេះ ។

សំខាន់ជាងនេះទៅទៀតគឺថាសិក្ខាសាលានេះចាប់ផ្តើមពិភាក្សាពីប្រធានបទស្តីពីជំហានដំបូងនៃការបង្កើតក្រុមការងារជាផ្លូវការមួយដែលនឹងក្លាយទៅជាគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅពេលអនាគតដើម្បីជួយបន្ថែមដល់យន្តការស្វែងរកយុត្តិធម៌អន្តរកាល ។ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជឿជាក់ថាគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានឹងដំណើរការឆ្ពោះទៅរកសមិទ្ធផលលើសពីវិសាលភាពដែលដំណើរការនីតិវិធីតាមផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចបានហើយបន្តបំពេញកិច្ចការទាំងនេះដើម្បីឆ្ពោះទៅរកការផ្សះផ្សាជាតិ ។ ការស្ទាបស្ទង់មតិដែលធ្វើឡើងនៅឆ្នាំ២០០៩ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់សាកលវិទ្យាល័យកាលីហ្វ័រញ៉ានៅប៊ឺឃ្លីបានរកឃើញថាអ្នករស់រានមានជីវិតចំនួន៧៧ភាគរយនិងយុវជនជំនាន់ក្រោយចំនួន៨៥ភាគរយចង់រៀនពីរបបខ្មែរក្រហម ។

ប៉ុន្តែយោងតាមការស្រាវជ្រាវដដែលនេះឃើញថា ៖ «ស្របពេលដែលប្រជាជនកម្ពុជាទាំងអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមនិងអ្នកដែលមិនបានឆ្លងកាត់របបខ្មែរក្រហមចង់ដឹងពីការពិតចំពោះអ្វីដែលបានកើតឡើងកាលពីរបបខ្មែរក្រហមនោះ មានប្រជាជនតិចជាង៥០ភាគរយមានបំណងចូលរួមនៅក្នុងវេទិកាពិភាក្សាសាធារណៈនិងនិយាយពីបទពិសោធន៍របស់ខ្លួន» ។ ដូច្នេះដំណើរការរបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានឹងអាចជួយបំពេញចន្លោះខ្វះខាតនិងជួយសម្របសម្រួលបន្ថែមដល់ដំណើរការស្វែងរកយុត្តិធម៌នៅក្នុងរបបខ្មែរក្រហមដោយធ្វើការជាមួយនឹងប្រជាជនកម្ពុជារាប់លាននាក់ដែលមានការស្ទាក់ស្ទើរក្នុងការនិយាយពីរបបខ្មែរក្រហមនៅទីសាធារណៈ ប៉ុន្តែជាអ្នកដែលចង់ដឹងពីរបបខ្មែរក្រហមដែលដំណើរការនេះត្រូវបានចាត់ទុកថាជាដំណើរការស្វែងរកការពិតដែលបន្តធ្វើឡើងជាមួយមនុស្សគ្រប់ជំនាន់និងតាមគ្រប់កន្លែងនៃផ្ទៃប្រទេស ។

ខណៈពេលដែលគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាខុសពីប្រទេសក្រោយជម្លោះផ្សេងទៀតដែលផ្តោតលើសាសនាគ្រិស្តសម្រាប់អត់ឱនទោសនោះ លោក ឆាំង យុ នាយកមជ្ឈមណ្ឌល


លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ឯកសារកម្ពុជាបានលើកបង្ហាញដ្យាក្រាមត្រីកោណមួយដែលមានប្រធានបទថា «ទស្សនវិស័យ ៖ ទឹកដីនៃការផ្សះផ្សា» ដែលមានលក្ខណៈជាការឆ្លុះបញ្ចាំងពីទស្សនៈដែលមានលក្ខណៈជាខ្មែរសម្រាប់ការផ្សះផ្សានិងព្យាបាលរបួសផ្លូវចិត្ត ។ «ទឹកដីនៃការផ្សះផ្សា» ផ្តល់អនុភាពឲ្យការអប់រំនិងគ្រូបង្រៀន ពីព្រោះការអប់រំនិងគ្រូបង្រៀនទទួលបានការគោរពខ្ពស់ពីសហគមន៍កម្ពុជាដោយគ្មានការរើសអើងផ្នែកជាតិពន្ធុ និងសាសនាឡើយ ។

ទស្សនវិស័យរបស់លោក ឆាំង យុ បានដាក់ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វគ្គបណ្តុះបណ្តាលគ្រូបង្រៀនការគ្រប់គ្រងគុណភាពបង្រៀននៅកំពូលកណ្តាលនៃត្រីកោណ ។ សិក្ខាសាលាប្រចាំឆ្នាំ ការស្រាវជ្រាវដែលធ្វើនៅតាមភូមិ ផ្ទាំងរូបភាព សារព័ត៌មាន ការចែកចាយសៀវភៅនិងការដាក់តាំងពាក្យស្លោកលើផ្ទាំងថ្មស្ថិតនៅតាមជ្រុងផ្សេងៗនៃត្រីកោណ ។

មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រសួងអប់រំនិងអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិមានជំនឿថា ការអប់រំពីប្រវត្តិសាស្ត្រកម្ពុជា ចំណេះដឹងពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហមអាចជួយសង្គមកម្ពុជាដើរឆ្ពោះទៅរកការផ្សះផ្សាជាតិនិងការផ្សះផ្សារបួសជាលក្ខណៈបុគ្គល ។ ជាក់ស្តែងគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានកំពុងតែធ្វើកិច្ចការទាំងអស់នេះរួចទៅហើយ ។ វគ្គបណ្តុះបណ្តាលគ្រូបង្រៀន វេទិកាពិភាក្សាអប់រំជាសាធារណៈ ការដាក់តាំងពាក្យស្លោកលើផ្ទាំងថ្មដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ការចែកចាយសៀវភៅនិងចុះតាមមូលដ្ឋានបានបង្កើតសាក្សីមួយចំពោះអ្នករស់រានមានជីវិតក្នុងការរៀបរាប់និងចែករំលែកបទពិសោធន៍កាលពីរបបកម្ពុជាប្រជាធិបតេយ្យ បើទោះបីជាអ្នកទាំងនោះមិនបានតាំងចិត្តមុនក៏ដោយ ។ ការនិយាយចែករំលែកឡើងវិញនូវបទពិសោធន៍ដែលមិនបានត្រៀមទុកជាមុននៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្រៀនទាំងបីលើកនេះឆ្លុះបញ្ចាំងឲ្យឃើញពីឥទ្ធិពលនៃវគ្គបណ្តុះបណ្តាលដែលបានដើរតួជាវេទិកាសម្រាប់ការផ្សះផ្សាជាលក្ខណៈបុគ្គលនិងលក្ខណៈរួម ។ បន្ថែមពីលើនេះ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងកម្មវិធីបង្រៀនបានធ្វើឲ្យអ្នករស់រានមានជីវិតនិយាយរៀបរាប់ពីបទពិសោធន៍ផ្ទាល់ខ្លួន ៖ បើទោះបីជាគ្រូបង្រៀនជាច្រើនរូបមកចូលរួមវគ្គសិក្ខាសាលានេះមានចំណេះដឹងតិចតួចពីរបបកម្ពុជាប្រជាធិបតេយ្យក្រៅពីបទពិសោធន៍ផ្ទាល់ខ្លួននោះក៏ដោយ ក៏កម្មវិធីបង្រៀនប្រវត្តិសាស្ត្រនេះផ្តល់ឲ្យអ្នករស់រានមានជីវិតនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ដើម្បីឲ្យអ្នកទាំងអស់នេះអាចធ្វើការរៀបរាប់ពីអតីតកាលរបស់ខ្លួនក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រទ្រង់ទ្រាយធំ ។ គ្រូបង្រៀនទាំងអស់សុទ្ធតែ




ទស្សនៈវិស័យទឹកដីនៃការផ្សះផ្សា ឆ្លុះបញ្ចាំងដោយលោក ឆាំង យុ

មានចំណាប់អារម្មណ៍និងចង់សិក្សាពីប្រវត្តិសាស្ត្រនេះ ហើយគ្រូបង្រៀនទាំងអស់មិនស្ទាក់ស្ទើរនឹងសួរសំណួរទៅកាន់វាគ្មិននិងសមាជិកក្រុមការងារវគ្គបណ្តុះបណ្តាលទេ ដើម្បីបញ្ជាក់និងពង្រីងវិសាលភាពនៃប្រធានបទនៅក្នុងអំឡុងវគ្គរបស់សិក្ខាសាលានេះ ។ ចុងក្រោយបង្អស់ គម្រោងនេះក៏បានអនុញ្ញាតឲ្យគ្រូបង្រៀនធ្វើការចែករំលែកបទពិសោធន៍នៅក្នុងបរិស្ថានដែលមានសុវត្ថិភាព ពីព្រោះគ្រូបង្រៀនទាំងអស់ពិតជាបានធ្វើការស្ម័គ្រចិត្តនិយាយពីបទពិសោធន៍និងអតីតកាលរបស់ខ្លួននៅក្នុងវេទិកាពិភាក្សានេះមែន ។

សមិទ្ធផលទាំងអស់របស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានដើរទន្ទឹមគ្នានឹងគោលដៅរបស់គណៈកម្មការស្វែងរកការពិត និងផ្សះផ្សា ជាពិសេសគឺនៅក្នុងការ «ទទួលស្គាល់ឧក្រិដ្ឋកម្មដែលជួយឲ្យជនរងគ្រោះទទួលបានសិទ្ធិបញ្ចេញមតិនិងផ្តល់ជារឿងរ៉ាវប្រវត្តិសាស្ត្រមួយស្តីពីកត្តាផ្សេងៗដែលនាំមកនូវអំពើសាហាវព្រៃផ្សៃ» ។ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជានេះស្ថិតនៅក្នុងពេលដ៏ពិសេសមួយដើម្បីបន្តនិងពង្រីកកិច្ចខិតខំប្រឹងប្រែងដើម្បីការផ្សះផ្សា ប៉ុន្តែគម្រោងនេះនឹងប្រើប្រាស់មធ្យោបាយដែលមានលក្ខណៈផ្លូវការជាងនេះ នៅពេលដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានបញ្ចប់កិច្ចការរបស់ខ្លួន ។


លោកជំទាវ ទន់ សាអ៊ីម និង លោក ឆាំង យុ នៅក្នុងកម្មវិធីប្រជុំឆ្នាំនៅព្រះវិហារ

គោលដៅមួយទៀតរបស់គម្រោង «ទឹកដីនៃការផ្សះផ្សា» គឺនឹងប្រើប្រាស់គ្រូបង្រៀនសម្រាប់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាដែលកំពុងតែស្នើសុំឲ្យបង្កើតឡើង ។ គណៈកម្មការនេះមិនត្រឹមតែមានលក្ខណៈច្នៃប្រឌិតប៉ុណ្ណោះទេ ថែមទាំងមានលក្ខណៈសមស្របទៅតាមបរិបទវប្បធម៌របស់ខ្មែរថែមទៀតពីព្រោះគ្រូបង្រៀនទទួលបានការគោរពខ្ពស់នៅក្នុងសង្គមកម្ពុជា ។ នៅក្នុងវគ្គសិក្ខាសាលានេះ ទាំងលោកជំទាវ ទន់ សាអ៊ីម និង លោក ឆាំង យុ បាននិយាយពីតួនាទីសំខាន់របស់គ្រូបង្រៀនកម្ពុជាដែលអាចដើរតួនាទីនៅក្នុងការប្រមូល ថែរក្សានិងសរសេរប្រវត្តិសាស្ត្ររបស់ខ្លួន ។ ជាក់ស្តែង គ្រូបង្រៀនទាំងអស់បានបង្ហាញឲ្យឃើញពីសមត្ថភាពរបស់ខ្លួននៅក្នុងការសម្រេចកិច្ចការទាំងអស់នេះរួចហើយ ៈ មុននឹងចូលរួមសិក្ខាសាលានេះ គ្រូបង្រៀនទាំងអស់មានកាតព្វកិច្ចសរសេរអត្ថបទពី១០ទៅ២០ទំព័រស្តីពីប្រធានបទផ្សេងៗទាក់ទងនឹងភូមិស្រុកដែលគ្រូបង្រៀនទាំងអស់កំពុងតែបង្រៀន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានអត្ថបទជាង២០០ ។ អត្ថបទសរសេរទាំងអស់នេះរៀបរាប់ពីការប្រឈមមុខនឹងអំពើសាហាវព្រៃផ្សៃ ការរួចរស់រានមានជីវិតនិងភាពអត់ឃ្លានក្នុងអំឡុងនិងក្រោយរបបខ្មែរក្រហម ។ អត្ថបទទាំងអស់នេះមិនមែនផ្តោតតែទៅលើរឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមប៉ុណ្ណោះទេ ៈ គ្រូបង្រៀនខ្លះបានសរសេរពីប្រវត្តិភូមិស្រុករបស់ខ្លួនដែលធ្វើការឆ្លុះបញ្ចាំងពីការចាប់ផ្តើមស្តាបនាកសាងភូមិស្រុករបស់ខ្លួនក្រោយពីរបបខ្មែរក្រហមនិងជីវភាពរស់នៅមុនការកើតឡើងនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ គុណភាពនិងចំនួនរបស់អត្ថបទទាំងអស់នេះបង្ហាញឲ្យឃើញនូវប្រសិទ្ធភាពនិងឆន្ទៈនៅក្នុងការធ្វើការស្រាវជ្រាវ ធ្វើបទសម្ភាសន៍និងចងក្រងប្រវត្តិសាស្ត្រនៅតាមភូមិរបស់គ្រូបង្រៀនដែលការធ្វើដូច្នេះបានជួយឲ្យអ្នករស់រានមានជីវិតអាចធ្វើការ «ចងក្រង» ពីប្រវត្តិផ្ទាល់ខ្លួនទៅជាប្រវត្តិភូមិស្រុករបស់ខ្លួនឯងបាន ។ អត្ថបទជាង២០០០ទំព័រដែលគ្រូបង្រៀនបានសរសេរសម្រាប់គម្រោងដែលមានឈ្មោះថា «ប្រវត្តិសាស្ត្រភូមិយើង» ក៏ឆ្លុះបញ្ចាំងពីតួនាទីដ៏សកម្មរបស់គ្រូបង្រៀនក្នុងការដើរឆ្ពោះទៅរកការផ្សះផ្សាសម្រាប់សង្គមជាតិកម្ពុជា ។ នៅពេលដែលគ្រូបង្រៀនចុះធ្វើការសម្ភាសន៍នៅតាមភូមិដើម្បីនិយាយជាមួយនឹងអ្នករស់រានមានជីវិត គ្រូបង្រៀនទាំងអស់នេះនឹងដើរតួជាអ្នកស្តាប់និងជាអ្នកទទួលស្គាល់

ពីការឈឺចាប់របស់អ្នករស់រានមានជីវិត ។ ការធ្វើបែបនេះឆ្លុះបញ្ចាំងឲ្យឃើញពីទិដ្ឋភាពដ៏សំខាន់បំផុតនៅក្នុងប្រទេសក្រោយជម្លោះទាំងឡាយក្នុងការទទួលដឹងឮនិងទទួលស្គាល់ជាផ្លូវការនូវភាពតានតឹងពីអតីតកាលរបស់អ្នករស់រានមានជីវិតពីព្រោះការធ្វើបែបនេះអាចជួយឲ្យអ្នកទាំងអស់នេះដឹងថាខ្លួនមិនមែនទទួលរងទុក្ខលំបាកវេទនាតែម្នាក់ឯងនោះទេ ។ កញ្ញា សូ ហ្វារីណា ដែលជាអ្នកជំនាញមានបទពិសោធន៍ច្រើនជាមួយជនជាតិចាមបានលើកឡើងពីគំនិតខាងលើទាំងអស់នេះនៅក្នុងអត្ថបទឯកសារដែលស្តីបទពិសោធន៍សម្ភាសន៍បងប្អូនខ្មែរអ៊ីស្លាមដោយនិយាយថា ៖ «ខ្ញុំបានកត់សម្គាល់ឃើញថាអ្នកដែលផ្តល់បទសម្ភាសន៍ទាំងអស់ត្រូវការអ្នកស្តាប់ដែលបង្ហាញពីសេចក្តីអាណិតរបស់ខ្លួនចំពោះគាត់ដើម្បីឲ្យខ្លួនគាត់បានដឹងថាមានអ្នកទទួលដឹងឮពីការចងចាំនិងទទួលស្គាល់ការរងទុក្ខលំបាកវេទនារបស់ខ្លួន ។ ដូច្នេះតួនាទីរបស់អ្នកស្តាប់គឺពិតជាមានសារសំខាន់នៅក្នុងការធ្វើឲ្យអ្នករៀបរាប់ពីបទពិសោធន៍របស់ខ្លួនមានអារម្មណ៍ថាជនរងគ្រោះមិនមែនជាមនុស្សដែលរងទុក្ខវេទនាតែម្នាក់ឯងនោះទេ ហើយជួយឲ្យអ្នកទាំងអស់នេះដឹងថាយ៉ាងហោចណាស់មានមនុស្សម្នាក់ទទួលដឹងឮការរងទុក្ខវេទនារបស់ខ្លួនដែលជាលទ្ធភាពធ្វើឲ្យអ្នកទាំងអស់នេះរំសាយនូវភាពឈឺចាប់» ។ លើសពីនេះទៅទៀត គ្រូបង្រៀនក៏ដើរតួជាអ្នកជួយពង្រីកដំណើរការសាកសួរពីបទពិសោធន៍របស់បុគ្គលតាមរយៈការសរសេររឿងរ៉ាវប្រវត្តិសាស្ត្រដែលខ្លួនបានឮពីព្រោះការសរសេរគឺផ្តោតជាពិសេសលើ «ការពិត» ដែលមាននៅក្នុងសង្គមកម្ពុជា ។

ចុងក្រោយបង្អស់ គ្រូបង្រៀនទាំងអស់នេះធ្វើការយល់ដឹងពីសារសំខាន់និងតួនាទីនៃគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងដំណើរផ្សះផ្សារបស់ប្រទេសកម្ពុជា ។ មនុស្សជាច្រើនមានអារម្មណ៍ពេញចិត្តដែលឃើញកម្មវិធីសិក្សាប្រវត្តិសាស្ត្រនេះមាននៅតាមសាលារៀនទាំងអស់នៅទូទាំងប្រទេសកម្ពុជា បើទោះបីជាអ្នកទាំងនេះមិនមានភាពធូរស្បើយក៏ដោយ ។ យោងតាមសម្តីរបស់អ្នកគ្រូ មុំ ម៉េត ជាគ្រូថ្នាក់ជាតិបាននិយាយនៅក្នុងទស្សនាវដ្តីស្វែងរកពិតឆ្នាំ២០០៩ ថា ៖ «ខ្ញុំបានប្រែក្លាយកំហឹងនិងការឈឺចាប់របស់ខ្ញុំពីការបាត់បង់ស្វាមីនិងប្អូនស្រីមកជាចំណុចខ្លាំងនិងស្មារតីអំណត់ដើម្បីបំពេញការងារនិងចិញ្ចឹមកូនទាំងប្រាំនាក់របស់ខ្ញុំរហូតដល់កូនៗក្លាយជាមនុស្សចេះដឹង ។ ខ្ញុំបង្រៀនក្មេងៗជំនាន់ក្រោយឲ្យយល់ពីប្រវត្តិសាស្ត្រខ្មែរក្រហមមិនមែនឲ្យក្មេងៗទាំងនេះចងគំនុំទេ តែដើម្បីជួយឲ្យក្មេងៗចេះសាមគ្គីគ្នា» ។ ជាមួយគ្នានេះដែរ គ្រូបង្រៀនថ្នាក់ខេត្តក៏មានទស្សនៈស្រដៀងគ្នានេះដែរ ហើយបាននិយាយថា «យើងត្រូវតែយល់ថាគម្រោងនេះគឺធ្វើឡើងដើម្បីការផ្សះផ្សានិងអធ្យាស្រ័យគ្នាទៅវិញទៅមក» ។ ទស្សនៈទាំងអស់នេះត្រូវបានលើកឡើងនៅក្នុងសិក្ខាសាលាខេត្តព្រះវិហារដោយគ្រូបង្រៀនទាំងអស់ស្របពេលដែលលោកគ្រូអ្នកគ្រូបានបន្តបង្ហាញពីការយល់ឃើញថា គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺជាមធ្យោបាយមួយដែលនាំឆ្ពោះទៅរកការផ្សះផ្សានិងការយល់ដឹងពីសារសំខាន់របស់ខ្លួនក្នុងនាមជាគ្រូបង្រៀននិងជាអ្នកដឹកនាំនៅតាមសហគមន៍ដើម្បីចូលរួមបង្កើត


អ្នកគ្រូ បែន នាង នៅក្នុងកម្មវិធីប្រជុំប្រចាំឆ្នាំនៅព្រះវិហារ


អ្នកគ្រូ ឈូក ស្រីមន្តា នៅក្នុងកម្មវិធីប្រជុំប្រចាំឆ្នាំនៅព្រះវិហារ

ដំណើរការផ្សះផ្សានេះ ។

**ព័ត៌មានសង្ខេបរបស់សិក្ខាសាលា**

សិក្ខាសាលានៅខេត្តព្រះវិហារគឺជាផ្នែកមួយរបស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយក្រសួងអប់រំយុវជន និង កីឡាដែលជាកិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិមួយដើម្បីអនុវត្តកម្មវិធីសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមថ្នាក់វិទ្យាល័យនិងសកលវិទ្យាល័យទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជាឲ្យបានសម្រេចត្រឹមដំណាច់ឆ្នាំ២០១៣ ។ គ្រូបង្រៀនដែលចូលរួមនៅក្នុងសិក្ខាសាលានៅខេត្តព្រះវិហារទទួលបាននូវវគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងវិធីសាស្ត្របង្រៀន



លោក ដួរ តារី និង លោក ស៊ុំ ធន ពិភាក្សាគ្នានៅក្នុងកម្មវិធីប្រជុំប្រចាំនៅព្រះវិហារ

កាលពីខែកក្កដានិងខែវិច្ឆិកា ឆ្នាំ២០០៩ក្នុងរយៈពេលប្រាំពីរថ្ងៃហើយទទួលបាននូវលិខិតបញ្ជាក់ពីក្រសួងអប់រំឲ្យបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងផ្តល់វគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀននៅតាមថ្នាក់មូលដ្ឋានផ្សេងៗទៀតដែលត្រូវបានធ្វើឡើងទូទាំងប្រទេសកម្ពុជាកាលពីឆ្នាំ២០១០ ។ រហូតមកដល់សព្វថ្ងៃនេះគ្រូបង្រៀនជាង១០០០នាក់ទទួលបាននូវវគ្គបណ្តុះបណ្តាលនិងលិខិតបញ្ជាក់ឲ្យធ្វើការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមសាលារៀនទូទាំងប្រទេសកម្ពុជា ។ ចាប់តាំងពីការបង្កើតគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាលពីខែកញ្ញា ឆ្នាំ២០០៨មក កិច្ចការដែលរៀបរាប់នៅខាងក្រោមនេះត្រូវបានសម្រេចបានជាស្ថាពរហើយ ។

**ការបោះពុម្ពនិងចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)** ៖ សៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានបោះពុម្ពជាលើកដំបូងនៅឆ្នាំ២០០៧ ។ ចាប់តាំងពីពេលនោះមកសៀវភៅ ជាង៣០០.០០០ក្បាលត្រូវបានចែកចាយទៅកាន់វិទ្យាល័យជាង១,៧០០នៅទូទាំងប្រទេសកម្ពុជា ។ សៀវភៅប្រវត្តិសាស្ត្រនេះត្រូវបានយល់ព្រមឲ្យបោះពុម្ពដោយក្រសួងអប់រំដើម្បីយកមកប្រើប្រាស់ជាសម្ភារបង្រៀននិងជាឯកសារយោងសំខាន់សម្រាប់កម្មវិធីបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនៅតាមវិទ្យាល័យ ។

**ការប្រែសម្រួលសៀវភៅប្រវត្តិសាស្ត្រនេះជាប្រាំភាសា** ៖ ក្រៅពីភាសាអង់គ្លេសនិងភាសាខ្មែរ សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ក៏នឹងត្រូវបានបកប្រែជាភាសាបារាំង ចិន វៀតណាម ថៃ និង ជប៉ុន ។

**ការវិវឌ្ឍទៅមុខនិងការបោះពុម្ពសម្ភារៈបង្រៀន (សៀវភៅណែនាំគ្រូបង្រៀននិងសៀវភៅលំហាត់សម្រាប់សិស្ស)** ៖ សៀវភៅណែនាំគ្រូបង្រៀនជាភាសាខ្មែរចំនួន៣០០០ក្បាលនិងជាភាសាអង់គ្លេសចំនួន១០០០ក្បាលត្រូវបានបោះពុម្ពឡើងដើម្បីវគ្គបណ្តុះបណ្តាលនៅតាមខេត្តកាលពីចុងឆ្នាំ២០០៩ ។ ដោយសារតែកង្វះខាតផ្នែកថវិកា សៀវភៅលំហាត់សម្រាប់សិស្សគ្រាន់តែថតចម្លងតែប៉ុណ្ណោះ ។

**វគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ជាតិ** ៖ គ្រូបង្រៀនថ្នាក់ជាតិចំនួន២៤រូបនិងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន១៥រូបទទួលបានការបណ្តុះបណ្តាលនៅក្នុងសិក្ខាសាលាដែលត្រូវបានរៀបចំធ្វើឡើងចាប់ពីថ្ងៃទី២៩ ខែមិថុនា រហូតដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ។ សិក្ខាកាមទាំងអស់ទទួលបានការបណ្តុះបណ្តាលពីអ្នកជំនាញជាតិនិងអន្តរជាតិផ្នែកប្រវត្តិសាស្ត្រ ផ្នែករៀបរៀងកម្មវិធីសិក្សា ផ្នែកអប់រំស្តីពីអំពើប្រល័យពូជសាសន៍និងផ្នែកច្បាប់ ។ សិក្ខាកាមទាំងអស់ទទួលបានការបណ្តុះបណ្តាលស្តីពីព័ត៌មានដែលមាននៅសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងការប្រើប្រាស់សៀវភៅណែនាំគ្រូបង្រៀននិងសៀវភៅលំហាត់សម្រាប់សិស្ស ។

**វគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ខេត្ត** ៖ ចាប់ពីថ្ងៃទី២៣ ខែវិច្ឆិកា រហូតដល់ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៩ គ្រូបង្រៀនថ្នាក់ខេត្តចំនួន១៦៨ នាក់បានទទួលវគ្គបណ្តុះបណ្តាលពីអ្នកជំនាញជាតិនិងអន្តរជាតិស្តីពីការប្រើប្រាស់សៀវភៅប្រវត្តិសាស្ត្រ សៀវភៅណែនាំគ្រូបង្រៀន និងសៀវភៅលំហាត់សម្រាប់សិស្ស ។ សិក្ខាសាលាស្តីពីវគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅតាមខេត្តចំនួនប្រាំមួយខុសៗគ្នាដូចជា ៖ កណ្តាល តាកែវ ព្រៃវែង កំពង់ចាម និងបាត់ដំបង រួមទាំងនៅទីក្រុងភ្នំពេញ ។

**វគ្គបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន** ៖ ចាប់ពីខែមេសារហូតដល់ខែមិថុនា ឆ្នាំ២០១០ សិក្ខាសាលាស្តីពីវគ្គបណ្តុះបណ្តាលគ្រូបង្រៀនចំនួនបីត្រូវរៀបចំឡើងក្នុងនោះមានពីរឬបីដងក្នុងមួយលើកៗ ។ វគ្គបណ្តុះបណ្តាលនេះមានលក្ខណៈស្រដៀងគ្នានឹងវគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់ជាតិនិងថ្នាក់ខេត្តដែរដោយគ្រូបង្រៀនថ្នាក់ជាតិនិងថ្នាក់ខេត្តមួយចំនួនបានចូលរួមនិងដើរតួជាអ្នកផ្តល់ការបណ្តុះបណ្តាលអមជាមួយនឹងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ គ្រូបង្រៀនជាង១០០០នាក់ដែលមកពីគ្រប់ខេត្តទាំងអស់ទូទាំងប្រទេសកម្ពុជាបានទទួលវគ្គបណ្តុះបណ្តាលអំពីវិធីសាស្ត្របង្រៀន និងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។

**ពាក្យស្លោកនិងបូជនីយដ្ឋានដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍** ៖

នៅខែមិថុនា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលការអនុញ្ញាតពីក្រសួងអប់រំឲ្យដាក់តាំងពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅតាមវិទ្យាល័យចំនួន១,៧០០ ទូទាំងប្រទេស ។ ការដាក់តាំងទាំងអស់នេះអាចធ្វើជាផ្ទាំងបដា ផ្ទាំងលោហៈធាតុ ផ្ទាំងគំនូរតាមជញ្ជាំងសាលា ឬក្នុងបែបបទផ្សេងៗទៀតដែលបង្ហាញពីអត្ថន័យនៃពាក្យស្លោកដែលធ្វើការចងចាំពីសោកនាដកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យនិងលើកកម្ពស់ការផ្សះផ្សាក្រោយអំពើប្រល័យពូជសាសន៍បានបញ្ចប់ទៅ ។

ពាក្យស្លោកទាំងពីរនេះមានអត្ថន័យដូចតទៅ ៖

១) «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហមគឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱនអធ្យាស្រ័យគ្នា» និង ២) «រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យគឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» ។ ការដាក់តាំងពាក្យស្លោកលើផ្ទាំងថ្មមួយមានតម្លៃប្រមាណជា៤០០ដុល្លារ ។ ពាក្យស្លោកទាំងអស់នេះនឹងជួយធ្វើការចងចាំអតីតកាលនៃរបបខ្មែរក្រហមស្របពេលដែលមានការជំរុញឲ្យមានការចាប់អារម្មណ៍ពីដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមជាលក្ខណៈប្រវត្តិសាស្ត្រដែលនឹងដំណើរការនាពេលឆាប់ៗខាងមុខនេះ ។ អ្នករស់រានមានជីវិតនិងក្មេងៗជំនាន់ក្រោយនឹងបានយល់ដឹងពីរបបកម្ពុជាប្រជាធិបតេយ្យ បង្កើតចំណាប់អារម្មណ៍ពីតុលាការកាត់ទោសខ្មែរក្រហមនិងធ្វើការទទួលស្គាល់បទពិសោធន៍និងភាពតានតឹងរបស់អ្នករស់រានមានជីវិត ។

**ការត្រួតពិនិត្យលើវគ្គបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់គ្រូថ្នាក់ជាតិ** ៖

នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០១០ បណ្ឌិត ជា ផល្លា ដែលជាសហនិពន្ធសៀវភៅណែនាំគ្រូបង្រៀនបានផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមស្តីពីវិធីសាស្ត្រដែលមានចែងនៅក្នុងសៀវភៅណែនាំគ្រូដល់គ្រូបង្រៀនថ្នាក់ជាតិចំនួន១៥រូប រួមទាំងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានិងមន្ត្រីរបស់ក្រសួងអប់រំ ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលបន្ថែមនេះគឺធ្វើឡើងដើម្បីពង្រឹងសមត្ថភាពរបស់គ្រូបង្រៀនថ្នាក់ជាតិដែលជាអ្នកដឹកនាំវគ្គបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់មូលដ្ឋាន ។ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងជាការផ្តល់បទបង្ហាញស្តីពីប្រធានបទចំនួន២៥ខុសៗគ្នានិងពីវិធីសាស្ត្របង្រៀនដើម្បីជួយឲ្យគ្រូបង្រៀនថ្នាក់ជាតិទទួលបាននូវចំណេះ


លោកគ្រូ អឿន សុទ្ធី ឆ្លើយសំណួរទាក់ទងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ដឹងកាន់តែប្រសើរដើម្បីប្រើប្រាស់និងបណ្តុះបណ្តាលគ្រូបង្រៀនផ្សេងទៀតឲ្យបានយល់ដឹងពីវិធីសាស្ត្រនីមួយៗឲ្យកាន់តែច្បាស់និងមានប្រសិទ្ធភាពជាងមុន ។

## វេទិកាអប់រំជាសាធារណៈរវាងគ្រូបង្រៀនសិស្សានុសិស្ស និងឪពុកម្តាយ

នៅឆ្នាំ២០១០គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមដំណើរការគម្រោងថ្មីមួយដើម្បីផ្តល់ជាចំណេះដឹងក្រៅផ្លូវការដល់សហគមន៍ផ្សេងៗនៅតាមទីជនបទដែលភូមិទាំងជនរងគ្រោះ និងជនដៃដល់ និយាយសន្ទនាគ្នានិងសហការគ្នាជាមួយនឹងគ្រូបង្រៀន ដើម្បីអប់រំក្មេងជំនាន់ក្រោយពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ លទ្ធផលដែលទទួលបានពីវេទិកាពិភាក្សានេះគឺថាអ្នកភូមិទទួលបានការយល់ដឹងពីរបបខ្មែរក្រហមកាន់តែទូលំទូលាយស្របពេលដែលក្មេងៗជំនាន់ក្រោយបានរៀនសូត្រពីសៀវភៅប្រវត្តិសាស្ត្រនិងរឿងរ៉ាវដែលកើតមាននៅក្នុងសហគមន៍របស់ខ្លួន ។ សំខាន់ជាងនេះទៅទៀតគឺថា មនុស្សជំនាន់ខុសៗគ្នាទទួលបានឱកាសចែករំលែកបទពិសោធន៍ជាមួយគ្នា


លោកគ្រូ សឿ ហាច នៅក្នុងសិក្ខាសាលាប្រចាំឆ្នាំ

ពុំសូវ ទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងអត្ថបទបោះពុម្ពផ្សាយផ្សេងៗទៀតដែលទាក់ទងនឹងប្រវត្តិរបបខ្មែរក្រហម ។ នៅឆ្នាំ២០១០វេទិកាពិភាក្សាចំនួនប្រាំត្រូវបានធ្វើឡើងនៅខេត្តកំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង តាកែវ និងក្រចេះដែលមានអ្នកចូលរួមចាប់ពី៥០ទៅ២៥០នាក់ក្នុងកិច្ចពិភាក្សានីមួយៗ ។ គ្រូថ្នាក់ខេត្តមិនមែនត្រឹមតែបានជួយរៀបចំវេទិកាពិភាក្សានេះប៉ុណ្ណោះទេ ថែមទាំងបានដឹកនាំការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមនេះទៀតផង ។

វេទិកាពិភាក្សាជាសាធារណៈនេះបានផ្តល់ឱកាសឲ្យអ្នកទៅវិញទៅមក ។ ការសន្ទនារវាងមនុស្សពីមួយជំនាន់ទៅមួយជំនាន់មិនត្រឹមតែជំរុញឲ្យក្មេងៗរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមតែប៉ុណ្ណោះទេ ថែមទាំងជំរុញឲ្យមានការនិយាយសន្ទនាគ្នានៅតាមផ្ទះដែលជាការកែប្រែការបដិសេធនិងការមិនជឿរបស់ក្មេងៗជំនាន់ក្រោយពីភាពតានតឹងរបស់ឪពុកម្តាយ ។

**សំណួរប្រឡងទូទាំងប្រទេសស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ៖** ជាការឆ្លើយតបបន្ថែមនឹងកម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបានបញ្ចូលសំណួរចំនួនប្រាំដែលទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមក្នុងរយៈពេលពីរឆ្នាំចុង

ក្រោយនេះ ។ ទាំងអស់នេះបានសង្កត់ធ្ងន់ពីសារសំខាន់នៃគម្រោងអប់រំប្រវត្តិសាស្ត្រនេះជាទ្រង់ទ្រាយថ្នាក់ជាតិ ។

## ការពង្រីកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនដល់សាស្ត្រាចារ្យសកលវិទ្យាល័យនិងមន្ត្រីនគរបាល

ខែធ្នូ ឆ្នាំ២០១០ រដ្ឋាភិបាលកម្ពុជាបានប្រគល់ភារកិច្ចឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់វគ្គបណ្តុះបណ្តាលដល់សាស្ត្រាចារ្យសកលវិទ្យាល័យនិងគ្រូបង្រៀនថ្នាក់វិទ្យាល័យស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ បទបញ្ជាថ្មីនេះអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការជាមួយនឹងសកលវិទ្យាល័យចំនួន៧០ នៅប្រទេសកម្ពុជានិងនិស្សិតចំនួន២០០.០០០នាក់ ។ សេចក្តីសម្រេចនេះគឺកើតចេញពីបទបញ្ជារបស់រដ្ឋាភិបាលកម្ពុជាកាលពីខែតុលាឆ្នាំ២០០៩ ដែលតម្រូវឲ្យនិស្សិតឆ្នាំទីមួយ (ឆ្នាំមូលដ្ឋាន) រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ អ្នកផ្តល់វគ្គបណ្តុះបណ្តាលជាតិនិងអន្តរជាតិនឹងផ្តល់វគ្គបណ្តុះបណ្តាលដល់សាស្ត្រាចារ្យសាកលវិទ្យាល័យដោយប្រើប្រាស់សម្ភារសិក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបង្កើតឡើងដើម្បីសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្រៀនតាមថ្នាក់មធ្យមសិក្សា ។ សម្ភារបង្រៀនឲ្យសមតាមកម្រិតសកលវិទ្យាល័យបន្ថែមនឹងត្រូវបានផ្តល់ជូនដោយអ្នកជំនាញអន្តរជាតិរួមមានលោកសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ ដែលជាអ្នកប្រាជ្ញដ៏ល្បីល្បាញពីប្រវត្តិសាស្ត្រកម្ពុជានៅឯសកលវិទ្យាល័យម៉ូណាស (ប្រទេសអូស្ត្រាលី) និងអ្នកប្រាជ្ញដែលមានបទពិសោធន៍នៅក្នុងការបង្រៀនពីហាយនភាពនិងអំពើប្រល័យពូជសាសន៍នៅរ៉ាន់ដា ។


លោកគ្រូ-អ្នកគ្រូ នៅក្នុងកម្មវិធីប្រជុំប្រចាំឆ្នាំនៅព្រះវិហារ

ស្របពេលជាមួយគ្នានេះ ក្រសួងមហាផ្ទៃក៏បានដាក់បញ្ចូលការអប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចូលទៅក្នុងកម្មវិធីសិក្សាដល់មន្ត្រីនគរបាលដែរ ។ ក្រសួងការពារជាតិដែលមានកងកម្លាំងទាហានជាអតីតទាហានខ្មែរក្រហមក៏កំពុងតែពិចារណាបញ្ចូលកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រនេះដែរ ។

## ការគ្រប់គ្រងគុណភាព ៖

ដើម្បីធានាថាការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រេចនូវគោលដៅការផ្សះផ្សាជាតិ ការកសាងសន្តិភាពនិងការជំរុញឲ្យមានការការពារអំពើប្រល័យពូជសាសន៍ជាលក្ខណៈទូលំទូលាយនោះ កម្មវិធីត្រួតពិនិត្យគ្រប់គ្រងគុណភាពនឹងចាប់ផ្តើមធ្វើឡើងនៅឆ្នាំ២០១១ ។ នៅក្នុងបរិបទរបស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គម្រោងគ្រប់គ្រងគុណភាពនឹងធ្វើការត្រួតពិនិត្យ គ្រប់គ្រងវិវឌ្ឍនិងធានាពីគុណភាពនៃការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមថ្នាក់មធ្យមសិក្សាជាលក្ខណៈថ្នាក់ជាតិ ។ ការគ្រប់គ្រងគុណភាពត្រូវបានរៀបចំធ្វើឡើងដោយការត្រួតពិនិត្យពីមជ្ឈដ្ឋានខាងក្រៅនិងការវាយតម្លៃលើខ្លួនឯង ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំនឹងពិនិត្យតាមដានដំណើរការនៃគម្រោងនេះតាមរយៈការអនុវត្តរបស់គម្រោងគ្រប់គ្រងគុណភាពនេះ ។

## សកម្មភាពរបស់សិក្ខាសាលា

### ទឹកដីនៃការផ្សះផ្សា

លោក ឆាំង យុ បានលើកឡើងពីទស្សនវិស័យស្តីពី «ទឹកដីនៃការផ្សះផ្សា» នៅក្នុងអំឡុងវគ្គសិក្ខាសាលាដូចដែលបានរៀបរាប់ខាងលើថានឹងប្រើប្រាស់គ្រូបង្រៀន ការអប់រំ និងការសាបព្រោះចំណេះដឹងដើម្បីជួយដល់យន្តការស្វែងរកយុត្តិធម៌អន្តរកាលនិងបង្កើតជា «ទឹកដីនៃការផ្សះផ្សា» មួយ ។ មូលហេតុដែលបង្កើតឲ្យមានទស្សនវិស័យបែបនេះគឺដោយសារ ៖ ១) តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបច្ចុប្បន្ននេះធ្វើការកាត់ទោសតែមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់តែប៉ុណ្ណោះស្របពេលដែលកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមកំពុងតែរស់នៅជាមួយនឹងជនរងគ្រោះនៅតាម

ភូមិនីមួយៗរបស់ប្រទេសកម្ពុជា ។ ដូច្នេះតុលាការកាត់ទោសខ្មែរក្រហមមិនអាចជំរុញឲ្យមានការផ្សះផ្សា «សម្រាប់ប្រជាជនទូទៅ» ទេ ពីព្រោះកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមមិនត្រូវបានកាត់ទោសឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ខ្លួន ។ ២) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុវត្តវិធីសាស្ត្រ «ពីថ្នាក់លើចុះមកថ្នាក់ក្រោម» ដើម្បីចេញសាលក្រមកាត់ទោសជនជាប់ចោទនិងចងក្រងប្រវត្តិសាស្ត្រខ្មែរក្រហមដែលវិធីសាស្ត្រនេះផ្តល់ឱកាសតិចតួចដល់ជនរងគ្រោះក្នុងការចូលរួម «លាតត្រដាង» ពីបទពិសោធន៍របស់ខ្លួន ។ ៣) ក្នុងរយៈពេល១៨ខែកន្លងមកនេះ គ្រូបង្រៀនបានបន្តបង្ហាញពីសមត្ថភាពរបស់ខ្លួននៅក្នុងការអប់រំសិស្សានុសិស្សនិងសហគមន៍ធំៗរៀបចំវេទិកាពិភាក្សានិងជំរុញឲ្យមានការផ្សះផ្សាជាលក្ខណៈបុគ្គលនិងជាលក្ខណៈរួម ។

ទស្សនវិស័យដែលលោក ឆាំង យុ បានចែករំលែកដល់គ្រូបង្រៀនដែលចូលរួមទាំងអស់នេះធ្វើការឆ្លុះបញ្ចាំងឲ្យឃើញពីវិធីសាស្ត្រចេញពីការចូលរួមរបស់ប្រជាជនសាមញ្ញ ៖ នៅពេលដែលសញ្ញាព្រួញដែលចេញពីកត្តាធំៗជះឥទ្ធិពលមកលើពីរ៉ាមីតរាងត្រីកោណនៃទស្សនវិស័យនេះ នោះផ្នែកកណ្តាលនៃត្រីកោណនឹងធ្វើចលនានៅក្នុងផ្ទៃរាបខាងក្នុងនៃត្រីកោណដើម្បីផ្តល់ឥទ្ធិពល ឬបង្កើតជាទឹកដីនៃការផ្សះផ្សា ។ ប៉ុន្តែការកើតឡើងដូច្នេះគឺចេញមកពីកម្លាំងនៃកត្តាតូចៗ «តាមថ្នាក់មូលដ្ឋាន» ដែលជួយតម្រង់ទិសឲ្យសញ្ញាព្រួញទាំងអស់នេះដើរតួជាកត្តាប្រៀបធៀបសម្រាប់ជនរងគ្រោះនិងក្មេងៗជំនាន់ក្រោយដែលអ្នកទាំងអស់នេះនឹងទទួលបន្ទុកក្នុងការចងក្រងប្រវត្តិសាស្ត្ររបស់ខ្លួន ។

## «ប្រវត្តិសាស្ត្រភូមិយើង»

ជាផ្នែកមួយនៃទស្សនវិស័យ «ទឹកដីនៃការផ្សះផ្សា» គ្រូបង្រៀនដែលមានតួនាទីជាអ្នកប្រតិបត្តិការនឹងតម្រូវឲ្យប្រគល់អត្ថបទចំនួនបីក្នុងរយៈពេលមួយឆ្នាំដើម្បីយកមកបោះពុម្ពជាឯកសារចងក្រង ហើយយកទៅចែកចាយទូទាំងប្រទេសកម្ពុជា ។

ជាសរុបមក អត្ថបទទាំងអស់នេះអាចនឹងផ្តល់ចម្លើយថាហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍កើតឡើង លើកឡើងពីវិធីដលអាចជំរុញឲ្យមានការទទួលស្គាល់ពីជនដែលឆ្លុះបញ្ចាំងពីការតស៊ូរបស់សហគមន៍កម្ពុជាក្នុងការតស៊ូដើម្បីរស់ និងកសាង


លោកគ្រូនិងលោកគ្រូកំពុងយកចិត្តទុកដាក់ស្តាប់អង្គប្រជុំនៅព្រះវិហារ


គ្រូបង្រៀនតាមក្រុមនីមួយៗពិភាក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

ជីវភាពរស់នៅសាជាថ្មីម្តងទៀតនិងបង្ហាញពីស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ននេះ ។ បន្ថែមពីលើនេះ ឯកសារចងក្រងនេះនឹងត្រូវយកមកប្រើប្រាស់នៅតាមសាលារៀនទូទាំងប្រទេសដើម្បីធ្វើជាសម្ភារសិក្សាបន្ថែមដែលនេះជាការឆ្លើយតបនឹងការត្អូញត្អែររបស់គ្រូបង្រៀនចំពោះសៀវភៅប្រវត្តិសាស្ត្រនេះដើម្បីជំរុញឲ្យវាមានលក្ខណៈ «ពិតប្រាកដមិនលម្អៀង» ដោយផ្អែកលើប្រវត្តិសាស្ត្រ ។ យោងតាមទស្សនវិស័យ «ទឹកដីនៃការផ្សះផ្សា» ដែលបានស្នើដោយគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអាចបោះពុម្ពរឿងរ៉ាវរបស់អ្នករស់រានមានជីវិតចំនួន៥៤០សាច់រឿងជារៀងរាល់ឆ្នាំ ។ លើសពីនេះទៅទៀត គ្រូបង្រៀនទាំងអស់នឹងមានការទទួលខុសត្រូវចំពោះការជំរុញលើកទឹកចិត្តឲ្យសិស្សានុសិស្សធ្វើការចង

ក្រងបទពិសោធន៍ពីរបបខ្មែរក្រហមរបស់សមាជិកគ្រួសារនិងអ្នកជិតខាងរបស់សិស្សានុសិស្សទាំងនោះ ។ ដើម្បីវិនិច្ឆ័យពីប្រសិទ្ធភាពនៃទស្សនៈដែលស្នើសុំឡើងខាងលើនេះ គ្រូបង្រៀនដែលចូលរួមទាំងអស់ធ្លាប់បានតម្រូវឲ្យប្រគល់អត្ថបទពី១០ទៅ២០ទំព័រដែលសរសេរឡើងទាក់ទងនឹងប្រធានបទស្ដីពីប្រវត្តិភូមិដែលលោកគ្រូអ្នកគ្រូទាំងអស់នេះកំពុងតែបង្រៀនមុនពេលចូលរួមសិក្ខាសាលានេះ ។ ដូចដែលបានកត់សម្គាល់ខាងលើ អត្ថបទចំនួនប្រមាណ២០០អត្ថបទត្រូវបានប្រមូល ។ អត្ថបទទាំងអស់នេះមិនត្រឹមតែឆ្លុះបញ្ចាំងពីរួមក្នុងដំណើរការចងក្រងនិងធានាថារឿងរ៉ាវប្រវត្តិសាស្ត្រនេះនឹងមិនបាត់បង់ ហើយត្រូវបានផ្សព្វផ្សាយដល់មនុស្សទូទៅ ។ ការពិភាក្សាពីតួនាទីរបស់គ្រូបង្រៀនត្រូវបានបន្តលើកឡើងបន្ថែមទៀតនៅក្នុងមតិឆ្លើយតបដែលទទួលបានពីលោកគ្រូអ្នកគ្រូដែលបានចូលរួមរៀបចំវគ្គវិធីសាស្ត្រ «ពីថ្នាក់ក្រោមទៅថ្នាក់លើ» ដើម្បីចងក្រងនិងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់មនុស្សជំនាន់នេះនិងជំនាន់ក្រោយ ។

គោលដៅសំខាន់មួយរបស់គម្រោងនេះគឺធ្វើឡើងដើម្បីចង


លោក គ្រីស្ទូហ្វឺ ឌៀរីង ជាមួយលោក វ៉ាន់ថាន់ ពៅដារ៉ា និយាយទៅកាន់លោកគ្រូ-អ្នកគ្រូនៅក្នុងការប្រជុំប្រចាំឆ្នាំនៅព្រះវិហារ

សមត្ថភាពរបស់គ្រូបង្រៀននៅក្នុងការស្រាវជ្រាវធ្វើបទសម្ភាសន៍និងចងក្រងប្រវត្តិអតីតកាលរបស់ខ្លួនប៉ុណ្ណោះទេ រឿងរ៉ាវដែលបានប្រមូលផ្ដុំទាំងអស់នេះក៏បង្ហាញពីការចង់ដឹងរបស់គ្រូបង្រៀនពីគម្រោងមួយនេះដែរ ។ នៅក្នុងអំឡុងវគ្គសិក្ខាសាលានេះ លោកគ្រូថ្នាក់ជាតិ ស៊ីវ ធួន បាននិយាយពីវិធីសាស្ត្រដែលគ្រូបង្រៀនអាចដោះស្រាយកត្តាប្រឈមមុខផ្សេងៗដែលកើតមាននៅក្នុងដំណើរការស្រាវជ្រាវរបស់គ្រូបង្រៀនស្របពេលដែលលោកជំទាវ ទន់ សាអ៊ីម បានមានប្រសាសន៍ពិភាក្សាពីតួនាទីរបស់គ្រូដែលអាចចូលក្រងរឿងរ៉ាវដែលមិនធ្លាប់បានដឹងពីមុនមកនិងដើម្បីផ្ដល់ឱកាសឲ្យអ្នករស់រានមានជីវិតនិយាយពីរឿងរ៉ាវរបស់ខ្លួននិង «បញ្ចេញមតិ» ។ រឿងរ៉ាវ «ដែលមិនដឹងពីមុនមក» ត្រូវបានលាតត្រដាងរួចហើយដូចជារឿងរ៉ាវរបស់អ្នកគ្រូ ឡុង វណ្ណៈ ជាគ្រូបង្រៀនមកពីខេត្តប៉ៃលិនដែលជាអតីតតំបន់ខ្មែរក្រហមជាដើម ។ អត្ថបទរបស់អ្នកគ្រូវណ្ណៈ ធ្វើការចងក្រងពីបទពិសោធន៍របស់អ៊ំស្រី ឈឺន ស្នា ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។ កាលពីក្មេង អ៊ំស្រី ឈឺន ស្នា មានបំណងចង់ធ្វើជាជាងកាត់ដេរហើយនៅពេលដែល

ខ្មែរក្រហមចាប់ផ្តើមជ្រើសរើសជាងកាត់ដេរ អ៊ឹស្រីបានចូលបម្រើបដិវត្តន៍បើទោះបីជាឪពុកម្តាយរបស់អ៊ឹស្រីមានការស្ទាក់ស្ទើរក៏ដោយ ។ ខ្មែរក្រហមមិនអាចបំពេញបំណងរបស់អ៊ឹស្រីឡើយ ។ អ៊ឹស្រីត្រូវបានបញ្ជូនទៅខេត្តបាត់ដំបងជាមួយនឹងនារីចំនួន១០នាក់ទៀតឲ្យទៅធ្វើស្រែ ។ នៅពេលដែលនារីផ្សេងទៀតសុំត្រឡប់ទៅផ្ទះវិញ ខ្មែរក្រហមបានសម្លាប់នារីទាំងនោះចោល ។ អ៊ឹស្រី ឈឹន ស្មា មានសំណាងដែលអាចគេចផុត ហើយរួចរស់រានមានជីវិតពីរបបនោះ ។

ដូចគ្នានេះដែរ អត្ថបទផ្សេងទៀតក៏ធ្វើការទទួលស្គាល់រឿងរ៉ាវជីវិតមុនរបបខ្មែរក្រហមដូចជា អត្ថបទរបស់អ្នកគ្រូ សុខ សូមុន្នី ដែលជាគ្រូបង្រៀនថ្នាក់ខេត្តមកពីវិទ្យាល័យហ៊ុនសែន កំពង់កន្ទួត ។ នៅក្នុងអត្ថបទរបស់អ្នកគ្រូ «បុណ្យដារលាន» អ្នកគ្រូបានរៀបរាប់ពីពិធីបុណ្យពិសេសមួយដែលអ្នកគ្រូបានចូលរួមអបអរសាទរក្រោយរដូវប្រមូលផលចប់រួចរាល់ ។ យោងតាមអ្នកគ្រូ សុខ សូមុន្នី អ្នកភូមិមានជំនឿថា ពិធីបុណ្យដារលាននេះបង្ហាញថាមនុស្សមានជាប់ពាក់ព័ន្ធជាមួយនឹងដី ដែលជំនឿនេះហើយធ្វើឲ្យប្រជាជនកម្ពុជាគោរពបូជាដូងព្រលឹងដែលជួយថែរក្សាការពារដី ។ ភាគច្រើនចូលប្រារព្ធពិធីបុណ្យនេះនៅក្រោមពន្លឺព្រះច័ន្ទហើយអ្នកភូមិមកជួបជុំគ្នាដើម្បីរាំរែកនិងបួងសួងសុំឲ្យទិន្នផលស្រូវសម្បូរហូរហៀរនៅឆ្នាំក្រោយទៀត ។ ចំណែកឯអត្ថបទផ្សេងទៀតគឺធ្វើការចងក្រងពីរឿងរ៉ាវនៃរបបខ្មែរក្រហម ប្រវត្តិភូមិឃុំ និងបញ្ហាសង្គមនាពេលបច្ចុប្បន្ននេះ ។

## ដំណើរទស្សនកិច្ចទៅប្រាសាទព្រះវិហារ

នៅថ្ងៃទីពីរនៃវគ្គសិក្ខាសាលា លោកគ្រូ-អ្នកគ្រូទាំងអស់បានធ្វើដំណើរទៅទស្សនាប្រាសាទព្រះវិហារដែលមានទីតាំងនៅភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាជាប់ព្រំដែនប្រទេសថៃ ហើយដែលត្រូវចំណាយពេលធ្វើដំណើរអស់ពីរម៉ោង ។ ប្រាសាទព្រះវិហារគឺជាប្រាសាទដ៏សំខាន់បំផុតសម្រាប់ស្មារតីជាតិនិយមនាពេលបច្ចុប្បន្ន ។ ប្រវត្តិសាស្ត្រខ្មែរក្រហមនិងក៏ជាមូលន័យសំខាន់នៃ «ការចងក្រងប្រវត្តិសាស្ត្រកម្ពុជា» របស់សិក្ខាសាលានេះដែរ ។ ព័ត៌មានប្រវត្តិសាស្ត្ររបស់ប្រាសាទព្រះវិហារមានចែងដូចខាងក្រោមនេះ ។

ព្រះបាទសូរ្យវរ្ម័នបានកសាងប្រាសាទព្រះវិហារនេះឡើងកាលពីសតវត្សរ៍ទី៩ នៅលើកំពូលភ្នំដងរែកដែលមានកម្ពស់ប្រមាណ៥៥០ម៉ែត្រ ។ ប្រាសាទព្រះវិហារលាតសន្ធឹងប្រហែលជាមួយពាន់ម៉ែត្រ ហើយត្រូវបានកសាងឡើងដើម្បីគោរពបូជាព្រះសិវៈនៃលទ្ធិហិណ្ឌូ ។ ប្រាសាទព្រះវិហារគឺជាប្រាសាទដែលត្រូវបានកសាងឡើងដោយលាតសន្ធឹងពីជើងទៅត្បូងហើយរចនាបទរបស់ប្រាសាទនេះមានភាពស្រស់ស្អាតនិងអស្ចារ្យបំផុតនៅក្នុងចំណោមប្រាសាទនានាដែលកសាងឡើងនៅក្នុងសម័យអង្គរ ។ ប្រាសាទព្រះវិហារធ្លាប់ជារាជធានីរបស់អាណាចក្រខ្មែរ ។ ប៉ុន្តែក្រោយពីការដួលរលំនៃអាណាចក្រអង្គរមក កងទ័ពសៀម (បច្ចុប្បន្នជាប្រទេសថៃ) បានកាន់កាប់ទឹកដីរបស់ប្រាសាទព្រះវិហារអស់រយៈពេលជាង៤០០ឆ្នាំ ។ ប៉ុន្តែនៅដើមទសវត្សរ៍៦០ ក្រោយពីទទួលបានឯករាជ្យពីប្រទេសបារាំង ប្រជាជនកម្ពុជាបានតស៊ូទាមទារទឹកដីព្រះវិហារមកវិញ ។ ក្រោយពីជម្លោះដ៏ជូរចត់នៅក្នុងកិច្ចប្រជុំនៅទីក្រុងឡាអេ ទឹកដីព្រះវិហារត្រូវបានប្រគល់ជូនប្រទេសកម្ពុជាវិញ ។ មុននិងក្នុងអំឡុងរបបខ្មែរក្រហម តំបន់ប្រាសាទព្រះវិហារបានក្លាយជាតំបន់គ្រប់គ្រងដោយខ្មែរក្រហម ។

នៅឆ្នាំ១៩៧៩ក្រោយពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមបានបញ្ចប់ទៅ ជនភៀសខ្លួនកម្ពុជារាប់ពាន់នាក់បាននាំគ្នាមករស់នៅប្រទេសថៃ ។ បួនខែក្រោយមកប្រទេសថៃមិនចង់ទទួលខុសត្រូវចំពោះប្រជាជនខ្មែរដែល «ខ្វត់ខ្វាយ» និង «សាហាវ» ទាំងអស់នោះតទៅទៀតឡើយ ដូច្នេះប្រទេសថៃ ក៏បានប្រាប់ឲ្យសហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលីមក «ជ្រើសរើសមនុស្ស» ដែលប្រទេសទាំងនេះត្រូវការ ។ ក្រោយពេលដែលជនភៀសខ្លួនចំនួន១២០០នាក់ត្រូវបានជ្រើសរើសដោយប្រទេសទាំងអស់នេះ មកជនភៀសខ្លួនដែលនៅសេសសល់ត្រូវបានដឹកជញ្ជូនតាមរថយន្តក្រុងទៅកាន់ទឹកដីព្រះវិហារ ។ ដោយនឿយហត់នឹងជួយប្រជាជនកម្ពុជា កងកម្លាំងថៃបានបញ្ជូនប្រជាជនកម្ពុជាប្រមាណ៤២,០០០នាក់ទៅក្នុងរថយន្តក្រុងរួចនាំអ្នកទាំងអស់នោះមកកាន់ទឹកដីព្រះវិហារ ។ ក្រោយពីរួចរស់មានជីវិតពីឋាននរកអស់រយៈពេលបួនឆ្នាំមក ប្រជាជនចំនួន៣,០០០នាក់ត្រូវបានស្លាប់នៅក្នុងពេលធ្វើដំណើរថ្មើរជើងដ៏ឆ្ងាយ ហើយ៧,០០០នាក់ទៀតនៅមិនទាន់ទទួលបានព័ត៌មានអ្វីនៅឡើយទេ ។ មានក្រុមជនអ្នកភៀសខ្លួន

ជាច្រើនក្រុមត្រូវបានបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញរហូតដល់ខែធ្នូ ឆ្នាំ១៩៧៩ដែលមានមនុស្សប្រមាណ៨៥០នាក់ត្រូវបានបញ្ជូនត្រឡប់មកវិញដោយធ្វើដំណើរឆ្លងកាត់ជ្រលងភ្នំនៅភាគខាងជើងនៃខេត្តអរញ្ញប្រាថេតដែលនៅទីនោះទាហានថៃបានបង្ខំឲ្យជនភៀសខ្លួនទាំងនោះដើរកាត់តំបន់ដែលមានគ្រាប់មីនហើយប្រសិនបើប្រឆាំងនឹងបញ្ជាទាហានថៃនឹងបាញ់សម្លាប់អ្នកទាំងនោះចោល ។ ដូចគ្នានេះដែរមានសេចក្តីរាយការណ៍មកទៀតថា ទាហានថៃបានច្រានអ្នកភៀសខ្លួនខ្មែរទម្លាក់ពីកំពូលភ្នំដែលមានកម្ពស់ប្រមាណ៥៥០ម៉ែត្រ ។

ចាប់ពីទសវត្សរ៍៨០រហូតមកដល់សព្វថ្ងៃនេះ ប្រទេសថៃបានទាមទារប្រាសាទព្រះវិហារត្រឡប់ទៅវិញដោយអះអាងថាជារបស់ខ្លួន ហើយបដិសេធមិនទទួលស្គាល់ថា កម្ពុជាជាម្ចាស់នៃប្រាសាទព្រះវិហារឡើយ បើទោះបីជាមានសេចក្តីសម្រេចជាអន្តរជាតិក៏ដោយ ។ ប៉ុន្តែក្រោយពីជម្លោះផ្នែកច្បាប់ អំពើសាហាវឃោរឃៅនិងសង្គ្រាមតាមព្រំដែនអស់រយៈពេលជាងមួយទសវត្សរ៍មកអង្គការយូនីស្កូបានទទួលស្គាល់ប្រទេសកម្ពុជាជាប្រទេសជាម្ចាស់តែមួយគត់នៃប្រាសាទដែលក្លាយជាបេតិកភ័ណ្ឌពិភពលោកនៅឆ្នាំ២០០៨ ។ អ្នកលក់ដូរនាំគ្នាលក់ដូរវត្ថុអនុស្សាវរីយ៍ស្តីពីប្រាសាទព្រះវិហារដ៏ល្បីល្បាញនេះ ។ មោទកភាពជាតិកើនឡើងដល់កំពូល ។ ទោះបីជាមានសេចក្តីសម្រេចកាលពីឆ្នាំ២០០៨ក៏ដោយ ក៏ប្រទេសថៃនៅតែបន្តដាក់កងកម្លាំងរបស់ខ្លួននៅលើកំពូលប្រាសាទព្រះវិហារដែរ ហើយចងទង់ជាតិរបស់ខ្លួនទៀតផង ។ ជាលទ្ធផលជម្លោះនៅតាមព្រំដែនក៏កើតមានឡើងរវាងប្រទេសកម្ពុជានិងប្រទេសថៃនៅឯខេត្តព្រះវិហារ ។ ដប់ថ្ងៃមុននឹងវគ្គសិក្សាសាលានៅខេត្តព្រះវិហារបានចាប់ផ្តើម ប្រទេសថៃបានដកកម្លាំងរបស់ខ្លួនចេញពីប្រាសាទព្រះវិហារ ។ ខណៈពេលដែលគ្រូបង្រៀនបានឡើងទៅទស្សនាប្រាសាទព្រះវិហារ លោកគ្រូ-អ្នកគ្រូទាំងអស់បានឃើញទង់ជាតិប្រទេសកម្ពុជាបក់រវិចៗដែលជានិមិត្តសញ្ញាទាក់ទងនឹងមូលន័យនៃការចងក្រងប្រវត្តិសាស្ត្រកម្ពុជារបស់វគ្គសិក្សាសាលានេះ ។



បណ្ឌិត ជា ផល្លា ជាមួយលោក ឌី ខាំបូលី កំពុងធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំ



លោកគ្រូ-អ្នកគ្រូពិភាក្សាតាមក្រុមនៅក្នុងការប្រជុំប្រចាំឆ្នាំ

## វគ្គសិក្សាសាលា ៖ ការពិភាក្សានិងការថ្លែងសុន្ទរកថារបស់ភ្ញៀវកិត្តិយស

ការពិភាក្សានិងការថ្លែងសុន្ទរកថានៅក្នុងការបើកវគ្គសិក្សាសាលានេះគឺជាការចាប់ផ្តើមជំហានដំបូងក្នុងការបង្កើតក្រុមការងារមួយសម្រាប់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាក្រោមប្រធានបទ «ទឹកដីនៃការផ្សះផ្សា» ។ តួយ៉ាងដូចកញ្ញា សូ ហ្វារីណា ដែលជាអ្នកស្រាវជ្រាវបានធ្វើការពិភាក្សាអំពីសារសំខាន់និងផលលំបាកនៃការប្រមូលឯកសារតាមរយៈការសួរនាំ ។ ចំណែកឯលោកជីទាវ ទន់ សាអ៊ីម បានសង្កត់ធ្ងន់ទៅលើតួនាទីសំខាន់របស់គ្រូបង្រៀននៅក្នុងសង្គមខ្មែរ ។ លោកសាស្ត្រាចារ្យ ជួរ គីរី ធ្វើការពិភាក្សាពីភាពខុសគ្នារវាងការយល់ដឹងនៃពាក្យអំពើប្រល័យពូជសាសន៍តាមន័យច្បាប់ និងតាមន័យអក្សរសាស្ត្រ ។ ខណៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងបំពេញនូវតម្រូវការតាមច្បាប់ គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា នឹងអាច

ជួយសម្របសម្រួលដល់ការយល់ដឹងពីអំពើប្រល័យពូជសាសន៍នេះតាមរយៈការអប់រំដើម្បីជួយបំពេញនូវចន្លោះខ្វះខាត ។ លោក អេង កុកថាយ ដែលជាវាគ្មិននិងជានាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាបានលើកឡើងបន្ថែមពីបញ្ហានេះ ដោយពិភាក្សាស្តីពីការអត់ឱន និងទស្សនៈរបស់ព្រះពុទ្ធដែលធ្វើឲ្យការអត់ឱនទោសនិងការផ្សះផ្សាអាចធ្វើទៅបាន ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃបទបង្ហាញ ដែលបានធ្វើឡើងនៅក្នុងវគ្គសិក្ខាសាលានេះ ។

**លោក ឃុត ឥន្ទសេរី អ្នកតំណាងមកពីមូលនិធិអន្តការអាស៊ី**

លោក ឃុត ឥន្ទសេរី ដែលជាតំណាងមកពីអង្គការមូលនិធិអាស៊ីបានមានមតិស្វាគមន៍ចំពោះសិក្ខាកាមទាំងអស់ ហើយបានធ្វើការសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីបន្តនូវកិច្ចខិតខំប្រឹងប្រែងក្នុងការផ្សះផ្សា ។ ជាពិសេសលោកបានថ្លែងប្រាប់ដល់សិក្ខាកាមទាំងអស់ពីភាពសប្បាយរីករាយរបស់លោកក្នុងការជួយឧបត្ថម្ភវគ្គបណ្តុះបណ្តាលនេះ ។ ក្នុងនាមជាគ្រូបង្រៀនអស់រយៈពេលជាង៣០ឆ្នាំ លោក ឃុត ឥន្ទសេរី មានសេចក្តីរំភើបណាស់ដែលបានឃើញការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សានៅតាមសាលា ហើយលោកក៏បានបញ្ជាក់ជាថ្មីម្តងទៀតពីសារសំខាន់របស់គ្រូបង្រៀនដែលមាននៅក្នុងសង្គមខ្មែរ ។

**លោក ស៊ុយ សេរីទ្ធិ អភិបាលរងនៃខេត្តព្រះវិហារ**

លោក ស៊ុយ សេរីទ្ធិ អភិបាលរងខេត្តព្រះវិហារបានថ្លែងបញ្ជាក់ពីសារសំខាន់នៃគម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍នេះនិងពីការបង្កើនសមត្ថភាពគ្រូបង្រៀនតាមរយៈការសិក្សារៀនសូត្រពីវិធីសាស្ត្រថ្មី និងការជំរុញឲ្យមានជំនាញខាងការត្រិះរិះពិចារណាក្នុងបណ្តាគ្រូបង្រៀនក៏ដូចជាសិស្សានុសិស្ស ។ នៅក្នុងបទថ្លែង លោក ស៊ុយ សេរីទ្ធិ ក៏បាននិយាយអំពីបទពិសោធន៍ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមរបស់លោកដែលនេះហើយគឺជាឧទាហរណ៍មួយទៀតបញ្ជាក់ថា គម្រោងអប់រំស្តីពីរបបប្រល័យពូជសាសន៍នេះអាចផ្តល់ជាវេទិកាមួយដើម្បីឲ្យអ្នករួចរស់ពីរបបនោះអាចរៀបរាប់ពីបទពិសោធន៍ដ៏ឈឺចាប់កាលពីអតីតកាល ។ លោកបាននិយាយប្រាប់សិក្ខាកាមទាំងអស់ថា ក្រុមគ្រួសាររបស់លោកក៏មានឈ្មោះនៅក្នុងបញ្ជីចាប់ខ្លួននិងសម្លាប់ដែរ ដោយសារតែគ្រួសាររបស់លោកជាអ្នកធូរធារ មានផ្ទះសម្បែង តែចៃដន្យល្អគ្រួសាររបស់លោកបានរួចរស់ពីសេចក្តីស្លាប់នេះបាន ។


លោកគ្រូ-អ្នកគ្រូពិភាក្សាតាមក្រុមនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ

លោកក៏បានបញ្ជាក់បន្ថែមម្តងទៀតដែរពីសារសំខាន់របស់គម្រោងនេះនៅក្នុងការថែរក្សាប្រវត្តិសាស្ត្រក៏ដូចជាជម្នះនូវការមិនទទួលស្គាល់របស់ក្មេងជំនាន់ក្រោយចំពោះប្រវត្តិសាស្ត្ររបស់ឪពុកម្តាយខ្លួន ។ លោក ស៊ុយ សេរិទ្ធិ បានបញ្ជាក់ទៀតថា រឿងរ៉ាវ និងប្រវត្តិសាស្ត្រទាំងនេះនឹងមិនត្រូវបានលុបបំបាត់ចោលនោះទេ ។ លោកបញ្ចប់នូវសុន្ទរកថារបស់លោកដោយធ្វើការគូសបញ្ជាក់ពីទីតាំងនៃការបើកវគ្គសិក្ខាសាលានេះថា លោក «មានមោទកភាពណាស់ដែលបានកើតជាកូនខ្មែរ និងមានប្រាសាទព្រះវិហារជារបស់ខ្លួន» ។

## លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា

លោកជំទាវ ទន់ សាអ៊ីម បានថ្លែងសុន្ទរកថាមួយដែលគួរឲ្យចាប់អារម្មណ៍ ដោយធ្វើការសង្កត់ធ្ងន់ទៅលើតួនាទីរបស់គ្រូបង្រៀននៅក្នុងការព្យាបាល ការផ្សះផ្សា និងការអប់រំ ។ លោកជំទាវក៏បានថ្លែងអំណរគុណផងដែរកាលដែលបានបង្កើតនូវការប្រជុំប្រចាំឆ្នាំនេះដែលបានប្រមូលនូវលោកគ្រូ-អ្នកគ្រូមកពីបណ្តាខេត្តនានាមកជួបជុំគ្នានៅទីនេះ ហើយលោកជំទាវក៏ជឿជាក់ថា ការសរសេរពីប្រវត្តិសាស្ត្ររបស់គ្រូម្នាក់ៗនេះគឺពិតជាមានសារសំខាន់ណាស់ក្នុងការជំរុញឲ្យគម្រោងនេះបន្តទៅមុខទៀត ដោយអះអាងថា ការសរសេរប្រវត្តិសាស្ត្ររបស់ខ្លួននេះគឺ «ពិតជាប្រវត្តិសាស្ត្រមួយដែលមានតម្លៃមិនអាចកាត់ថ្លៃបាន» ។ ដូចគ្នាទៅនឹងប្រសាសន៍របស់លោកអភិបាលរងខេត្តដែរ លោកជំទាវ ទន់ សាអ៊ីម បានប្រើប្រាស់នូវវគ្គសិក្ខាសាលានេះដើម្បីធ្វើការគូសបញ្ជាក់ពីសារសំខាន់នៃទីតាំងបើកវគ្គនេះថាជាកន្លែងមួយល្អក្នុងការលើកឡើងនូវការលំបាកនៃការអប់រំនៅក្នុងខេត្តព្រះវិហារនេះ ដោយសារតែខេត្តនេះមានចម្រុះទៅដោយជនជាតិភាគតិចគួយដែលមានដល់ទៅជាង៧០ភាគរយនៃប្រជាជនទាំងអស់ ។ លោកជំទាវបានសង្កត់ធ្ងន់ទៅលើតម្រូវការរបស់ក្រសួងអប់រំក្នុងការស្វះស្វែងរកមធ្យោបាយដើម្បីធ្វើឲ្យមានតុល្យភាពអប់រំនៅតាមសាលារវាងប្រជាជនខ្មែរនិងក្រុមជនជាតិភាគតិច ។ ដូចគ្នាផងដែរ លោកជំទាវក៏បានលើកឡើងពីបញ្ហាលំបាកនៃការចូលរៀនតាមសាលារបស់កូនសិស្សនៅក្នុងខេត្តនេះ ដោយសារតែទីតាំងរបស់សាលាភាគច្រើននៅឆ្ងាយដាច់ស្រយាលពីភូមិដែលជាហេតុធ្វើឲ្យមានសិស្សជាច្រើនមិនបានចូលរៀន ។

លោកជំទាវ ទន់ សាអ៊ីម បានជំរុញឲ្យលោកគ្រូ-អ្នកគ្រូធ្វើការប្រមូលប្រវត្តិរបស់អ្នករស់រានមានជីវិតពីរបបនេះ ដោយសារតែអ្នកទាំងនោះគឺជាឃ្លាំងប្រវត្តិសាស្ត្ររស់និងអាចចូលរួមចំណែកមួយផ្នែកធំនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ហើយលោកជំទាវក៏មានប្រសាសន៍ថែមទៀតថា លោកជំទាវនឹងចូលរួមសរសេរពីបទពិសោធន៍កាលពីជំនាន់ខ្មែរក្រហមនោះជូនមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកជំទាវធ្វើការបញ្ជាក់បន្ថែមពីតម្លៃនៃគម្រោងនេះដោយនិយាយថា ខណៈពេលដែលខាងមន្ត្រី ឬស្ថាប័នអង្គការនានាធ្វើការចងក្រងប្រមូលប្រវត្តិសាស្ត្រជារួម លោកគ្រូអ្នកគ្រូដែលនៅតាមមូលដ្ឋានមានតួនាទីសំខាន់ណាស់ក្នុងការធ្វើឲ្យគម្រោងនេះកាន់តែមានប្រសិទ្ធភាពជាងនេះដោយសារតែការធ្វើឲ្យមានប្រសិទ្ធភាពនេះត្រូវការនូវកិច្ចខំប្រឹងប្រែងរួមសហការគ្នាទូទាំងប្រទេស ដើម្បីធ្វើការថែរក្សាប្រវត្តិសាស្ត្រក៏ដូចជាធ្វើការផ្សះផ្សាដែរ ។



លោកគ្រូ-អ្នកគ្រូយកចិត្តទុកដាក់ស្តាប់អង្គប្រជុំប្រចាំឆ្នាំ

នៅក្នុងសុន្ទរកថា លោកជំទាវក៏បានលើកទឹកចិត្តលោកគ្រូ-អ្នកគ្រូទាំងអស់ឲ្យមានទស្សនៈបើកទូលាយ ហើយ «ដាក់ខ្លួនដើម្បីរៀនសូត្របន្ថែម» ។ លោកជំទាវបញ្ជាក់ទៀតថា ការសិក្សារៀនសូត្រគឺជាដំណើរការមួយជីវិត ដូចជាគ្រូបង្រៀនដែរ «ត្រូវរៀន...រហូតដល់ចាស់» ។ លោកជំទាវ ក៏ជំរុញឲ្យលោកគ្រូ-អ្នកគ្រូ

ធ្វើការចែករំលែកនូវព័ត៌មានជាមួយគ្នាទៅវិញទៅមកដើម្បីផ្តោតទៅលើការធ្វើការមួយឆ្ពោះទៅរកប្រសិទ្ធភាពនៃវិធីសាស្ត្របង្រៀនក្នុងគោលបំណងធ្វើឲ្យកាន់តែមានជំនាញទាំងអស់គ្នា ។

លោកជំទាវ ទន់ សាអ៊ីម ក៏បានពិភាក្សាអំពីភាពខុសគ្នារវាងការសរសេរប្រវត្តិសាស្ត្រជាក់ស្តែង និងអំពីអារម្មណ៍ផ្ទាល់ខ្លួនដែលជាការឆ្លើយតបមួយទៅនឹងការត្អូញត្អែររបស់គ្រូបង្រៀនមកលើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងវគ្គសិក្ខាសាលាពីមុនថា កម្មវិធីសិក្សានេះខ្វះខាតនូវ «មនោសញ្ចេតនា» ។ លោកជំទាវបានអះអាងថា អ្នកនិពន្ធប្រវត្តិសាស្ត្រត្រូវបានចៀសវាងនូវការបញ្ចូលមនោសញ្ចេតនាទៅក្នុងប្រវត្តិសាស្ត្រដោយសារតែការធ្វើបែបនោះនឹងអាចបង្កើតនូវប្រវត្តិសាស្ត្រមួយដែលមិនច្បាស់លាស់ ។ ជាងនេះទៅទៀត លោកគ្រូ-អ្នកគ្រូនិងអ្នកនិពន្ធប្រវត្តិសាស្ត្រត្រូវសរសេរនូវប្រវត្តិសាស្ត្ររបស់ខ្លួនតាមអង្គហេតុជាក់ស្តែងដើម្បីធានាថាការបង្ហាត់បង្រៀនប្រវត្តិសាស្ត្រមួយដែលមានសុក្រឹតភាពនិងជំរុញឲ្យមានការផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះដោយសារតែប្រវត្តិសាស្ត្រតាមបែបមនោសញ្ចេតនានឹងអាចបង្កឲ្យមាននូវការខឹង គុំកួន សងសឹកគ្នា ហើយជំរុញឲ្យមានការមិនរាប់អានគ្នានិងបន្ថែមឲ្យកាន់តែមានការឃ្លាតឆ្ងាយពីគ្នាផងដែរ ។ លោកជំទាវ ក៏បានលើកឡើងពីបទសោធន៍ផ្ទាល់ខ្លួនមួយអំពីអតីតកម្មាភិបាលនារីម្នាក់ឈ្មោះ អ៊ឹម ចែម ដែលបានប្រាប់លោកជំទាវថាគាត់មានអារម្មណ៍ធូរស្រាលបន្តិចដោយសារលោកជំទាវធ្វើការទទួលស្គាល់រូបគាត់ថ្មីដ្បិតគាត់ជាអតីតកម្មាភិបាលខ្មែរក្រហម ប៉ុន្តែគាត់ក៏ជា «ខ្មែរ» ដែរ ។

ទោះបីជាយ៉ាងនេះក្តី លោកជំទាវក៏បានគូសបញ្ជាក់ម្តងទៀតអំពីសារសំខាន់នៃការសរសេរប្រវត្តិសាស្ត្រតាមអារម្មណ៍ ដោយលោកជំទាវអះអាងថា ការសរសេរប្រភេទនេះ ទោះបីជាយ៉ាងណាក៏ដោយ ក៏បានបញ្ជាក់ពី «ការពិត» នៅក្នុងនោះដែរ ។ លោកជំទាវអះអាងថា «ប្រវត្តិសាស្ត្រភូមិយើង» នេះអាចជួយបន្ថែមទៅលើសៀវភៅប្រវត្តិសាស្ត្រជាក់ស្តែងទូទៅ ដោយធ្វើការបំពេញបន្ថែមទៅលើការពិតដទៃទៀតនៅតាមភូមិឃុំដែលមិនត្រូវបានដាក់បញ្ចូលនៅក្នុងសៀវភៅនេះ ។

ជាកិច្ចបញ្ចប់ លោកជំទាវ ទន់ សាអ៊ីម បានធ្វើការពិភាក្សាពីសារសំខាន់នៃការធ្វើពាក្យស្លោកប្រឆាំងនឹងអំពើប្រល័យពូជសាសន៍ដើម្បីជំរុញឲ្យមានការផ្សះផ្សានិងបំបាត់ការសងសឹកគុំកួន ដោយសារតែសិស្សនឹងមើលឃើញពាក្យស្លោកនេះជារៀងរាល់ថ្ងៃ ដែលនិយាយពីការការពារនិងការយល់ដឹងពីអំពើប្រល័យពូជសាសន៍ ហើយលោកជំទាវក៏សង្ឃឹមថាសិស្សានុសិស្សនឹងសិក្សាយល់ដឹងពីអត្ថន័យទាំងនេះ ។

## លោកសាស្ត្រាចារ្យ ស៊ីវ ធួន គ្រូបង្គោលថ្នាក់ជាតិ

លោកសាស្ត្រាចារ្យ ស៊ីវ ធួន ដែលជាគ្រូបង្គោលថ្នាក់ជាតិមកពីក្រសួងអប់រំ យុវជន និង កីឡាបានធ្វើបទបង្ហាញខ្លីមួយ



លោក ឆាំង យុ កំពុងបង្ហាញអំពីរូបភាពទៅកាន់លោកគ្រូ-អ្នកគ្រូនៅក្នុងការប្រជុំប្រចាំឆ្នាំ

ទាក់ទងនឹងបទពិសោធន៍របស់លោកសាស្ត្រាចារ្យដែលបានចូលរួមចំណែកនៅក្នុងការសរសេរ «ប្រវត្តិសាស្ត្រភូមិយើង» ។ លោកសាស្ត្រាចារ្យក៏បានធ្វើការពិភាក្សានូវការលំបាកដែលលោកគ្រូ-អ្នកគ្រូមួយចំនួនបានជួបប្រទះនៅពេលចុះទៅធ្វើការស្រាវជ្រាវ និងរៀបរៀងរឿងរ៉ាវទាំងនោះ ។ ឧទាហរណ៍ លោកគ្រូបាននិយាយថាលោកគ្រូ-អ្នកគ្រូមួយចំនួនដែលមិនមែនជាអ្នករស់នៅក្នុងភូមិនោះតាំងពីមុនមកគឺមានការលំបាកក្នុងការធ្វើបទសម្ភាសន៍ដោយសារតែមិនស្គាល់អ្នកភូមិជិតស្និទ្ធនោះទេ ។ ទន្ទឹមនឹងពេលនោះដែរ លោកគ្រូ-អ្នកគ្រូដែលរស់នៅខេត្តរតនគិរី និងមណ្ឌលគិរីប្រហែលជាជួបការលំបាកដោយសារតែលោកគ្រូ-អ្នកគ្រូទាំងនោះត្រូវធ្វើការជាមួយក្រុមជនជាតិភាគតិច ។ ដូច្នេះ ដើម្បីដោះស្រាយ

នឹងការលំបាកទាំងនេះ លោកសាស្ត្រាចារ្យបានស្នើឲ្យមានការសរសេរជាដៃគូជាមួយគ្រូផ្សេងទៀត ប៉ុន្តែសរសេរអត្ថបទតែមួយ តែអ្នកនិពន្ធពីរនាក់ ដោយសារតែលោកសាស្ត្រាចារ្យយល់ឃើញថាការសរសេរដោយអ្នកនិពន្ធពីរនេះគឺជាយុទ្ធសាស្ត្រមួយដ៏ជោគជ័យ ។ ជាងនេះទៅទៀត លោកសាស្ត្រាចារ្យជឿជាក់ថានេះគឺពិតជាមានសារសំខាន់ណាស់ក្នុងការបណ្តុះឲ្យមានការចាប់អារម្មណ៍ក្នុងការសរសេរប្រវត្តិសាស្ត្រជាជាងធ្វើតែទៅតាមវិធីសាស្ត្រនៃការថែរក្សាប្រវត្តិសាស្ត្រតាមការនិយាយ ។ លោកសាស្ត្រាចារ្យជឿជាក់ថា ការធ្វើបែបនេះពិតជាមានអត្ថប្រយោជន៍ណាស់ក្នុងការចងក្រង និងអភិរក្សប្រវត្តិសាស្ត្រនេះសម្រាប់ក្មេងជំនាន់ក្រោយនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ។

**លោក គ្រីស្តូហ្វឺ ឌៀរីង សហនិពន្ធនៃសៀវភៅណែនាំគ្រូបង្រៀន និងអ្នកស្រី ស៊ីរី សាវីណា ផ្តល់បទបង្ហាញពី «ទស្សនៈចម្បងៗនៃការអភិវឌ្ឍជំនាញ»**

បន្ទាប់ពីសម្រាកទទួលទានអាហារសម្រន់រួច លោក គ្រីស្តូហ្វឺ ឌៀរីង ដែលជាសហនិពន្ធនៃសៀវភៅណែនាំគ្រូបង្រៀន និងលោកស្រី ស៊ីរី សាវីណា បានធ្វើការផ្តល់បទបង្ហាញពី «ទស្សនៈចម្បងៗនៃការអភិវឌ្ឍជំនាញ» ។ នៅក្នុងបទបង្ហាញ លោក ឌៀរីង បានធ្វើការលើកឡើងពីលទ្ធផលស្ទាបស្ទង់មតិ និងការអង្កេតទៅលើវគ្គសិក្សាមុនៗ និងការលំបាកជារួមដែលរកឃើញថា ៖ ១) សមត្ថភាពនៅក្នុងការផ្ទេរវិធីសាស្ត្របង្រៀនរបស់សិក្ខាកាមថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅមានកម្រិតនៅឡើយ ហើយតម្រូវឲ្យមានការពង្រឹងសមត្ថភាពបន្ថែម ។ ២) លោកគ្រូថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានមានការខ្វែងគំនិតគ្នាទាក់ទងនឹងការបកស្រាយវិធីសាស្ត្របង្រៀន និងតម្រូវឲ្យមានការបកស្រាយរួមមួយ ។

បន្ទាប់មក វាគ្មិនទាំងពីរបានផ្តល់នូវបទបង្ហាញពីទស្សនៈទូទៅនៃការអភិវឌ្ឍជំនាញ ដោយអះអាងថា ជំនាញគឺមិនមែនជាសញ្ញាមួយដែលផ្តោតតែទៅលើធនធាន ប៉ុន្តែចំណេះវិជ្ជាថ្មីមួយតែប៉ុណ្ណោះទេ ។ ជាងនេះទៅទៀត ជំនាញគឺរួមបញ្ចូលទាំង «ដំណើរការនៃការជ្រួតជ្រាបពីគំនិតថ្មី និងវិធីសាស្ត្រ» ក៏ដូចជាការទទួលស្គាល់ផ្នែកមួយរបស់បុគ្គល ដើម្បីធ្វើការបង្កើតនូវវិធីសាស្ត្របង្រៀនថ្មីផ្សេងៗជាច្រើនទៀត ។ ដោយយោងទៅលើសៀវភៅរបស់សកលវិទ្យាល័យខេមប្រ៊ីត ស្តីពីការបង្ហាញពីជំនាញដែលមានចំណងជើងថា *Cambridge Handbook of Expertise and Expert Performance* លោក ឌៀរីង និងលោកស្រី ស៊ីរី សាវីណា បានអះអាងថា យើងម្នាក់ៗត្រូវការ «ការអនុវត្តជាក់ស្តែងមួយក្នុងការសម្រេចបាននូវវត្ថុបំណងរបស់ខ្លួន» ហើយវាគ្មិនទាំងពីរក៏បានលើកទឹកចិត្តឲ្យសិក្ខាកាមម្នាក់ៗធ្វើការចែករំលែកនូវការយល់ដឹងទាំងអស់គ្នា ។

បន្ទាប់ពីរំឭកឡើងវិញនូវនិយមន័យនៃសហគមន៍សិក្សាបែបជំនាញ និងយោងទៅលើឧទាហរណ៍ប្រហាក់ប្រហែលផងនោះ លោក ឌៀរីង និងលោកស្រី ស៊ីរី សាវីណា បានបែងចែកសិក្ខាកាមទាំងអស់ជាក្រុមតូចៗ ដោយធ្វើដូច្នេះលោកគ្រូ-អ្នកគ្រូអាចជួបគ្នាដោយផ្ទាល់ដើម្បីងាយស្រួលធ្វើការពិភាក្សាលើចំណុចដែលត្រូវការកែតម្រូវ និងពីគោលបំណងនៃការកំណត់គោលដៅ ។ បន្ទាប់ពីការពិភាក្សាបានបញ្ចប់នៅតាមក្រុមតូចៗ


លោកគ្រូ-អ្នកគ្រូកំពុងពិភាក្សានៅតាមក្រុម

នីមួយៗ លោក ឌៀវីឌ និងលោកស្រី ស៊ីវ សាវីណា បានធ្វើការបង្ហាញពីលទ្ធផលសង្ខេបសន្និដ្ឋានដោយធ្វើការគូសបញ្ជាក់ពីចំណុចខ្លាំង និងចំណុចខ្សោយនៃវគ្គបណ្ដុះបណ្ដាលពីមុនៗ ។

ខាងក្រោមនេះគឺជាការឆ្លើយតបពីក្រុមតូចៗមួយចំនួន ៈ

១) លោកគ្រូ-អ្នកគ្រូត្រូវតែធ្វើការសិក្សាស្រាវជ្រាវឲ្យបានច្រើនដើម្បីធ្វើការបង្ហាត់បង្រៀនឲ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសលោកគ្រូ-អ្នកគ្រូដែលកើតក្រោយជំនាន់ខ្មែរក្រហម ។

២) លោកគ្រូ-អ្នកគ្រូត្រូវតែសួរនាំអ្នកភូមិបន្ថែមដើម្បីជាជំនួយដល់ការសិក្សា ។

៣) លោកគ្រូ-អ្នកគ្រូគួរតែចេះប្រើប្រាស់ឧទាហរណ៍ រូបភាព និងឯកសារផ្សេងៗពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

៤) ដើម្បីទទួលនូវការគោរពរាប់អាន លោកគ្រូ-អ្នកគ្រូគួរតែព្យាយាមឆ្លើយនឹងសំណួររបស់កូនសិស្សជាមុនសិនជាជាងគ្រាន់តែនិយាយថា «មិនដឹង» ហើយក្រោយមកគ្រូអាចឲ្យសិស្សទៅធ្វើការសិក្សានិងស្រាវជ្រាវបន្ថែមពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

៥) លោកគ្រូ-អ្នកគ្រូគួរតែមានវិធីសាស្ត្របង្រៀនមួយដែលយ៉ាងហោចណាស់ត្រូវមានភាពប្រហាក់ប្រហែលគ្នា ។

លោក អេង កុកថាយ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា និងនាយកផ្នែកស្រាវជ្រាវ «តើអាចមានការអត់ឱនទោសបានដែរឬទេ តើអាចបង្រៀនមនុស្សឲ្យចេះអត់ឱនគ្នាបានដែរឬទេ?»

លោក អេង កុកថាយ បានបន្តធ្វើបទបង្ហាញពីអត្ថបទស្រាវជ្រាវរបស់លោកដែលមានចំណងជើងថា «តើការអត់ឱនទោសអាចធ្វើបានដែរឬទេ ហើយថាតើអាចបង្រៀនមនុស្សឲ្យចេះអត់ឱនគ្នាបានដែរឬទេ?» នៅក្នុងបទបង្ហាញនេះ លោក អេង កុកថាយ បានរៀបរាប់ពីទស្សនៈនៃការអត់ឱនទោសនៅក្នុងសង្គមកម្ពុជា និងប្រទេសក្រោយជម្លោះ ហើយលោកបានអះអាងថា វិធីសាស្ត្រនៃការអត់ឱនទោសមានលក្ខណៈខុសប្លែកពីគ្នាអាស្រ័យលើវប្បធម៌របស់សង្គមនីមួយៗ ។ បទបង្ហាញរបស់លោកផ្ដោតពិសេសទៅលើឥទ្ធិពលនៃអំពើប្រល័យពូជសាសន៍របស់ប្រទេសកម្ពុជា និងស្វែងរកនូវមធ្យោបាយសម្រាប់ប្រជាជនកម្ពុជាដោះស្រាយជាមួយនឹងកេរដំណែលដែលបន្សល់ពីអំពើប្រល័យពូជសាសន៍នេះ ។ សម្រាប់រូបលោកផ្ទាល់ ការអត់ឱនទោសសំដៅលើ «ការដែលអាចវិវឌ្ឍទៅមុខបាន ដោយបោះបង់ចោលសោកនាដកម្ម» ។ លោក អេង កុកថាយ បានលើកឡើងថា ការធ្វើបែបនេះអាចកើតឡើងបានលុះត្រាតែដំណើរការតាមផ្លូវច្បាប់ត្រូវបានធ្វើឡើងជាមុនសិន ។ បទបង្ហាញរបស់លោកបានបញ្ចប់ទៅដោយការពិភាក្សាខ្លីពីការប្រណិប័តន៍សាសនាព្រះពុទ្ធ ។ បើទោះបីជាលោកបាននិយាយថា នៅក្នុងសៀវភៅធម៌របស់ព្រះពុទ្ធមិនមានលើកឡើងពីទស្សនៈអត់ឱនទោសនេះក៏ដោយ ក៏ប្រជាជនខ្មែរត្រូវបានទូន្មានប្រៀនប្រដៅថា «ពៀរ» រំងាប់ «ដោយការមិនចងពៀរ» ។

**ដួរ គីរី សាស្ត្រាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា និង ស៊ីវ ធួន គ្រូបង្គោលថ្នាក់ជាតិបកស្រាយពី «អត្ថន័យនៃអំពើប្រល័យពូជសាសន៍»**

បណ្ឌិត ដួរ គីរី បានបកស្រាយពីទស្សនៈដែលមិនពាក់ព័ន្ធនឹងច្បាប់នៃពាក្យប្រល័យពូជសាសន៍និងជាតិពន្ធុទៅតាមបរិបទកម្ពុជាដោយផ្ដោតទៅលើដើមកំណើតនៃពាក្យទាំងពីរនេះ ។ ពាក្យប្រល័យពូជសាសន៍នៅក្នុងភាសាខ្មែរមានន័យថា «សម្លាប់ពូជសាសន៍ សាសនា ឬជាតិសាសន៍របស់នរណាម្នាក់» ។ យោងទៅតាមសាស្ត្រាចារ្យ ដួរ គីរី ការបកស្រាយចំពោះលើពាក្យនេះគឺខុសពីការបកស្រាយតាមផ្លូវច្បាប់ ។ ប៉ុន្តែលោកបានសង្កត់ធ្ងន់ថា គ្រូបង្រៀនទាំងអស់គួរតែដឹងពីការបកស្រាយខុសៗគ្នា ជាពិសេសអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានតួនាទីរួមចំណែកផ្ដល់នូវយុត្តិធម៌ និងការចងចាំជារួម ។ បន្ទាប់មក លោក ស៊ីវ ធួន បានពិភាក្សាទៅលើដើមកំណើតនៃពាក្យជាតិពន្ធុ និងជនជាតិភាគតិចថាតែងតែពឹងផ្អែកទៅលើគ្នាទៅវិញទៅមក ។ លោកបានអះអាងថា ប្រជាជនកម្ពុជាជាច្រើនចាត់ទុកជនជាតិចាមមូស្លីមជាជនជាតិភាគតិច ប៉ុន្តែចំពោះចាមមូស្លីមផ្ទាល់គិតថា ខ្លួនឯងមិនមែនជាជនជាតិភាគតិចទេ ប៉ុន្តែគឺជាខ្មែរ ។

**បណ្ឌិត ជា ផល្លា សហអ្នកនិពន្ធសៀវភៅណែនាំគ្រូបង្រៀន និង ឌី ខាំបូលី អ្នកនិពន្ធប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បកស្រាយពី «ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជា**

*ប្រជាធិបតេយ្យឲ្យមានប្រសិទ្ធភាព»*

ជាជាងធ្វើការបង្រៀន បណ្ឌិត ជា ផល្លា និង ឌី ខាំបូលី បានជួយសម្របសម្រួលការពិភាក្សាជាមួយគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្តស្តីពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យមានប្រសិទ្ធភាព។ នៅអំឡុងពេលធ្វើបទបង្ហាញ អ្នកទាំងពីរបានសួរសិក្ខាកាមក្នុងសន្និសីទអំពីអ្វីដែលអ្នកទាំងនោះរកឃើញថាជាវិធីសាស្ត្របង្រៀនដ៏មានប្រសិទ្ធភាព និងអ្វីជាវិធីសាស្ត្របង្រៀនដ៏ពិបាក។ លោកគ្រូ-អ្នកគ្រូបានស្នើឲ្យបណ្ឌិត ជា ផល្លា និង ឌី ខាំបូលី បញ្ជាក់ពីវិធីសាស្ត្រនៅក្នុងសៀវភៅណែនាំគ្រូបង្រៀនដែលខ្លួនមិនទាន់យល់ដូចជាសកម្មភាព *«Jigsaw»* លំហាត់ប្រមូលគំនិត ដ្យាក្រាមវ៉ែន តារាង *K-W-L* ខិតប័ណ្ណទំនាក់ទំនងអន្តរជាតិ និងប្រអប់សង្គ្រោះជីវិត។ ដើម្បីជាការឆ្លើយតបនឹងសំណួរទាំងនេះ បណ្ឌិត ជា ផល្លា និង ឌី ខាំបូលី បានបង្ហាញពីគំរូមេរៀននិងសុំឲ្យគ្រូខ្លះទៀតមកបង្ហាញពីមេរៀននេះទៅគ្រូដទៃទៀត។ នៅអំឡុងពេលធ្វើបទបង្ហាញនោះ គ្រូម្នាក់មកពីខេត្តបាត់ដំបងបានលើកឡើងពីបញ្ហាលំបាកដែលគាត់និងគ្រូបង្រៀនដទៃទៀតបានជួបប្រទះ នៅពេលប្រើប្រាស់វិធីសាស្ត្រទាំងនេះ ពីព្រោះបន្ទប់រៀននៅកម្ពុជាមានសិស្សជាច្រើនដែលបញ្ហានេះបានឆ្លុះបញ្ចាំងពីការព្រួយបារម្ភដែលបានលើកឡើងនៅពេលបង្រៀននៅឆ្នាំ២០០៩។ អ្នកគ្រូ មុំ ម៉េត ដែលជាគ្រូបង្គោលថ្នាក់ជាតិបានឡើងមកខាងមុខ ហើយបកស្រាយថា វិធីសាស្ត្រទាំងនេះនៅតែអាចប្រើប្រាស់បាន ទោះបីជាបន្ទប់រៀនមិនធំក៏ដោយ។ អ្នកគ្រូបាននិយាយថា វិធីសាស្ត្រទាំងនេះមិនចាំបាច់យកទៅប្រើនៅគ្រប់ថ្នាក់ទេគឺអាចយកទៅប្រើនៅពេលដែលគ្រូមានពេលវេលាគ្រប់គ្រាន់។ អ្នកគ្រូក៏បានលើកទឹកចិត្តគ្រូបង្រៀនកុំឲ្យយល់ថា ខ្លួនត្រូវប្រើប្រាស់គ្រប់វិធីសាស្ត្រនៅក្នុងថ្នាក់នីមួយៗ តែគ្រូបង្រៀនគួរតែផ្តោតតែទៅលើវិធីសាស្ត្រតែមួយ។ បណ្ឌិត ជា ផល្លា ក៏យល់ស្របនឹងអ្នកគ្រូ មុំ ម៉េត ដែរ ហើយលើកទឹកចិត្តគ្រូបង្រៀនឲ្យប្រើប្រាស់តែវិធីសាស្ត្រខ្លះដូចជា ខិតប័ណ្ណ និងប្រអប់សង្គ្រោះជីវិត នៅពេលដែលសិស្សយល់ដឹងខ្លះពីមេរៀន ដើម្បីវាយតម្លៃទៅលើការយល់ដឹងរបស់សិស្សទៅលើសម្ភារៈ។

**ឌី ខាំបូលី គ្រូបង្រៀន និងអ្នកនិពន្ធប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បកស្រាយពី «កម្មវិធីឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងគុណភាពបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»**

បន្ទាប់មក ឌី ខាំបូលី និយាយអំពីកម្មវិធីវាយតម្លៃទៅលើគុណភាពបង្រៀនដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំនឹងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០១១។ ការគ្រប់គ្រងគុណភាព



លោក ឌី ខាំបូលី និង កញ្ញា ស៊ូ ហ្សារីណា និយាយទៅកាន់លោកគ្រូ-អ្នកគ្រូ

បង្រៀននឹងវាយតម្លៃទៅលើប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាល និងបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងថ្នាក់រៀន។ មានហេតុផលពីរដែលជំរុញឲ្យមានការគ្រប់គ្រងគុណភាពបង្រៀន។ ដូចដែល ឌី ខាំបូលី បានបកស្រាយ គ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលពេញលេញ «មិនត្រឹមតែមានការព្រួយបារម្ភពីបញ្ហាក្រមសីលធម៌ និងសង្គមដ៏ស្មុគស្មាញនៃការបង្រៀនប្រវត្តិ-សាស្ត្រប៉ុណ្ណោះទេ ថែមទាំងបារម្ភពីសមត្ថភាពរបស់ខ្លួនក្នុងការបង្រៀនឲ្យមានប្រសិទ្ធភាពទៀតផង»។ ស្រដៀងគ្នានេះដែរ ថ្នាក់ដឹកនាំក្រសួងអប់រំ មជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកជំនាញថ្នាក់ជាតិ និងអន្តរជាតិ និងអ្នកអប់រំដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាលបង្រៀនក៏ព្រួយបារម្ភពីបញ្ហានេះដែរ។ អាស្រ័យហេតុនេះ ការគ្រប់គ្រងគុណភាពបង្រៀនអាចជួយដោះស្រាយនូវការព្រួយបារម្ភទាំងនេះ អភិវឌ្ឍសមត្ថភាព បង្រៀន និងបង្កើនភាពជឿជាក់ និងការទទួលខុសត្រូវរបស់គ្រូបង្រៀនទៅលើការអប់រំប្រវត្តិសាស្ត្រ។ ការវាយតម្លៃទៅលើគម្រោងក៏អាចធានាថា គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជានឹងសម្រេចបាន

តាមគោលដៅអប់រំរបស់គម្រោងនិងជំរុញឲ្យមានការផ្សះផ្សាជាតិ ។ បន្ទាប់មក ឌី ខាំបូលី បាននិយាយពីកម្មវិធីវាយតម្លៃការគ្រប់គ្រងគុណភាព ដោយបកស្រាយពីសម្ភារៈដែលប្រើប្រាស់សម្រាប់វាយតម្លៃ និងទស្សនៈវាយតម្លៃផ្សេងៗ ។

**វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា បកស្រាយពី «កម្មវិធីឆ្នាំ២០១១ សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន»**

វ៉ាន់ថាន់ ពៅដារ៉ា បកស្រាយពីផែនការយុត្តិសាស្ត្រសម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឆ្នាំ២០១១ ។ លោកបានប្រាប់គ្រូបង្រៀនពីអនុស្សរណៈយោគយល់គ្នាដែលចុះ



លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា

ហត្ថលេខាដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ ដែលបានរៀបរាប់លម្អិតនៅផ្នែកខាងលើនៃរបាយការណ៍នេះ ។ លោកបានពន្យល់ពីបញ្ហាគ្រប់គ្រងដែលពាក់ព័ន្ធនឹងពាក្យស្លោកអប់រំពីអំពើប្រល័យពូជសាសន៍ និងការចែកចាយសៀវភៅមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យបន្ថែមពីរសែនក្បាល និងវគ្គបណ្តុះបណ្តាល គ្រូបង្រៀនអក្សរសាស្ត្រ សីលធម៌ ពលរដ្ឋវិជ្ជា និងប្រវត្តិសាស្ត្រ៩៤០នាក់ នៅឆ្នាំ ២០១១ ។ លោក ដារ៉ា ក៏បានហៅឈ្មោះលោកគ្រូ-អ្នកគ្រូដែលត្រូវបានជ្រើសរើសសម្រាប់ការបណ្តុះបណ្តាលវគ្គ ក្រោយនៅភ្នំពេញ ខេត្តកណ្តាល កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ និងបាត់ដំបងសម្រាប់ឆ្នាំ២០១១ ។

**សូ ហ្វារីណា វាគ្មិន និងប្រធាន «គម្រោងប្រវត្តិសាស្ត្រចាមតាមរយៈការសួរនាំ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា**

កញ្ញា សូ ហ្វារីណា បានផ្តោតទៅលើដំណើរការនៃប្រវត្តិសាស្ត្រតាមរយៈការសួរនាំនៅសហគមន៍ចាមមូស្លីមនៅក្នុងកម្ពុជា ។ នៅពេលធ្វើបទបង្ហាញ កញ្ញា សូ ហ្វារីណា បានពិភាក្សាពីវិធីសាស្ត្រស្រាវជ្រាវក្នុងការប្រមូលសក្ខីកម្មពីមេដឹកនាំសាសនានិងចាមមូស្លីម ។ កញ្ញា ហ្វារីណា ក៏បានពិភាក្សាពីកិច្ចខំប្រឹងប្រែងរបស់គម្រោងដើម្បីជួបជាមួយយុវជនចាមមូស្លីមនិងមធ្យោបាយដែលក្មេងជំនាន់ក្រោយអាចដើរតួនាទីដ៏សំខាន់ក្នុងការចងក្រងប្រវត្តិសាស្ត្រខ្មែរក្រហម ខណៈពេលដែលអ្នកទាំងនោះទទួលឥទ្ធិពលដោយផ្ទាល់ពីកេរដំណែលចម្រុះជាច្រើនជំនាន់ ។ ជាឧទាហរណ៍ កញ្ញា ហ្វារីណា បានពិភាក្សាពីការប្រកួតក្នុងការសរសេរអត្ថបទដែលខ្លួនបានរៀបចំនៅឆ្នាំ២០០៥ គឺឲ្យយុវជនចាមមូស្លីមសម្ភាសឪពុកម្តាយរបស់ខ្លួនទាក់ទងនឹងបទពិសោធន៍របស់គាត់នៅក្នុងរបបខ្មែរក្រហម ។ យោងទៅតាមកញ្ញា ហ្វារីណា បានឲ្យដឹងថាការប្រកួតប្រជែងក្នុងសរសេរអត្ថបទនេះអាច «បង្ហាញពីសារសំខាន់នៃប្រវត្តិសាស្ត្រតាមរយៈការសួរនាំតាមពីរវិធី គឺការអប់រំ និងការបង្កើតទំនាក់ទំនង» ។ ការងាររបស់ កញ្ញា ហ្វារីណា ដើរស្រប នឹងទស្សនៈនៃគណៈកម្មការស្វែងរកការពិត «ទឹកដីនៃការផ្សះផ្សា» ដែរ ។ ជាក់ស្តែង ការងាររបស់កញ្ញា ហ្វារីណា ជាមួយនឹងចាមមូស្លីមគឺមានជាប់ពាក់ព័ន្ធនឹងគម្រោង «ប្រវត្តិសាស្ត្រភូមិយើង» ដែលបានគ្រោងទុក ពីព្រោះគម្រោងទាំងពីរសុទ្ធតែមានបំណងរក្សា និងចងក្រងប្រវត្តិសាស្ត្រ ។ ជាក់ស្តែង កញ្ញា ហ្វារីណា បានសង្កត់ធ្ងន់ទៅលើតួនាទីដ៏សំខាន់នៃសក្ខីកម្មនិងសកម្មភាពឆ្ពោះទៅកិច្ចខំប្រឹងប្រែងផ្សះផ្សាធំជាងនេះ ។ យោងទៅតាមបទបង្ហាញរបស់ កញ្ញា ហ្វារីណា បានឲ្យដឹងថា បញ្ញវន្ត និងប្រវត្តិវិទូខ្លះបានសួរនាំពីសក្ខីកម្មរបស់អ្នករស់រានមានជីវិតដើម្បីផ្តល់នូវប្រវត្តិ «ពិត» និង «ត្រឹមត្រូវ» ប៉ុន្តែ កញ្ញា ហ្វារីណា បានសង្កត់ធ្ងន់ពីសារសំខាន់នៃការប្រាប់ និងស្តាប់រឿងរ៉ាវរបស់អ្នកនៅរស់ ទោះបីជាមានដែនកំណត់ «ប្រវត្តិ-

សាស្ត្រ» ក៏ដោយ ។ ដូចដែលកញ្ញាបានបកស្រាយថា «តាមរយៈការលើកទឹកចិត្តអ្នករស់រានមានជីវិតឲ្យនិយាយ ការស្តាប់រឿងរ៉ាវរបស់អ្នកទាំងនោះដោយយកចិត្តទុកដាក់ និងការធ្វើឲ្យអ្នកទាំងនោះដឹងពីអំណាចនៃប្រវត្តិរបស់ខ្លួនឯង យើងប្រហែលជាអាចជួយអ្នកទាំងនោះទម្លាយភាពស្ងៀមស្ងាត់ ហើយការចងចាំរបស់អ្នកទាំងនោះនឹងមានគេជឿ ហើយវានឹងមិនត្រូវបានគេបំភ្លេចចោល ។ អាស្រ័យហេតុនេះ កិច្ចខំប្រឹងប្រែងនេះចាំបាច់ត្រូវតែបន្តអប់រំក្មេងជំនាន់ក្រោយក្នុងគោលបំណងទប់ស្កាត់អំពើប្រល័យពូជសាសន៍ អប់រំ និងការចងចាំ ព្រមទាំងធ្វើឲ្យប្រជាធិបតេយ្យនៅប្រទេសកម្ពុជាកាន់តែរឹងមាំជាងមុន ។

**ភាពខ្លាំង**

ការសាកល្បងផ្នែកមួយនៃគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជាតិដែលត្រូវបានស្នើភាពខ្លាំងបំផុតមួយនៃសិក្ខាសាលានេះគឺថាវាអាចផ្តល់ឱកាសឲ្យអ្នកគ្រប់គ្រងគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាអាចសាកល្បងប្រើប្រាស់ផែនការសម្រាប់គណៈកម្មការស្វែងរកពិត និងផ្សះផ្សា ។ សិក្ខាសាលាបានផ្តល់ឱកាសសម្រាប់ «សាកល្បង» និងពិសោធន៍ទៅលើគំនិតជាច្រើនមុននឹងបង្កើតជាអនុសាសន៍គោលនយោបាយ និងការអនុវត្តគំនិតនោះឲ្យទៅជាទ្រង់ទ្រាយកម្រិតជាតិ ។ ជាឧទាហរណ៍ «ទឹកដីនៃការផ្សះផ្សា» ពង្រីកឱកាសឲ្យគ្រូបង្រៀនថ្នាក់ខេត្តដែលមកពីគ្រប់ស្រុកធ្វើការស្រាវជ្រាវពីសិស្ស និងផ្ញើអត្ថបទចំនួនបីដែលមានចំនួន១០-២០ទំព័រដែលអាចបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ ។ ជាផ្នែកមួយនៃ «ទឹកដីនៃការផ្សះផ្សា» ជារៀងរាល់ឆ្នាំនឹងមានការប្រមូលតែងសេចក្តីចំនួន៥៤០ច្បាប់ ហើយនិងមានការបោះពុម្ពជាសៀវភៅ និងចែកចាយទូទាំងប្រទេសដើម្បីបំពេញបន្ថែមទៅលើសម្ភាររបស់កម្មវិធីអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជា ។ អាស្រ័យហេតុនេះ ដូចដែលបានកត់សម្គាល់នៅខាងលើ គម្រោងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជាតម្រូវឲ្យសិក្ខាកាមក្នុងសិក្ខាសិលានៅព្រះវិហារទាំងអស់ធ្វើការស្រាវជ្រាវ និងផ្ញើអត្ថបទដែលពាក់ព័ន្ធនឹងភូមិដែលខ្លួនបង្រៀនចំនួន១០-២០ទំព័រ ។ ការធ្វើបែបនេះអនុញ្ញាតឲ្យអ្នករៀបចំអាចវាយតម្លៃពីភាពជោគជ័យនៃផែនការ



ព្រះសង្ឃនៅប្រាសាទព្រះវិហារ

ព្រមទាំងយល់ដឹងកាន់តែច្រើនពីទុក្ខលំបាកនិងភាពខ្លោចផ្សារដែលបានប្រឈមមុខទាក់ទងនឹងអ្វីដែលត្រូវបានស្នើឡើង ។ ស្រដៀងគ្នានេះដែរ គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាក៏បានសួរយោបល់របស់គ្រូបង្រៀនស្តីពីការផ្សះផ្សាជាតិ និងតួនាទីក្នុងដំណើរការដែលអនុញ្ញាតឲ្យអ្នកគ្រប់គ្រងគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាដឹងថាតើទស្សនៈរបស់ខ្លួនត្រូវបានប្រជាជនគាំទ្រយ៉ាងណា «នៅតាមមូលដ្ឋានផ្ទាល់» ។ កិច្ចការរបស់គម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាតាមទស្សនវិស័យដែលបានស្នើទុកគឺជាយុត្តិសាស្ត្រដ៏មានប្រសិទ្ធភាពមួយ ហើយទស្សនវិស័យនេះគួរតែយកទៅប្រើប្រាស់នៅក្នុងសិក្ខាសាលានៅពេលអនាគត ។

## កម្រងសំណួរស្តីពីគណៈកម្មការស្វែងរកការពិត

នៅពេលដែលសកម្មភាពរបស់សិក្ខាសាលាបានបញ្ចប់ទៅ សិក្ខាកាមទាំងអស់ត្រូវបានស្នើឲ្យបង្ហាញពីការយល់ឃើញរបស់ខ្លួនទៅលើគោលបំណង និងអត្ថន័យនៃ «គណៈកម្មការស្វែងរកការពិត និងផ្សះផ្សា» ហើយថាតើគេនឹងអនុវត្តគណៈកម្មការនេះនៅប្រទេសកម្ពុជាបានដោយរបៀបណា ។ កម្រងសំណួរបានស្នើឲ្យសិក្ខាកាមកំណត់និយមន័យគណៈកម្មការស្វែងរកការពិត ហើយចម្លើយភាគច្រើនបានឆ្លើយតបថា គណៈកម្មការស្វែងរកការពិតគឺជាយន្តការនៃយុត្តិធម៌អន្តរកាលមួយប្រភេទដែលមានសិទ្ធិនិងធ្វើការស៊ើបអង្កេត និងដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សកាលពីអតីតកាល ។ មានអ្នកខ្លះបានបកស្រាយថា តួនាទីរបស់គណៈកម្មការស្វែងរកពិតបន្ទាប់ពីការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ចប់ទៅគឺនឹងធ្វើការផ្សះផ្សា ចងក្រង និងរក្សាឯកសារពាក់ព័ន្ធនឹងខ្មែរក្រហម ចែកចាយព័ត៌មាន និងអប់រំក្មេងជំនាន់ក្រោយ ។ មានអ្នកខ្លះទៀតឆ្លើយតបថា គណៈកម្មការស្វែងរកការពិតនឹងដើរតួនាទីដ៏សំខាន់ក្នុងការជួយជនរងគ្រោះក្នុងការព្យាបាលរបួសផ្លូវចិត្តរបស់ខ្លួន ។ ក៏មានសំណួរខ្លះទៀតថាតើលោកគ្រូ-អ្នកគ្រូគិតថា បន្ទាប់ពីការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ចប់ គណៈកម្មការស្វែងរកការពិតមានសារសំខាន់ឬអត់ ហើយក៏មានសំណួរឲ្យពិភាក្សាពីតួនាទីឬការចូលរួមរបស់ជនដែលក្នុងគណៈកម្មការស្វែងរកការពិតនេះដែរ ។ ការឆ្លើយតប ភាគច្រើនបាននិយាយថា គណៈកម្មការស្វែងរការពិត បន្ទាប់ពីការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ចប់ទៅ មានសារសំខាន់ និងចាំបាច់ពីព្រោះវាអាចជួយជំរុញដល់កិច្ចខំប្រឹងប្រែងផ្សះផ្សាជួយឲ្យប្រជាជនកម្ពុជាបន្តស្រាវជ្រាវ និងចងក្រងការពិត និងកោតសរសើរដល់ដំណើរការនីតិវិធីច្បាប់នាបច្ចុប្បន្ន ។ លោកគ្រូ-អ្នកគ្រូផ្សេងទៀតក៏បានឆ្លើយតបថា តួនាទីរបស់ជនដែដល់នៅក្នុងដំណើរការគណៈកម្មការស្វែងរកការពិតគឺមានភាពចាំបាច់ណាស់ ។ គ្រូបង្រៀនម្នាក់បានឆ្លើយថា «វានឹងមិនមានការផ្សះផ្សាទេ ប្រសិនបើមិនមានការរួមបញ្ចូលជនដែដល់នៅក្នុងដំណើរការនេះ» ។ ការឆ្លើយតបរបស់គ្រូខ្លះផ្សេងទៀតគឺថា តួនាទីមួយរបស់គណៈកម្មការស្វែងរកការពិតគឺត្រូវធ្វើការជាមួយជនដែដល់ដោយមធ្យោបាយទទួលខុសត្រូវ ។ គ្រូបង្រៀនផ្សេងទៀតឆ្លើយតបថា គួរតែ «លើកទឹកចិត្តជនដែដល់ឲ្យនិយាយ» ដោយ «ធានានូវសុវត្ថិភាពរបស់



លោកគ្រូ ប៉ិច សៀកឡេង នៅក្នុងកម្មវិធីប្រជុំប្រចាំឆ្នាំនៅព្រះវិហារ

អ្នកទាំងនោះ» និងមិន «រើសអើងអ្នកទាំងនោះ» ។ កម្រងសំណួរក៏បានផ្តល់ឱកាសឲ្យគ្រូបង្រៀនផ្តល់អនុសាសន៍ដល់គណៈកម្មការស្វែងរកការពិតនៅកម្ពុជាដែរ ។ លោកគ្រូ-អ្នកគ្រូខ្លះបានផ្តល់អនុសាសន៍ឲ្យប្រើប្រាស់សិល្បៈដើម្បីបន្ថែមលើដំណើរការផ្សះផ្សា និងជំរុញឲ្យមានការផ្លាស់ប្តូរយោបល់ដោយបង្កើតប្រអប់ផ្តល់មតិមួយដោយដាក់នៅក្នុងទីរួមខេត្តសម្រាប់ឲ្យអ្នកភូមិចែករំលែករឿងរ៉ាវ ឬសំឡេងរបស់ខ្លួន ។

អ្នកដទៃទៀតដែលបានបង្ហាញពីតម្លៃរបស់ខ្លួននៅក្នុងកិច្ចប្រឹងប្រែងទាំងនេះក៏បានបង្ហាញពីអារម្មណ៍បែបនេះដែរ ។ ស្រដៀងគ្នានេះដែរ លោក ឆាំង យុ បានសង្កត់ធ្ងន់ទៅលើមធ្យោបាយដែលនាំឲ្យកិច្ចខំប្រឹងប្រែងរបស់គ្រូបង្រៀនអាចឈានទៅដល់កម្រិតអន្តរជាតិ និងជះឥទ្ធិពលដល់សកលលោកទាំងមូល ។ ការសង្កត់ធ្ងន់ទៅលើការរួមចំណែកដែលអាចយកធ្វើជាគំរូបានរបស់គ្រូបង្រៀនដើម្បីចែករំលែកដល់ពិភពលោក អាចលើកទឹកចិត្តគ្រូ


ប្រាសាទព្រះវិហារ

## ការសង្កត់ធ្ងន់របស់អ្នកផ្តល់បទបង្ហាញទៅលើសារសំខាន់របស់គ្រូបង្រៀននៅក្នុងសង្គមកម្ពុជា

ការធ្វើបទបង្ហាញជាច្រើនធ្វើការលើកទឹកចិត្ត ជំរុញ និងបង្ហាញពីការពេញចិត្តទៅលើការងាររបស់គ្រូបង្រៀននៅក្នុងសង្គមកម្ពុជា ដែលអាចជំរុញឲ្យសិក្ខាកាមបង្កើនការឲ្យតម្លៃលើខ្លួនឯង និងបន្តចាប់អារម្មណ៍ជានិរន្តភាពទៅលើគម្រោងនេះ ។ ជាឧទាហរណ៍ លោកជំទាវ ទន់ សាអ៊ីម និងលោក ឆាំង យុ បានមានប្រសាសន៍លើកទឹកចិត្តដោយសង្កត់ធ្ងន់ទៅលើតួនាទីដ៏សំខាន់របស់គ្រូបង្រៀននៅក្នុងការផ្សះផ្សាជាតិ ។ ឃុត ឥន្ទុសេរី និង

បង្រៀនពីសារសំខាន់របស់ខ្លួនក្នុងការបន្តចូលរួមនៅក្នុងគម្រោងនេះ ។ ដូចគ្នានេះដែរ ប្រសាសន៍របស់លោកជំទាវ ទន់ សាអ៊ីម ក៏បានលើកទឹកចិត្តឲ្យគ្រូបង្រៀនយល់ពីតម្លៃរបស់ខ្លួនឯង និង «ឋានៈ» របស់ខ្លួននៅក្នុងសង្គមកម្ពុជា ។ លោកជំទាវបានពិភាក្សាពីការផ្លាស់ប្តូររវាងកិច្ចខំប្រឹងប្រែងរបស់គ្រូបង្រៀនជាមួយនឹងអ្នកគ្រប់គ្រងគម្រោងអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជានិងមន្ត្រីរដ្ឋាភិបាល ។ ការចូលរួមរបស់លោកជំទាវមានសារសំខាន់ពិសេសមួយនៅក្នុងសង្គមកម្ពុជានិងដើរតួនាទីក្នុងយុត្តិសាស្ត្រលើកទឹកចិត្តដ៏មានប្រសិទ្ធភាពមួយ ពីព្រោះកិច្ចការនេះបានលើក

កម្ពស់ឋានៈរបស់គ្រូបង្រៀនឲ្យស្មើទៅនឹងមន្ត្រីរដ្ឋាភិបាលមួយចំនួន និងអ្នកសំខាន់ផ្សេងទៀត ។

## ការជ្រើសរើសកន្លែងបណ្តុះបណ្តាល

ការរៀបចំវគ្គសិក្ខាសាលាប្រចាំឆ្នាំនៅក្នុងទីតាំងផ្សេងគ្នានៅក្នុងប្រទេសគឺជាយុត្តិសាស្ត្រដ៏មានប្រសិទ្ធភាពមួយដែលអាចបង្កើនតម្លៃជាតិ បង្កើនការពេញចិត្តពីសំណាក់លោកគ្រូ-អ្នកគ្រូ និងពង្រីកទស្សនៈរបស់គម្រោងឲ្យទៅដល់ចំណុចជាក់លាក់ដែលអាចមើលឃើញ ។ ទោះបីជាមានទីតាំងខុសគ្នាក៏ដោយ ក៏លោកគ្រូ-អ្នកគ្រូនៅតែត្រៀមខ្លួនរួចជាស្រេចនឹងអាចចូលរួមក្នុងសន្និសីទដោយសារតែយុត្តិសាស្ត្ររបស់អ្នកគ្រប់គ្រងគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាបានធានានូវការធ្វើដំណើរនិងផ្តល់ថវិកាចំណាយបន្តិចបន្តួចដល់លោកគ្រូ-អ្នកគ្រូទាំងអស់ ។ ដូចដែលកត់សម្គាល់នៅខាងលើរួចមកហើយ ប្រាសាទព្រះវិហារមានលក្ខណៈពិសេសមួយនៅក្នុងស្មារតីចងចាំរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្ន ហើយគឺជាទីតាំងដ៏មានប្រសិទ្ធភាពសម្រាប់វគ្គសិក្ខាសាលានេះ ពីព្រោះទីតាំងនេះមានជាប់ពាក់ព័ន្ធជាពិសេសទៅនឹងគោលដៅនៃសិក្ខាសាលាគឺ «ការចងក្រងប្រវត្តិសាស្ត្រ» ។ ដូចគ្នានេះដែរ ទីតាំងនេះមានជាប់ពាក់ព័ន្ធនឹងទស្សនវិស័យនៃ «ទឹកដីនៃការផ្សះផ្សា» ។ នៅពេលដែលលោកគ្រូ-អ្នកគ្រូបានធ្វើដំណើរនៅលើផ្លូវដែលទើបតែជួសជុលរួច លោកគ្រូ-អ្នកគ្រូទាំងអស់រួមគ្នាជាមួយនឹងក្រុមការងារបានទទួលប្រសិទ្ធពរជ័យពីព្រះសង្ឃអុជធូបដើម្បីរំឭកដល់អ្នកដែលបានស្លាប់ និងអង្គុយស្ងឹងស្ងាធិ៍ជាមួយគ្នាដោយនឹកគិតដល់ប្រវត្តិសាស្ត្រដ៏ឈឺចាប់ និងយូរអង្វែងរបស់ព្រះវិហារនៅពេលនោះ ។ ដោយបានថតរូបនៅពីមុខស្លាកសញ្ញាដែលមានសារសរសេរថា «ខ្ញុំមានមោទកភាពដែលបានកើតជាខ្មែរ» និងអង្គុយហូបបាយជាមួយគ្នានៅលើកំពូលភ្នំ លោកគ្រូ-អ្នកគ្រូអាចប្រែក្លាយទីតាំងដែលធ្លាប់មានជម្លោះទៅជាទីតាំងមួយដែលមានភាពសុខសាន្ត សន្តិភាព និងមោទកភាព ។ នៅពេលជាមួយគ្នានោះដែរ ការរៀបចំវគ្គសិក្ខាសាលានៅទីតាំងផ្សេងៗគ្នានៅក្នុងប្រទេសក៏អាចផ្តល់នូវវេទិកាមួយសម្រាប់ពិភាក្សាបញ្ហាអប់រំបច្ចុប្បន្ននៅតាមទីតាំងនៃវគ្គសក្ខាសាលានីមួយៗដែរ ។ ជាឧទាហរណ៍ លោកជិទាវ ទន់ សាអ៊ីម ប្រើប្រាស់ទីតាំងសិក្ខាសាលានៅព្រះវិហារដើម្បីលើកឡើងពីបញ្ហាអប់រំនៅព្រះវិហារ ជាពិសេសទាក់ទងនឹងជនជាតិភាគតិចក្នុយ៧០ភាគរយនៅក្នុងខេត្តនេះ ។ ជាពិសេសលោកជិទាវបានបង្ហាញពីបញ្ហាដែលគ្រូបង្រៀនបានជួបប្រទះនៅពេលដែលគ្រូបង្រៀនទាំងនោះព្យាយាមធ្វើឲ្យមានសមតុល្យរវាងប្រជាជនកម្ពុជា និងជនជាតិភាគតិចនៅសាលារៀន ។ ការពិភាក្សាបែបនេះមិនត្រឹមតែផ្តល់វេទិកាពិភាក្សាដើម្បីស្វែងយល់ពីបញ្ហាដែលកំពុងប្រឈមមុខនៅព្រះវិហារទេ តែថែមទាំងអាចស្វែងយល់ពីបញ្ហាដែលគ្រូបង្រៀនជួបប្រទះនៅសាលារៀននៅក្នុងស្រុកផ្សេងៗដែរ ។ ស្រដៀងគ្នានេះដែរ លោក ស៊ុយ សេរិទ្ធិ បានពិភាក្សាពីបញ្ហាអប់រំ និងសេដ្ឋកិច្ចនៅព្រះវិហារដែលអាចឲ្យសិក្ខាកាមដឹងពីបញ្ហាលំបាកបច្ចុប្បន្ននៅតំបន់ផ្សេងនៅប្រទេសកម្ពុជា ។

## សន្និសីទបានផ្តល់ឱកាសឲ្យគ្រូបង្រៀនបង្ហាញពីការព្រួយបារម្ភ លើកសំណួរអំពីវិធីសាស្ត្របង្រៀន និងទទួលការបណ្តុះបណ្តាលដែលអាចអភិវឌ្ឍវិជ្ជាជីវៈ

សិក្ខាសាលាផ្តល់ឱកាសឲ្យគ្រូបង្រៀនបង្ហាញពីការព្រួយបារម្ភ និងបញ្ជាក់បន្ថែមពីចំណុចនៅក្នុងសៀវភៅណែនាំគ្រូបង្រៀន និងសៀវភៅមេរៀន ។ ដោយសារគ្រូបង្រៀនមិនដែលបានជួបគ្នាជាក្រុមតាំងពីខែមេសា ឆ្នាំ២០១០មក ដូច្នេះសិក្ខាសាលានេះអនុញ្ញាតឲ្យលោកគ្រូ-អ្នកគ្រូលើកឡើងនូវសំណួរដែលខ្លួនជួបប្រទះនៅពេលបណ្តុះបណ្តាលគ្រូដទៃទៀត ។ អាស្រ័យហេតុនេះ សិក្ខាកាមក្នុងសិក្ខាសាលានៅព្រះវិហារបានសួរសំណួរ និងសួរបញ្ជាក់បន្ថែមពីវិធីសាស្ត្រគំរូលើតារាង *K-W-L* សកម្មភាព «*Jigsaw*» និងខិតប័ណ្ណនយោបាយបរទេសនៅពេលធ្វើសកម្មភាពបង្រៀន ។ មានការចំណាយពេលវេលាជាច្រើនទៅលើសំណួរទាំងនេះ ហើយបញ្ហាទាំងនេះគឺជាធាតុផ្សំដ៏មានសារសំខាន់ ហើយមានប្រយោជន៍សម្រាប់គ្រូបង្រៀនដែលនឹងចូលរួមជាអ្នកបណ្តុះបណ្តាលនៅក្នុងការបណ្តុះបណ្តាលនៅកម្រិតមូលដ្ឋានបន្តទៀត ។

## ឥរិយាបថវិជ្ជមានរបស់សិក្ខាកាម

សិក្ខាកាមបន្តបង្ហាញឥរិយាបថវិជ្ជមានចំពោះសិក្ខាសាលា និងបានបំពេញតម្រូវការមុនពេលសិក្ខាសាលា ។ នៅអំឡុងពេល

សិក្ខាសាលា លោកគ្រូ-អ្នកគ្រូចង់រួមចំណែកក្នុងការពិភាក្សា និងសកម្មភាពផ្សេងៗ ។ ទោះបីជាបន្ទប់សន្និសីទមានស្ថានភាពមិនសូវល្អ ក៏លោកគ្រូ-អ្នកគ្រូតែងតែយកចិត្តទុកដាក់ស្តាប់វាគ្មិននិងចូលរួមដោយឥរិយាបថវិជ្ជមានដែរ ។ តាមរយៈរឿងរ៉ាវចំនួន ២០០ដែលប្រមូលបាននៅមុនធ្វើសិក្ខាសាលា បានបង្ហាញថា សិក្ខាកាមក៏យល់ និងត្រៀមខ្លួនរួមចំណែកក្នុងគម្រោងនេះដែរ ។ ភាពវិជ្ជមានបែបនេះដើរតួនាទីយ៉ាងសំខាន់ពីភាពជោគជ័យរបស់សិក្ខាសាលា និងធ្វើឲ្យលោកគ្រូ-អ្នកគ្រូអាចរួមចំណែកក្នុងការដឹកនាំកិច្ចខំប្រឹងប្រែងផ្សះផ្សាជាតិ ។

**កិច្ចប្រជុំប្រចាំឆ្នាំបង្កើនការរាប់អានគ្នារវាងគ្រូនិងគ្រូ រក្សានិងបង្កើនចំណាប់អារម្មណ៍លើគម្រោង និងផ្តល់ឱកាសសម្រាប់អភិវឌ្ឍការអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

កិច្ចប្រជុំប្រចាំឆ្នាំបង្កើនការរាប់អានគ្នារបស់គ្រូបង្រៀន និងជួយរក្សាចំណាប់អារម្មណ៍របស់គ្រូទៅលើគម្រោងនេះ ។ ដូចដែលគ្រូបង្រៀនជាច្រើន និងអ្នកគ្រប់គ្រងគម្រោងអប់រំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅកម្ពុជាមិនបានជួបមុខគ្នាតាំងពីសិក្ខាសាលាបណ្តុះបណ្តាលប្រចាំឆ្នាំនៅខែមេសា ឆ្នាំ ២០១០ សិក្ខាកាមមានភាពរីករាយដែលបានជួបមុខគ្នានិងជួបជុំគ្នាម្តងទៀត ។ ដូចគ្នានេះដែរ កិច្ចប្រជុំប្រចាំឆ្នាំក៏បានផ្តល់ឱកាសឲ្យវាគ្មិនបញ្ជាក់ម្តងទៀតពីសារសំខាន់របស់គម្រោង និងសារសំខាន់របស់គ្រូបង្រៀននៅក្នុងគម្រោងនេះ ។ ប្រសាសន៍របស់លោកជទាវ ទន់ សាអ៊ីម លោក ឆាំង យុ និង លោកអភិបាលរងខេត្ត និងលោក យុត ឥន្ទុសេរី មានលក្ខណៈលើកទឹកចិត្តជាពិសេស និងធ្វើឲ្យលោគ្រូ-អ្នកគ្រូយល់ដឹងពីរូបភាព «ធំជាងនេះ» នៃការចូលរួមរបស់ខ្លួននៅក្នុងគម្រោង ។ ជាមួយគ្នានេះដែរ សិក្ខាសាលាក៏ផ្តល់ឱកាសឲ្យគ្រូបង្រៀនពង្រីកចំណេះដឹងរបស់ខ្លួនដែរ ។ ជាឧទាហរណ៍ ការពិភាក្សារបស់សាស្ត្រាចារ្យ ដួរ គិរី បានផ្តល់ការវិភាគដ៏មានផ្លែផ្កាទៅលើដើមកំណើតនៃពាក្យប្រល័យពូជសាសន៍ ហើយកញ្ញា សូ ហ្វារីណា ក៏បានបង្ហាញពីអង្គហេតុស្តីពីបទពិសោធន៍របស់ចាមមូស្លីមនៅក្នុងរបបខ្មែរក្រហមដែលលោកគ្រូ-អ្នកគ្រូខ្លះមិនធ្លាប់បានឆ្លងកាត់ដែរ ។ សិក្ខាសាលាប្រចាំឆ្នាំគឺជាវេទិកាពិភាក្សាដ៏មានប្រសិទ្ធភាពមួយដែលអាចបង្ហាញការអភិវឌ្ឍន៍ ការគ្រប់គ្រង ពិនិត្យទៅលើភាពខ្លាំង និងភាពខ្សោយក្នុងឆ្នាំនេះ និងផ្សព្វផ្សាយព័ត៌មានស្តីពីផែនការសកម្មភាពនៃឆ្នាំបន្ទាប់ ។ ជាឧទាហរណ៍ លោក គ្រីស្តូហ្វឺ ឌៀរីង និងអ្នកស្រី ស៊ុំ សារីណា បានបង្ហាញពីលទ្ធផលនៃការស្ទាបស្ទង់លើសិក្ខាសាលាបណ្តុះបណ្តាលវគ្គមុនៗដែលវាយតម្លៃលើភាពខ្លាំងរបស់គ្រូបង្រៀន និងចំណុចដែលត្រូវអភិវឌ្ឍបន្ថែម ។ នៅពេលជាមួយគ្នានេះដែរ លោក វ៉ាន់ថាន់ ពៅដារ៉ា និង ឌី ខាំបូលី បានលើកបង្ហាញពីទីតាំង និងពេលវេលាសម្រាប់ការបណ្តុះបណ្តាលវគ្គក្រោយគោលបំណងរបស់គម្រោងនៅឆ្នាំក្រោយ និងសេចក្តីលម្អិតអំពីកម្មវិធីគ្រប់គ្រងគុណភាព ។ ការចែកចាយព័ត៌មានទៅកាន់គ្រូបង្រៀនជាក្រុមអាចធានាថា គ្រូបង្រៀនទទួលព័ត៌មានដូចគ្នា និងពង្រឹងភាពខ្លាំងនៃគម្រោង ។

**សារ៉ា ចូនឌីកឃិន**



ប្រាសាទព្រះវិហារ

# ដំណើរជីវិតរបស់ សែ វួចនី




សែ វួចនី អាយុ៦១ឆ្នាំ មានមុខរបរជាអ្នកលក់ផ្លែឈើ ក្រុងភ្នំពេញ ។ វួចនី មានស្រុកកំណើតនៅភូមិព្រៃរំដេង ឃុំព្រៃរំដេង ស្រុកគិរីវង្ស ខេត្តតាកែវ ។ ដូចប្រជាជនកម្ពុជារាប់លាននាក់ដែលបានឆ្លងកាត់សម័យខ្មែរក្រហម វួចនី ក៏ធ្លាប់ទទួលរងការឈឺចាប់និងបាត់បង់សាច់ញាតិនៅក្នុងរបបនោះដែរ ។

ដំបូងឡើយ វួចនី រស់នៅភូមិកំណើតជាមួយឪពុកម្តាយដោយប្រកបរបរកសិកម្ម ។ លុះក្រោយពីគាត់បានរៀបការជាមួយបុរសម្នាក់រួចមក គាត់និងប្តីក៏ប្តូរមករស់នៅក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញវិញ ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វួចនី និងគ្រួសារត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើដំណើរទៅទិសខាងត្បូងដោយប្រាប់ថា «ដើរទៅរហូតមិនត្រូវងាកក្រោយទេ បីថ្ងៃទៀតទើបឲ្យត្រឡប់មកវិញ» ។ ធ្វើដំណើរជាច្រើនថ្ងៃ គ្រួសាររបស់ វួចនី ក៏បានមកដល់ស្រុកគិរីវង្សដែលជាស្រុកកំណើត ។ ប្រហែលមួយសប្តាហ៍ក្រោយមក កម្មាភិបាលខ្មែរក្រហមបានបែកចែកប្រជាជនជាក្រុមៗ រួចចាត់តាំងឲ្យគាត់លើកទំនប់និងជីកប្រលាយ ។ ដោយសារតែខ្វះកន្លែងស្នាក់នៅ អង្គការបានអនុញ្ញាតឲ្យគាត់រស់នៅជាមួយឪពុកម្តាយគាត់បណ្តោះអាសន្នសិន ។ ប៉ុន្តែប្រហែលជាពីរសប្តាហ៍ក្រោយមកទៀតអង្គការបានសង់ខ្ទមជាច្រើនរួចបញ្ជូនគាត់ឲ្យទៅរស់ក្នុងខ្ទមតូចមួយជាមួយសមាជិកផ្សេងទៀតនៅក្នុងកងជាមួយគ្នា ។ កម្មាភិបាលខ្មែរក្រហមបានចាត់តាំងឲ្យ វួចនី ចេញទៅធ្វើស្រែតាំងពីព្រលឹមរហូតដល់ព្រលប់ទើបអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។ ចំណែកការហូបចុកវិញមិនគ្រប់គ្រាន់ទេ ។ វួចនី បានរៀបរាប់ថា «របបបបរដែលគេចែកឲ្យតិចណាស់ សូម្បីតែក្មេងក៏ហូបមិនឆ្អែតផង ព្រោះម្នាក់ៗទទួលបានតែបបរមួយវែកប៉ុណ្ណោះ» ។

ធ្វើការបានមួយរយៈ អង្គការបានផ្លាស់ វួចនី ឲ្យទៅធ្វើការនៅភូមិបួរ ឃុំព្រៃរំដេងវិញ ។ នៅទីនោះអង្គការចាត់តាំងឲ្យគាត់ជីកប្រលាយនិងលើកទំនប់ដូចមុនដដែល ។ ប៉ុន្តែដោយសារការខិតខំធ្វើការខ្លាំងពេក សុខភាពរបស់គាត់កាន់តែទ្រុឌទ្រោមទៅៗ ហើយថែមទាំងមានជំងឺជាញឹកញាប់ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏គាត់មិនហ៊ានសុំច្បាប់ឈប់សម្រាកដែរ ព្រោះខ្លាចប្រធានកងចោទប្រកាន់ថាធ្វើពុតជាឈឺ ។ វួចនី បានរៀបរាប់ទាំងអួលដើមកថា «ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំឃើញតែមនុស្សស្លាប់ដោយសារជំងឺនិងគ្មានអាហារហូបដោយក្នុងនោះក៏មានបងប្អូនបង្កើតរបស់ខ្ញុំពីរនាក់ដែរ» ។ លើសពីនេះទៅទៀត ការរស់នៅគឺស្ថិតនៅក្នុងភាពភ័យខ្លាចរហូតដោយសារតែព្រួយបារម្ភខ្លាចអង្គការចោទប្រកាន់ថាក្បត់ ។ ជាក់ស្តែង វួចនី បានបាត់បង់បងប្អូនជីដូនមួយប្រាំមួយនាក់ដែលកាលនោះកម្មាភិបាលប្រាប់ថាយកទៅរៀនសូត្រ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកក៏ឃើញយកសម្លៀកបំពាក់អ្នកទាំងនោះត្រឡប់មកវិញ ។ ពេលនោះ វួចនី ដឹងច្បាស់ថាបងប្អូនជីដូនមួយរបស់គាត់ជាអង្គការយកទៅសម្លាប់បាត់ហើយ ។

បន្ទាប់ពីរបបនេះដួលរលំនៅឆ្នាំ១៩៧៩ វួចនី និងក្រុមគ្រួសារក៏នាំគ្នាត្រឡប់មករស់នៅក្នុងសង្កាត់បឹងទំពុន ខណ្ឌចំការមន រាជធានីភ្នំពេញរហូតដល់សព្វថ្ងៃនេះ ។

**លន់ ដាលីន**

## កម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរនឹងធ្វើការចាក់ផ្សាយកម្មវិធីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដែលនិពន្ធដោយ ឌី ខាំបូលី ដែលអ្នកទាំងអស់គ្នាអាចស្តាប់ផងចម្លងនិងអានសាច់រឿងដែលមាននៅក្នុងសៀវភៅនេះតាមរយៈគេហទំព័រ http://www.voanews.com/ khmer/democratic-kampuchea.cfm របស់វិទ្យុផ្សាយសំឡេងសហរដ្ឋអាមេរិកជាភាសាខ្មែរ ។ **មជ្ឈមណ្ឌលឯកសារកម្ពុជា**

# តើអ្វីជាអំពើប្រល័យពូជសាសន៍? តើអ្វីជាចំណុចខ្វះខាតនៅក្នុងអនុសញ្ញាអំពើប្រល័យពូជសាសន៍? តើត្រូវទប់ស្កាត់អំពើប្រល័យពូជសាសន៍ដោយរបៀបណា?

***(តចប់)***

*ដូចជានៅក្នុងខែកញ្ញា ឆ្នាំ២០០៥ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិបានធ្វើការសិក្សាមួយដើម្បីសម្រេចថាតើអំពើប្រល័យពូជសាសន៍មានបានប្រព្រឹត្តឡើងនៅដាហ្វ័រដែរឬយ៉ាងណា ។ លទ្ធផលនៃរបាយការណ៍ជំនាញមិនបានព្យាយាមដើម្បីកំណត់ថា ជនជាតិស៊ូដង់ណាម្នាក់បានសម្លាប់មនុស្សដោយមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ ។ តែរបាយការណ៍នោះបែរជាពិនិត្យទៅមើលលើគោលនយោបាយរបស់រដ្ឋាភិបាលស៊ូដង់ទៅវិញដោយអះអាងថា «គណៈកម្មាធិការធ្វើការសន្និដ្ឋានថា រដ្ឋាភិបាលស៊ូដង់មិនបានអនុវត្តនូវគោលនយោបាយប្រល័យពូជសាសន៍ទេ» ។ គណៈកម្មាធិការនេះបានបន្តថា គឺមានភ័ស្តុតាងនៃសមាសធាតុនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ចំនួនពីរ ។ ទីមួយ គឺវត្តមាននៃទង្វើជាក់ស្តែងដែលឆ្លើយតបទៅនឹងកថាខណ្ឌនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មនេះដែលមានចែងក្នុងមាត្រា២ នៃអនុសញ្ញាស្តីពីការការពារនិងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ។ គណៈកម្មាធិការនេះបានអង្កេតឃើញថា «ការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តឡើងដោយកងកម្លាំងនិងកងឈ្លប ដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល» ដែលក្នុងនោះរួមមានការរាយការណ៍ពីការសម្លាប់ ការបង្ករបួសស្នាមយ៉ាងធ្ងន់ធ្ងរលើរូបរាងកាយឬស្មារតី និងការបង្កឲ្យមានដោយចេតនានូវលក្ខខណ្ឌរស់នៅដែលនាំមកនូវការបំផ្លិចបំផ្លាញផ្នែករូបរាងកាយ ។ សមាសធាតុទីពីរគឺ ទស្សនៈដែលថាជនរងគ្រោះនិងជនដែលដល់ (ជនជាតិភាគតិចអាហ្វ្រិកនិងអារ៉ាប់) បានបង្កើតនូវក្រុមជាតិពន្ធពីរខុសគ្នា ។ ប៉ុន្តែ គណៈកម្មាធិការបាននិយាយថា «សមាសធាតុសំខាន់មួយហាក់បីដូចជាមិនឃើញនោះគឺចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ បើតាមដែលយើងគិតពីអំណាចរបស់រដ្ឋាភិបាលមជ្ឈិមនោះ» ។ បើនិយាយក្នុងន័យទូទៅ គោលនយោបាយនៃការវាយប្រហារ ការសម្លាប់ និងការបង្ខិតបង្ខំផ្លាស់ប្តូរទីកន្លែងរបស់សមាជិកនៃក្រុមជនជាតិភាគតិចខ្លះគឺ មិនបានបង្ហាញនូវចេតនាជាក់លាក់មួយក្នុងការបំផ្លាញឲ្យទាំងស្រុងឬដោយផ្នែកនូវក្រុមមនុស្សដែលបែងចែកតាមមូលដ្ឋាននៃជាតិសាសន៍ ជាតិពន្ធ ជាតិនិងសាសនានោះទេ ។*

*មាត្រា៣ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍បានចែងថា បន្ថែមទៅលើការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌសម្រាប់ជនដែលដល់ជាក់លាក់នៃអំពើឧក្រិដ្ឋកម្មនោះ ជនផ្សំគំនិតក៏ត្រូវផ្តន្ទាទោសដែរ ។ ការយកនូវទស្សនៈស្មុគស្មាញនេះដែលដកចេញពីច្បាប់ព្រហ្មទណ្ឌទូទៅមកប្រើក្នុងបរិបទនៃអំពើសាហាវឃោរឃៅអន្តរជាតិនេះគឺខ្វះនូវភាពជាក់លាក់ខ្លះៗ ។ ជាក់ស្តែង គឺអ្នករៀបចំនិងអ្នកញុះញង់ឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅវិញនោះទេដែលត្រូវទទួលខុសត្រូវធ្ងន់បំផុត ។ ទង្វើមកលើរូបរាងកាយត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលដែលមានឋានៈទាបហើយប្រហែលជាអ្នកដែលមិនបានដឹងពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទេ ។*

*លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានបង្កើតនូវបទបញ្ញត្តិសម្រាប់ធ្វើការកាត់ទោសមេបញ្ជាការឬថ្នាក់លើដែលទង្វើឧក្រិដ្ឋត្រូវបានប្រព្រឹត្តឡើងដោយកូនចៅឬថ្នាក់ក្រោមរបស់ខ្លួន បើទោះបីជាមិនមានភ័ស្តុតាងបញ្ជាក់ថា មានបញ្ជាឬទិសដៅជាក់លាក់ក៏ដោយ ។ វិធីសាស្ត្រក្នុងការដាក់ឲ្យទទួលខុសត្រូវនេះដែលដកចេញពីករណីសំណុំរឿងនៃសង្គ្រាមលោកលើកទីពីរត្រូវបានបង្ហាញឲ្យឃើញថា គ្រាន់តែជាការចាប់អារម្មណ៍ផ្នែកទ្រឹស្តីប៉ុណ្ណោះ ។ នៅក្នុងស្ថានភាពដែលថ្នាក់លើម្នាក់ត្រូវបានកាត់ឲ្យជាប់ទោសចំពោះការដែលមិនទប់ស្កាត់ថ្នាក់ក្រោមរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺជារឿងមួយដែលមិនគួរឲ្យជឿ*

នៅពេលដែលត្រូវបានគេយល់ឃើញថា នេះគឺជាឧក្រិដ្ឋកម្មដែលកើតចេញពីផែនការឬគោលនយោបាយរបស់រដ្ឋនោះ ។

ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិជាច្រើននាពេលបច្ចុប្បន្ននេះត្រូវបានយោងទៅតាមទ្រឹស្តីមួយ ដែលត្រូវបានស្គាល់ថា «សហកម្មឧក្រិដ្ឋកម្មរួម» ។ ទ្រឹស្តីនេះទទួលស្គាល់ថាបទល្មើសឃោរឃៅដែលត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មអន្តរជាតិដែលរួមទាំងបទអំពើប្រល័យពូជសាសន៍ផងនោះ គឺត្រូវបានប្រព្រឹត្តឡើងដោយក្រុមឬអង្គការដែលអនុវត្តឡើងដោយឈរលើគោលបំណងរួមមួយ ។ តាមការជាក់ស្តែងនេះគឺមានន័យថា មេដឹកនាំឬអ្នករៀបចំនឹងត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយសហការីរបស់ខ្លួន បើទោះបីជាពួកគេមិនមានចេតនាជាក់លាក់ណាក៏ដោយ ក៏ស្ថិតនៅក្នុងកម្រិតមួយដែលថា ទាំងនេះគឺជាលទ្ធផលដែលអាចទៅរួចនិងអាចព្យាករណ៍ទុកមុនបានដែលកើតចេញពីបំណងរួមឬសហកម្មរួមមួយនោះ ។

## ការទទួលខុសត្រូវរបស់រដ្ឋ

ទោះបីជានិយមន័យនៃអំពើប្រល័យពូជសាសន៍ត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មមួយ ដោយបង្កប់ន័យថាប្រើប្រាស់បានតែចំពោះបុគ្គលប៉ុណ្ណោះក៏ដោយ ក៏នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ បានដាក់តួនាទីមកលើរដ្ឋផងដែរដើម្បីការពារការកើតឡើងវិញនៃអំពើប្រល័យពូជសាសន៍និងគិតគូរយ៉ាងច្បាស់លាស់ពីការទទួលខុសត្រូវរបស់រដ្ឋនោះនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ។ មន្ទិលទាំងប៉ុន្មានទាក់ទងនឹងចំណុចនេះ គឺត្រូវបានដោះស្រាយនៅក្នុងសេចក្តីសម្រេចខែកុម្ភៈ ឆ្នាំ២០០៧ របស់តុលាការអន្តរជាតិ ។ នៅមានការជជែកពិភាក្សាជាបន្តបន្ទាប់នៅក្នុងចំណោមមេធាវីទាក់ទងនឹងបញ្ហាថា តើរដ្ឋពិតជាប្រព្រឹត្តឧក្រិដ្ឋកម្មមែនឬយ៉ាងណា ។ តុលាការនេះបានចៀសវាងសំណួរដែលចោទថាតើនេះអាចចាត់ទុកថាជាឧក្រិដ្ឋកម្មមួយឬក៏ជាទង្វើខុសឆ្គងអន្តរជាតិមួយឬយ៉ាងណា នៅពេលដែលតុលាការនេះបានសម្រេចថារដ្ឋាភិបាលសើប៊ីត្រូវទទួលខុសត្រូវចំពោះការមិនបានទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

តុលាការក៏បានយល់ឃើញថា នៅពេលដែលបទចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើង បទចោទនោះត្រូវតែកសាងឡើងដោយពឹងលើភស្តុតាង «ដែលបង្ហាញពីភាពច្បាស់លាស់ កម្រិតខ្ពស់មួយសមស្របទៅនឹងភាពធ្ងន់ធ្ងរនៃការចោទប្រកាន់នោះ» ។ នេះគឺជាបទដ្ឋានដែលទាមទារគួរឲ្យកត់សម្គាល់មួយជាងអ្វីដែលតែងតែត្រូវបានយកមកប្រើប្រាស់នៅក្នុងករណីធម្មតាដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ហើយនេះហាក់បីដូចជាធ្វើឲ្យមានលក្ខណៈប្រហាក់ប្រហែលទៅនឹងបទដ្ឋានដែលត្រូវបានយកមកអនុវត្តនៅក្នុងការកាត់ទោសចំពោះឧក្រិដ្ឋកម្មទាំងឡាយ ។ ឧទាហរណ៍ លក្ខន្តិកៈទីក្រុងរ៉ូមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានចែងថា «ដើម្បីធ្វើការកាត់ទោសជនជាប់ចោទឲ្យមានទោស បានតុលាការត្រូវតែច្បាស់លាស់ពីពិរុទ្ធភាពរបស់ជនជាប់ចោទឲ្យលើសពីការសង្ស័យដែលសមហេតុផលនោះ» ។ ក្នុងការអនុម័តវិធីសាស្ត្រនេះ តុលាការយុត្តិធម៌អន្តរជាតិបានកាត់បន្ថយនូវភាពដែលអាចកើតឡើងនៃលទ្ធផលមួយដែលមិនស៊ីសង្វាក់គ្នាទៅនឹងវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ បទដ្ឋាននៃភស្តុតាងដ៏តឹងរ៉ឹងនេះទាក់ទងនឹងករណីអំពើប្រល័យពូជសាសន៍បានធានាឲ្យច្បាស់ថាតុលាការយុត្តិធម៌អន្តរជាតិដែលដោះស្រាយជាមួយនឹងបញ្ហានៃការទទួលខុសត្រូវរបស់រដ្ឋ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលដោះស្រាយជាមួយនឹងបញ្ហាការទទួលខុសត្រូវរបស់បុគ្គល គឺនៅតែមានទស្សនៈយល់ឃើញដូចគ្នាដដែល ។

## សេចក្តីបញ្ចប់

អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នៅតែបន្តធ្វើឲ្យអ្នកជំនាញច្បាប់ អ្នកនយោបាយ អ្នកយកព័ត៌មាន និងសកម្មជនសិទ្ធិមនុស្សទាំងអស់មានការចាប់អារម្មណ៍ដូចគ្នា ។ ក្នុងអំឡុងពេលហាសិបឆ្នាំនេះ អនុសញ្ញានេះនៅតែស្ថិតនៅក្នុងស្ថានភាពតានតឹងជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជដែល ។ ឃើញថាមានការមិនពេញចិត្តជាខ្លាំងទៅនឹងភាពចង្អៀតចង្អល់នៃនិយមន័យពាក្យប្រល័យពូជសាសន៍ ។ លោក ចច ស្តុវ៉ាហ្សេនបើហ្គឺ បានធ្វើការកត់សម្គាល់ថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍គឺ «មិនចាំបាច់នោះទេនៅពេលដែលអាចយកមកអនុវត្តបាន តែមិនអាចអនុវត្តបានទេនៅពេលដែលចាំបាច់នោះ» ។ លោក ហ្វ្រេង

ឆក និង លោក យើត ចនសាន់សួញ បានសរសេរថា «ពាក្យពេចន៍ដែលប្រើប្រាស់នៅក្នុងអនុសញ្ញានោះគឺពិតជាមានលក្ខណៈរិតត្បិតខ្លាំងណាស់រហូតទាល់តែមិនមានការសម្លាប់ប្រល័យពូជសាសន៍ណាមួយដែលប្រព្រឹត្តឡើងចាប់តាំងពីពេលដែលអនុសញ្ញានោះត្រូវបានអនុម័ត» ។ អាស្រ័យហេតុនេះ មានមនុស្សជាច្រើនបានទាមទារឲ្យមានការបកស្រាយបែបទូលំទូលាយទាក់ទងនឹងទស្សនៈស្តីពីអំពើប្រល័យពូជសាសន៍ដែលអាចរួមបញ្ចូលទាំងក្រុមទទួលបានការការពារផ្សេងទៀត ដូចជាក្រុមនយោបាយនិងសង្គម ហើយដែលអាចអនុវត្តន៍មកលើបទល្មើសផ្សេងៗទៀតដែលទូលំទូលាយជាងនេះ ។ ប៉ុន្តែតាមការជាក់ស្តែង អ្វីដែលអ្នកទាំងនោះធ្វើការស្នើសុំគឺមានន័យស្មើទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមិនមានជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ។

នៅដើមឆ្នាំ១៩៨៥ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍គឺមិនមែនកើតមកពីប្រភពតែមួយនោះទេ ហើយពាក្យនេះបង្កើតឡើងដើម្បីធ្វើការពិពណ៌នាពីបទល្មើសដ៏ឃោរឃៅព្រៃផ្សៃរបស់របបណាហ្ស៊ី ។ ទោះបីជាវិសាលភាពមិនមានភាពដូចគ្នាក៏ដោយក៏ពាក្យនេះមានន័យជាន់គ្នា ហើយអាចយកមកប្រើប្រាស់ជំនួសគ្នាបាន ទោះបីជាតិចក្តីច្រើនក្តី ដើម្បីពិពណ៌នាពីឧក្រិដ្ឋកម្មដ៏ធំធេងនាគ្រានោះ ដែលព្យាយាមធ្វើការកម្ទេចប្រជាជនជ្វីហ្វនៅប៉ែកអឺរ៉ុបទាំងអស់ ។ នៅចុងឆ្នាំ១៩៨៦ មានការកើតឡើងនូវការមិនយល់ស្របគ្នាដ៏សំខាន់មួយ ហើយវាមិនត្រូវបានដោះស្រាយនោះទេ រហូតទាល់តែដល់ចុងសតវត្សរ៍ទី២០ ។ ចុងបញ្ចប់ ពាក្យថាជាប់ពាក់ព័ន្ធនោះត្រូវបានបាត់ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែវាត្រូវការពេលជាងកន្លះសតវត្សរ៍ទៀតដើម្បីវិវត្តឲ្យកាន់តែមានភាពជាក់ស្តែងជាងនេះ ។ នៅក្នុងឆ្នាំ១៩៩៥ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានប្រកាសថា តម្រូវការដែលបានចែងថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែមានជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធនោះគឺមិនស្របទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ។ អង្គជំនុំជម្រះបែរជាផ្តល់នូវការពន្យល់មិនគួរឲ្យជឿមួយថាក្រុមប្រឹក្សាសន្តិសុខបានដាក់បញ្ចូលពាក្យជាប់ពាក់ព័ន្ធនៅក្នុងមាត្រា៥នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដើម្បីគ្រាន់តែកំណត់កម្រិតយុត្តាធិការប៉ុណ្ណោះ ។ តែការពន្យល់ដែលគួរឲ្យជឿជាងនេះ គឺថាមេធាវីនៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិដែលជាអ្នកតាក់តែងធម្មនុញ្ញនេះឡើងមានការជឿជាក់ថា ពាក្យថាជាប់ពាក់ព័ន្ធគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយក្រុមប្រឹក្សាមិនមានការជំទាស់អ្វីទេ ។

យ៉ាងណាក៏ដោយ ឥឡូវគឺមិនមានចម្ងល់នោះទេទាក់ទង



សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អេនច្រូ ខេលី

ទៅនឹងកំហុសឆ្គងនៃទស្សនៈរបស់តុលាការនូរ៉ែមប៊េកថាត្រូវបានកែប្រែហើយឬយ៉ាងណាទេស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលជាអ្វីបណ្តាលឲ្យលើកឡើងនូវគំនិតផ្តួចផ្តើមរបស់ លេមគីន ទាក់ទងនឹងអំពើប្រល័យពូជសាសន៍នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ។ និយមន័យដែលទទួលបានការគាំទ្រនោះ គឺមានចែងនៅក្នុងមាត្រា៧នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលមិនមានផ្ទុកនូវសេចក្តីយោងទៅលើជម្លោះប្រដាប់អាវុធថាជាសមាសធាតុនៅក្នុងបរិបទនោះទេ។ ភាពមិនច្បាស់លាស់ដែលបន្តមានជាក់ស្តែងតែមួយគត់នោះ គឺពេលវេលាដែលពាក្យថាជាប់ពាក់ព័ន្ធនេះបានបាត់ខ្លួនយ៉ាងពិតប្រាកដចេញពីសមាសធាតុនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បើតាមដែលគិតពីគណៈកម្មាធិការច្បាប់អន្តរជាតិនោះ ពាក្យនេះដូចជានៅមានវត្តមានរហូតដល់ឆ្នាំ១៩៥០ ហើយប្រហែលជាអាចឈានដល់ក្រោយហ្នឹងទៀតផង។ នៅក្នុងឆ្នាំ១៩៥៤ គណៈកម្មាធិការបានធ្វើការសាកល្បងដោយដកពាក្យជាប់ពាក់ព័ន្ធនេះចេញហើយជំនួសដោយសមាសធាតុនៃបរិបទមួយទៀត គឺផែនការឬគោលនយោបាយរបស់រដ្ឋវិញ។ ក៏មានការទទួលស្គាល់ផងដែរនាពេលថ្មីៗនេះពីសំណាក់តុលាការសិទ្ធិមនុស្សនៅអឺរ៉ុប ដែលបានគាំទ្រទស្សនៈដែលថាពាក្យថា ជាប់ពាក់ព័ន្ធនេះត្រូវបានអវត្តមានតាំងពីដើមទសវត្សរ៍៥០មកម្ល៉េះ។ នៅក្នុងសេចក្តីសម្រេចមួយកាលពីខែកញ្ញា ឆ្នាំ២០០៨ អង្គជំនុំជម្រះនៃតុលាការនេះបាននិយាយយ៉ាងប្រុងប្រយ័ត្នថាជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ «ប្រហែលជាលែងមានទាក់ទងទៀតហើយ ចាប់ពីឆ្នាំ១៩៥៦មក»។ បញ្ហានេះគឺប្រឈមដោយផ្ទាល់ជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងកិច្ចខំប្រឹងប្រែងនាពេលថ្មីៗនេះដើម្បីធ្វើការកាត់ទោសអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម។



អនត្រូ ខេលី បកស្រាយពីនិយមន័យនៃអំពើប្រល័យពូជសាសន៍

បច្ចុប្បន្ននេះ យើងប្រហែលជានិយាយពីពាក្យអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិម្តងទៀតដូចដែលអ្វីដែលពាក្យនេះត្រូវបានប្រើប្រាស់កាលពីមុន។ លទ្ធផលតាមផ្លូវច្បាប់តែមួយគត់ក្នុងការពិពណ៌នាពីអំពើឃោរឃៅមួយថាជាអំពើប្រល័យពូជសាសន៍ជាជាងអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺគ្រង់ថាអំពើនេះងាយស្រួលនឹងនាំយកទៅកាត់ទោសនៅតុលាការយុត្តិធម៌អន្តរជាតិដែលមានចែងក្នុងមាត្រា៩នៃអនុសញ្ញាឆ្នាំ១៩៤៨។ ប៉ុន្តែ មាត្រា៩នេះបាននាំមកនូវកម្តៅ ជាជាងពន្លឺ ហើយសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់តុលាការនៅបូស្នៀ និងស៊ែប៊ី គួរតែធ្វើឲ្យរាថយនូវការធ្វើតាមវិធីសាស្ត្រនេះលើកលែងតែនៅក្នុងករណីដែលច្បាស់លាស់បំផុតតែប៉ុណ្ណោះ។

ជាការពិតណាស់ ភាពខុសគ្នារវាងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺនៅតែមានសារសំខាន់តែគ្រាន់តែជានិមិត្តរូបមួយប៉ុណ្ណោះ។ មានប្រជាជនបូស្នៀជាច្រើនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារថាការឈឺចាប់របស់ពួកគេកាលពីសង្គ្រាមឆ្នាំ១៩៩២-១៩៩៥ នោះមិនត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍នោះ លើកលែងតែនៅក្នុងករណីជាក់លាក់បំផុតនិងជាចុងក្រោយគឺករណីនៃការសម្លាប់រង្គាលនៅស្រេព្រេនីកាប៉ុណ្ណោះ។ បញ្ហានេះគឺត្រូវបានឆ្លុះបញ្ចាំង

ចេញពីមតិជាច្រើនរបស់មេធាវីអន្តរជាតិស្តីពីសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ។ ស្រដៀងគ្នាផងដែរ គឺមានការមិនពេញចិត្តជាខ្លាំងនៅពេលដែលគណៈកម្មាធិការស៊ើបអង្កេតបានរៀបចំដោយអនុលោមទៅតាមតម្រូវការមួយរបស់ក្រុមប្រឹក្សាសន្តិសុខដែលបានសម្រេចថា ស៊ូដង់មិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅដាហ្វួរនោះទេ ។ ប៉ុន្តែ ចំណុចសំខាន់នៃសង្គ្រាមបូស្នៀត្រូវបានពិពណ៌នាជាច្រើនលើកច្រើនសានៅក្នុងសំណុំរឿងច្បាប់នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅវិញ ហើយគណៈកម្មាធិការដាហ្វួរក៏អនុវត្តដូចគ្នាផងដែរចំពោះការបោសសម្អាតជាតិពន្ធុនៅប្រទេសស៊ូដង់ ដោយជំរុញឲ្យស្ថានភាពនេះត្រូវតែប្រគល់ជូនតុលាការឧក្រិដ្ឋកម្មអន្តរជាតិដើម្បីធ្វើការកាត់ទោស ។ សេចក្តីសម្រេចដែលថាគ្មានគោលនយោបាយប្រល័យពូជសាសន៍ណាត្រូវបានដើរតាមឬអនុវត្តន៍ឡើយនៅតំបន់ដាហ្វួរ ដោយអាជ្ញាធររដ្ឋាភិបាលនោះទេមិនថាដោយផ្ទាល់ឬតាមរយៈកងឈ្លបដែលនៅក្រោមការគ្រប់គ្រងរបស់ខ្លួនក្តីគឺមិនគួរត្រូវបានបោកបញ្ឆោតនូវគ្រប់មធ្យោបាយណាទាំងអស់ដើម្បីបន្ថយភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងតំបន់នោះ ។ បទល្មើសអន្តរជាតិ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដែលបានប្រព្រឹត្តឡើងនៅតំបន់ដាហ្វួរ ប្រហែលជាមិនមែនមានភាពធ្ងន់ធ្ងរនិងឃោរឃៅតិចជាងអំពើប្រល័យពូជសាសន៍នោះទេ ។

ប្រសិនបើការរងគ្រោះរបស់ពួកគេត្រូវបានទទួលស្គាល់ថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នោះជនជាតិភាគតិចបូស្នៀ មូស្លីម និងដាហ្វួរ គឺមានភាពប្រហាក់ប្រហែលគ្នានោះទេ ។ ទោះបីជានាពេលបច្ចុប្បន្ននេះយើងនិយាយពីការប្រល័យពូជសាសន៍មកលើជនជាតិអាម៉េនីនិងជ្វីហ្វក៏ដោយ តែនៅពេលដែលជនជាតិទាំងនេះទទួលរងនូវអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះគឺជាពាក្យមួយដែលអាចប្រើប្រាស់បាននៅពេលនោះប្រហែលជានៅប៉ុន្មានឆ្នាំទៅមុខទៀត នាពេលបច្ចុប្បន្ន ទោះបីការលំបាកផ្នែកច្បាប់ស្តីពីភាពខុសគ្នានៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានដោះស្រាយ ហើយក៏ដោយក៏អត្ថន័យនៃពាក្យទាំងនេះនឹងទោរទន់នៅជុំវិញទិសដៅដូចគ្នាដដែល ។

សារសំខាន់ផ្នែកច្បាប់នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍នេះបានធ្លាក់ចុះតាំងពីមួយទសវត្សរ៍មុនមកម្ល៉េះ ប៉ុន្តែមិនមែនដោយសារអនុសញ្ញានេះមិនអាចប្រើប្រាស់បាននៅក្នុងកាលៈទេសៈជាក់លាក់ណាមួយឬក៏ឃ្លាតឆ្ងាយពីការយល់ឃើញរបស់អ្នកការទូតនិងចៅក្រមនោះទេ ។ ប៉ុន្តែ ដោយសារតែមានឧបករណ៍និងស្ថាប័នថ្មីៗបានកើតឡើង ដែលក្នុងចំណោមនោះមានតុលាការឧក្រិដ្ឋកម្មអន្តរជាតិជាដើម ។ បើតាមវិធីផ្សេងវិញនោះ តុលាការនេះបានទទួលជោគជ័យច្រើនស្រដៀងគ្នាទៅនឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ប៉ុន្តែក៏នៅក្នុងរបៀបមួយដែលអាចប្រើប្រាស់មកលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ ។ ជាងនេះទៅទៀត វិធីសាស្ត្រថ្មីមួយអំពី «ការដាក់ឲ្យទទួលខុសត្រូវ ដើម្បីទប់ស្កាត់» គឺបានបន្ថយនូវតួនាទីក្នុងការការពារដែលមានចែងនៅក្នុងមាត្រាមួយនៃអនុសញ្ញាប្រល័យពូជសាសន៍ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ បើយោងតាមច្បាប់វិញ ប្រសិនបើមាននោះវាគ្រាន់តែមានសារសំខាន់តែបន្តិចបន្តួចប៉ុណ្ណោះទាក់ទងនឹងភាពខុសគ្នានៃអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សារសំខាន់នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍អាចប្រទះឃើញមិនច្រើនប៉ុន្មានទេនៅក្នុងសក្តានុពលនាពេលបច្ចុប្បន្នរបស់អនុសញ្ញានេះក្នុងការលើកឡើងពីអំពើព្រៃផ្សៃដែលជាអ្វីដែលភាគច្រើនត្រូវបានជំនួសដោយអត្ថបទថ្មីជាងនេះ ដោយសារតែការរួមចំណែកជាប្រវត្តិសាស្ត្ររបស់វានៅក្នុងការតស៊ូដើម្បីដាក់ឲ្យមានការទទួលខុសត្រូវនិងការការពារសិទ្ធិមនុស្ស ។

**ទីលៀម សាបាស់**

## អានទស្សនាវដ្តីតាមគេហទំព័រ

*ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។*

**សូមអរគុណ!**

# ការសន្មតទុកជាមុនថាមានការសម្ងាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា : តម្រូវការឱ្យមានបទដ្ឋានសម្រាប់ការពារការស៊ើបអង្កេតជាឯកជន ផ្តល់ការស្វែងរកព័ត៌មានដល់សាធារណជនដូចគ្នានិងបង្កើនតម្លាភាព

## ក) ប្រវត្តិ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការពិសេសមួយក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដោយសារតែតុលាការនេះមានដំណើរការជាមួយប្រព័ន្ធច្បាប់ក្នុងស្រុក ។ ដោយសារតែរចនាសម្ព័ន្ធរបស់ខ្លួន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើប្រាស់នូវបទដ្ឋានយុត្តិធម៌អន្តរជាតិ និងដើរតួនាទីជាគំរូមួយសម្រាប់ប្រទេសកម្ពុជា ។ តាមរយៈការអនុវត្តច្បាប់ស៊ីវិល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានដំណើរការនៅក្រោមវិធាននីតិវិធីដែលខុសឆ្ងាយពីវិធានរបស់តុលាការផ្សេង ។ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតជំយូរនិងត្រូវបានសន្មតថាសម្ងាត់ និងមិនមានការប្រកាសជាសាធារណៈនូវការស្នើរបស់ភាគីនិងដីកាតុលាការទេ ។ ក្នុងករណីអវត្តមានកាលៈទេសៈពិសេសខ្លះ នៅពេលដែលសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីរបស់សាធារណជនត្រូវបានរក្សាទុកមុនពេលមានសវនាការជំនុំជម្រះសវនាការអង្គបុរេដែលដោះស្រាយបណ្តឹងជំទាស់ដែលស្នើដោយដីការបស់សហចៅក្រមស៊ើបអង្កេតត្រូវធ្វើឡើងដោយសម្ងាត់ ។ ជាលទ្ធផល ព័ត៌មានសាធារណៈអំពីដំណើរការនីតិវិធីមុនពេលជំនុំជម្រះក្តីត្រូវបានគេដាក់កំហិតជាខ្លាំង ។

ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏តម្រូវឲ្យរក្សាតម្លាភាព និងផ្តល់គ្រប់ព័ត៌មានដល់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការនីតិវិធីដែរ ។ ការស៊ើបអង្កេតជំយូរ ចំនួនជនរងគ្រោះជាច្រើន និងការឃុំឃាំងកម្មាភិបាលខ្មែរក្រហមដែលមានគេទទួលស្គាល់ជាច្រើនបានបណ្តាលឲ្យតម្រូវការចង់ដឹងពីព័ត៌មានសាធារណៈកើនឡើង ។ បន្ទាប់ពីមានដីកាចម្រូងចម្រាស់របស់ចៅក្រមស៊ើបអង្កេតទាក់ទងនឹងការទម្លាយការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការនៅឆ្នាំ២០០៩ និងការព្រមានរបស់អង្គបុរេជំនុំជម្រះទៅលើអ្នកកាសែតមិនឲ្យផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយមិនមានការអនុញ្ញាត ថ្មីៗនេះបណ្តាលឲ្យមានសំណួរមួយចំនួនទាក់ទងនឹងតុល្យភាពនៃការសម្ងាត់និងតម្លាភាព ។

សំណួរទីមួយគឺ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរចនាសម្ព័ន្ធពិសេស តើអ្វីជាទម្រង់នៃការសន្មតទុកជាមុនថាមានការរក្សាសម្ងាត់នៅអំឡុងពេលមុនសវនាការ? ទីពីរ តើលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរៀបចំនូវវិធានការណ៍បន្ថែមដើម្បីធានាថាសាធារណជនអាចស្វែងរកព័ត៌មានបានដែរឬទេ?

### ១) គោលការណ៍មូលដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា : ការការពារបុគ្គល តម្លាភាព និងលក្ខណៈពិសេស

គោលការណ៍មូលដ្ឋានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងនៅក្នុងវិធាន២១(១) នៃវិធានផ្ទៃក្នុងតម្រូវថា :

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមានត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនជាប់ចោទនិងជនរងគ្រោះដើម្បីធានានូវសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃដំណើរការនីតិវិធីដោយគិតពីលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដូចបានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង ។

ដូច្នេះ វិធាន២១តម្រូវថាផលប្រយោជន៍ក្រុមនៃបុគ្គលពិសេសគួរតែត្រូវបានគេធ្វើឲ្យមានសមតុល្យជាមួយនឹងសារសំខាន់នៃការរក្សាសច្ចៈភាពផ្លូវច្បាប់និងតម្លាភាព ហើយផលប្រយោជន៍ទាំងនោះត្រូវបានគេចាត់ទុកថាជា «លក្ខណៈពិសេស» របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លក្ខណៈពិសេសនេះគឺជា

សម្ងាត់មិនច្បាស់លាស់ ប៉ុន្តែការណែនាំគឺអាស្រ័យលើការបកស្រាយផ្ទាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅលើគោលការណ៍ដែលអាចបំបែកជាគោលបំណងពីរ គឺដើម្បីប្រើប្រាស់បទដ្ឋានយុត្តិធម៌អន្តរជាតិ និងដើរតួនាទីជាគំរូមួយសម្រាប់តុលាការកម្ពុជាក្នុងស្រុក ។

ដូច្នេះ ភាសានៅក្នុងវិធាន២១បង្ហាញថាច្បាប់គ្រប់គ្រងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលរួមមានវិធានផ្ទៃក្នុងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងត្រូវបានបកស្រាយរួមគ្នាដោយមានការពិចារណាទៅលើគោលបំណងសំខាន់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាជាងយកមកបកស្រាយម្តងមួយចំណុច ។ រូបរាងនៃការសន្មតទុកជាមុនថាមានការសម្ងាត់មិនត្រឹមតែតម្រូវឲ្យមានការបកស្រាយជារួមទៅលើវិធានផ្ទៃក្នុងទេ តែថែមទាំងតម្រូវឲ្យមានការវិភាគទៅលើគោលបំណងដែលនៅពីក្រោយពីគោលការណ៍នោះ និងសេចក្តីណែនាំរបស់ច្បាប់អន្តរជាតិទេ ។

**គ) និន្នាការនៃការស្វែងរកព័ត៌មានសាធារណៈ**

សច្ចភាពផ្លូវច្បាប់និងតម្លាភាពដែលមានចែងនៅក្នុងវិធាន២១នៃវិធានផ្ទៃក្នុងគឺជាទស្សនៈដែលបានមកពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ។ ភាពខុសគ្នារវាងតុលាការទាំងនេះ និងតុលាការក្នុងស្រុកគឺជាគោលបំណងតែមួយសម្រាប់ផ្តល់យុត្តិធម៌ និងជួយដល់ការផ្សះផ្សាជាតិ ។ ខណៈពេលដែលការការពារដោយសម្ងាត់នៅតែជាការព្រួយបារម្ភមួយនៅតុលាការដែលបង្កើតឡើងដើម្បីការពារជនរងគ្រោះនិងសាក្សីនិងការរួមបញ្ចូលគ្នានៃការស៊ើបអង្កេតដោយសារតែចំនួននៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានកើនឡើងនៅក្នុងពិភពលោក ការការពារនេះក៏មាននិន្នាការទូទៅមួយសម្រាប់ឆ្ពោះទៅរកការផ្តល់ព័ត៌មានជាសាធារណៈច្រើនជាងមុន ។

ក្នុងចំណោមតុលាការអន្តរជាតិ វិធានដែលទាក់ទងនឹងការសម្ងាត់ត្រូវបានបែងចែកជាពីរផ្នែកៈ ១) វិធានដែលគ្រប់គ្រងការដឹកនាំរបស់ព្រះរាជអាជ្ញានៅអំឡុងពេលស៊ើបអង្កេត និង ២) វិធានដែលគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មានជាឯកសារនិងសាលក្រមរបស់អង្គជំនុំជម្រះ ។ ខណៈពេលដែលការស៊ើបអង្កេតនៅតុលាការផ្សេងមិនត្រូវធ្វើឡើងជាសម្ងាត់ ព្រះរាជអាជ្ញាអាចមានឆន្ទានុសិទ្ធិនៅក្នុងដំណាក់កាលស៊ើបអង្កេតស្រដៀងនឹងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ការសន្មតនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតទំនងជាមានការស៊ើបអង្កេតជាសាធារណៈខណៈពេលដែលនៅក្នុងវិធាននីតិវិធីតម្រូវឲ្យមានការសម្ងាត់នៅក្នុងកាលៈទេសៈខ្លះ ។ ខណៈពេលដែលវិធានគ្រប់គ្រងទៅលើព្រះរាជអាជ្ញា និងចៅក្រមត្រូវបានយកទៅប្រើប្រាស់នៅក្នុងដំណាក់កាលមុនពេលជំនុំជម្រះនៅតុលាការផ្សេងទៀត លទ្ធភាពក្នុងការរក្សាព័ត៌មានជាសម្ងាត់កាន់តែមានកំណត់ជាងមុនទោះបីជាការស៊ើបអង្កេតត្រូវបញ្ចប់ហើយសាលក្រមនឹងត្រូវប្រកាសជាសាធារណៈក៏ដោយ ។

ការអនុវត្តរបស់តុលាការអន្តរជាតិផ្សេងទៀតបង្ហាញថាទោះបីជាសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានឆន្ទានុសិទ្ធិដ៏ទូលាយក្នុងការការពារការស៊ើបអង្កេតរបស់ខ្លួន មានការបកស្រាយយ៉ាងតិចតួចបំផុតទៅលើការរក្សាព័ត៌មានជាសម្ងាត់ជាពិសេសគឺនៅពេលដែលដីកាដំណោះស្រាយត្រូវបានបំពេញ ។

**ឃ) ការសន្មតទុកជាមុនថាមានការសម្ងាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតម្រូវការឲ្យមានបទដ្ឋាន**

ដោយខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត និងស្របនឹងប្រព័ន្ធច្បាប់ស៊ីវិលក្នុងស្រុក វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថារាល់ការស៊ើបអង្កេតរបស់តុលាការត្រូវធ្វើឡើងជាសម្ងាត់ ។ ដោយយោងទៅតាមការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងវិធានទូទៅ រាល់ឯកសារនិងព័ត៌មានដែលមាននៅក្នុងសំណុំរឿងត្រូវរក្សាជាសម្ងាត់ សូម្បីតែឯកសារដែលមានព័ត៌មានដែលបម្រុងនឹងផ្សព្វផ្សាយជាសាធារណៈក៏ដោយ ។

ទោះបីជាមានការសន្មតថាមានការស៊ើបអង្កេតជាសម្ងាត់ ការិយាល័យសហចៅក្រមស៊ើបអង្កេតបាននិយាយថាគោលការណ៍មូលដ្ឋាននៃការរក្សាការសម្ងាត់មានភាពបត់បែនដើម្បីផ្តល់ព័ត៌មានដ៏តិចតួចដល់សាធារណជន ។ ប៉ុន្តែដើម្បី

សម្រេចតាមបទដ្ឋានរក្សាការសម្ងាត់ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានបកស្រាយអ្វីឡើយ ។ ស្រដៀងគ្នានេះដែរ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានបង្កើតលក្ខណៈវិនិច្ឆ័យជាក់លាក់អ្វីសម្រាប់បញ្ជាក់ថានៅពេលណាត្រូវផ្តល់ព័ត៌មានដល់សាធារណជន ហើយតែងតែរំឭកដល់សាធារណៈថាសេចក្តីសម្រេច គឺផ្អែកទៅលើមូលដ្ឋាននៃសំណុំរឿងពីមួយទៅមួយ ។

ការវិភាគឯកសារនៅតែធ្វើឡើងជាសម្ងាត់នៅអំឡុងពេលស៊ើបអង្កេតរបស់តុលាការ ហើយអ្នកដែលផ្តល់ព័ត៌មានដល់សាធារណជនក៏បានផ្តល់សេចក្តីណែនាំដ៏តិចតួចទាក់ទងនឹងការសន្មតទុកមុនថាមានការសម្ងាត់ដែរ ។ ស្រដៀងគ្នានេះដែរ ការវិភាគទៅលើលក្ខណៈមិនស្របគ្នាដែលត្រូវបានសម្រេចមុនពេលសវនាការក៏បង្ហាញពីសេចក្តីសម្រេចមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតនិងអង្គបុរេជំនុំជម្រះ ។ ប៉ុន្តែវិធាន៧៧(១៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថា បណ្តឹងឧទ្ធរណ៍នៅអង្គបុរេត្រូវតែមានហេតុផលសម្អាងដោយបង្ហាញជាផ្នែកថា «រាល់សេចក្តីសម្រេចនៅក្នុងវិធានដែលរួមមានរាល់យោបល់ជំទាស់គួរតែមានហេតុផលសម្អាងនិងមានចុះហត្ថលេខា» ។ ខណៈពេលដែលវិធាន៧៧នៃវិធានផ្ទៃក្នុងមិនបានតម្រូវថាដីការបស់សហចៅក្រមស៊ើបអង្កេតត្រូវមានហេតុផលសំអាងដីការបស់សហចៅក្រមស៊ើបអង្កេតត្រូវតែមានសម្អាងច្បាស់លាស់ ។

អង្គបុរេជំនុំជម្រះបានរំឭកដល់សហចៅក្រមស៊ើបអង្កេតអំពីសារសំខាន់ក្នុងការផ្តល់ហេតុផលសម្អាងនៅក្នុងដីការបស់ខ្លួនដោយអះអាងថា «រាល់សេចក្តីសម្រេចរបស់អង្គភាពតុលាការតម្រូវឲ្យមានហេតុផលសម្អាងពីព្រោះវាគឺជាបទដ្ឋានអន្តរជាតិ» ។ អង្គបុរេជំនុំជម្រះក៏បានរៀបរាប់ពីគោលបំណងសំខាន់ពីរស្តីពីសេចក្តីសម្រេចដែលរួមមានហេតុផលសម្អាង ។ គោលបំណងទីមួយគឺសាធារណជននិងភាគីមានសិទ្ធិទទួលបានសេចក្តីសម្រេចដែលមានហេតុផលសម្អាង ហើយទីពីរដើម្បីរក្សាអំណាចរបស់ខ្លួនក្នុងការផ្តល់សេចក្តីសម្រេចដែលមានហេតុផលសម្អាង ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវតែបង្ហាញឲ្យច្បាស់លាស់និងផ្តល់ហេតុផលដែលអង្គបុរេជំនុំជម្រះប្រើប្រាស់ដើម្បីចេញសេចក្តីសម្រេចរបស់ខ្លួន ។

ការខ្វះសេចក្តីសម្រេចដែលប្រកបដោយហេតុផលសម្អាង ឬបទដ្ឋានច្បាស់លាស់ដើម្បីគ្រប់គ្រងលើការរក្សាការសម្ងាត់បានបណ្តាលឲ្យមានការរិះគន់ជាច្រើនទៅលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីសំណាក់ភាគីរបស់ខ្លួនផ្ទាល់ អ្នកអង្កេតតុលាការ និងប្រជាជនកម្ពុជា ។ ទស្សនៈសាធារណៈទៅលើប្រតិបត្តិការមិនស្របច្បាប់ដែលអាចកើតមាននៅតុលាការគឺជាបញ្ហាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាហើយវាអាចកាត់បន្ថយការចាប់អារម្មណ៍របស់សាធារណជន និងរារាំងដល់ការដើរតួជាតុលាការគំរូមួយដល់តុលាការក្នុងស្រុក ។

នៅកំរិតទាបបំផុត ការបង្កើតបទដ្ឋាននៃការរក្សាការសម្ងាត់ដោយមិនមានយុត្តិសាស្ត្របន្ថែមសម្រាប់ផ្តល់ព័ត៌មានដល់សាធារណជននឹងបង្កើនការវិនិយោគនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ស្រដៀងគ្នានេះដែរ ដោយដឹងថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងដំណើរការនៅក្រោមបទដ្ឋានដ៏ច្បាស់លាស់មួយ វាអាចនឹងធានាដល់សាធារណជនថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានមូលដ្ឋានស្របច្បាប់មួយសម្រាប់រក្សាព័ត៌មានជាសម្ងាត់ ហើយទោះបីជាព័ត៌មានខ្លះត្រូវបានការពារយុត្តិធម៌ក៏ត្រូវបានគេគ្រប់គ្រងដោយត្រឹមត្រូវដែរ ។ ប្រសិទ្ធភាពនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទំនងជាអាចកើនឡើង ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនអនុវត្តតាមបទដ្ឋានឬខកខានមិនបានផ្តល់សេចក្តីសម្រេចដែលមានហេតុផលសម្អាង អ្នកទាំងនោះនឹងត្រូវទទួលខុសត្រូវចំពោះគ្រប់ភាគីទាំងអស់ និងសាធារណៈជន ។ ជាងនេះទៅទៀត ការអប់រំសាធារណជនឲ្យយល់ដឹងពីមុខងារស៊ើបអង្កេតដ៏ស្របច្បាប់របស់តុលាការនឹងធានាថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចដើរតួនាទីជាគំរូមួយដល់ប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជា ។

## ង) រូបភាពនៃគោលការណ៍រក្សាការសម្ងាត់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

យោងទៅតាមភាពខ្វះខាតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងការបង្កើតវិធានឬសេចក្តីសម្រេចរបស់

តុលាការដែលមានហេតុផលសម្អាងទាក់ទងនឹងរូបភាពនៃយុត្តិសាស្ត្រសម្ងាត់សេចក្ដីណែនាំសម្រាប់កំណត់ទៅលើការសន្មតទុកមុនថាមានការសម្ងាត់តម្រូវឲ្យមានការវិភាគទៅលើគោលបំណងនៃគោលការណ៍រក្សាការសម្ងាត់ដូចដែលបានរៀបរាប់ដោយតុលាការ និងសេចក្ដីណែនាំរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ។ ខណៈពេលដែលភាពស្របគ្នាជាមួយនឹងដំណើរការនីតិវិធីក្នុងស្រុករបស់កម្ពុជាគឺជាកត្តាសំខាន់មួយដែលប្រើប្រាស់សម្រាប់ពង្រាងបទដ្ឋានបែបនេះ វាក៏ជាលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។

ភាសានៅក្នុងវិធាន៥៦នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចែងថាគោលការណ៍ដែលនៅពីក្រោយការរក្សាការសម្ងាត់គឺដើម្បី «ការពារសិទ្ធិ និងប្រយោជន៍របស់ភាគី» ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតក៏បានបកស្រាយពីហេតុផលជាក់លាក់បីសម្រាប់តម្រូវការការស៊ើបអង្កេតជាសម្ងាត់ដើម្បីធានានូវគុណភាពនៃដំណើរការតុលាការដែលរួមមាន ១) ការធានានូវការរក្សាភាពជាឯកជនរបស់អ្នកដែលមានឈ្មោះនៅក្នុងសំណុំរឿង ២) ការសន្មតទុកជាមុននូវការគ្មានទោស និង៣) ប្រសិទ្ធិភាពនៃការស៊ើបអង្កេត ។

## ១) ឯកសារសម្ងាត់

ការការពារជនរងគ្រោះ និងសាក្សីគឺជាហេតុផលសម្អាងដែលតុលាការព្រហ្មទណ្ឌអន្តរជាតិប្រើប្រាស់សម្រាប់ដាក់កំហិតលើការរក្សាព័ត៌មានសម្ងាត់ ។ ដោយគិតទៅដល់បុគ្គលដែលដាក់ពាក្យបណ្ដឹងទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបានសហការនៅក្នុងសំណុំរឿងមានមនុស្សជាច្រើនត្រូវបានរួមបញ្ចូលនៅក្នុងបទបញ្ញត្តិរក្សាការសម្ងាត់ ។

ដោយសហចៅក្រមស៊ើបអង្កេតបាននិយាយតែបន្តិចបន្តួចអំពីការការពារជនរងគ្រោះ និងសាក្សី ដាក់ស្ដែងអ្នកទាំងនោះមានសិទ្ធិតែបន្តិចបន្តួចក្នុងការផ្សព្វផ្សាយព័ត៌មានរបស់អ្នកដែលបានជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតប៉ុណ្ណោះ ។ ប៉ុន្តែ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈពិសេសវាប្រហែលជាមិនតម្រូវឲ្យមានស្ថានភាពការការពារជនរងគ្រោះនិងសាក្សីទៀតទេ ។ នៅប្រទេសកម្ពុជា ជនរងគ្រោះនៃរបបខ្មែរក្រហមមានចំនួនរាប់ពាន់នាក់ ។ ប្រវត្តិសោកនាដកម្មរបស់ប្រទេសនេះធ្វើឲ្យជនរងគ្រោះជាច្រើន ហើយភាគច្រើននៃអ្នកទាំងនោះចង់ចែករំលែករឿងរ៉ាវរបស់ខ្លួនជាខ្លាំង ។ អាស្រ័យហេតុនេះ គោលបំណងនៃការរក្សាការសម្ងាត់របស់ជនរងគ្រោះប្រហែលជាមិនចាំបាច់ទៀតទេនៅពេលដែលអ្នកដែលមានបទបញ្ញត្តិការពារបោះបង់សិទ្ធិនោះ ។

នៅក្នុងសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យុត្តិសាស្ត្រការពារជនរងគ្រោះនិងសាក្សីមានការព្រួយបារម្ភចំពោះការរក្សាការសម្ងាត់របស់អ្នកទាំងនោះ ។ ប៉ុន្តែ នៅពេលដែលជនរងគ្រោះមិនមានការព្រួយបារម្ភ និងចង់ចែករំលែកពីរឿងរ៉ាវរបស់ខ្លួន វាមានហេតុផលតែបន្តិចបន្តួចប៉ុណ្ណោះសម្រាប់រក្សាព័ត៌មានរបស់អ្នកទាំងនោះជាសម្ងាត់ ។ ករណីនេះនឹងមានលក្ខណៈត្រឹមត្រូវនៅពេលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានតួនាទីជាតុលាការគំរូដែលតម្រូវឲ្យមានតុល្យភាពរវាងតម្រូវការឲ្យមានបុគ្គលជាក់លាក់និងតួនាទីរបស់តុលាការក្នុងការរក្សាសច្ចភាពនិងតម្លាភាពដូចដែលមានចែងនៅក្នុងវិធាន២១នៃវិធានផ្ទៃក្នុង ។

ទោះបីជាដីការបស់សហចៅក្រមស៊ើបអង្កេតមិនបានបង្ហាញពីសារសំខាន់ក្នុងការការពារសិទ្ធិរបស់ជនត្រូវចោទក៏ដោយ ក៏ដំណើរនោះគឺជាគោលបំណងចម្បងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់រក្សាភាពជាឯកជនរបស់អ្នកទាំងនោះ ។ ប៉ុន្តែនៅក្នុងករណីជាច្រើននៅពេលដែលមិនមានការពិភាក្សាអំពីសាក្សីនិងជនរងគ្រោះឬហេតុផលដែលបកស្រាយពន្យល់ដោយតុលាការ ក៏មិនមានហេតុផលច្រើនបង្ហាញថាហេតុអ្វីបានជាមិនមានការផ្សព្វផ្សាយព័ត៌មានជាសាធារណៈដែរ ។ ភាសាដ៏ច្បាស់លាស់របស់វិធាន៥៦ដែលអះអាងថាការសន្មតទុកមុននូវការរក្សាការសម្ងាត់គឺដើម្បី «ការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគី» បានបង្ហាញថាបុគ្គលទាំងអស់អាចបោះបង់សិទ្ធិទទួលបានការរក្សាការសម្ងាត់នោះបាន ។ ការធ្វើបែបនេះប្រហែលជាអាចទៅរួចប្រសិនបើយើងគិតទៅដល់វិធាន២១នៃវិធានផ្ទៃក្នុងដែលមានគោលបំណងធ្វើឲ្យមានសមតុល្យរវាងការការពារភាគីនិងសិទ្ធិរបស់សាធារណជនក្នុងការទទួលបានដំណើរការនីតិវិធីដ៏

មានតម្លាភាព ។

ពាក្យ "ប្រសិទ្ធភាពនៃការស៊ើបអង្កេត" និង "ការស៊ើបអង្កេតឲ្យមានប្រសិទ្ធភាព" ត្រូវបានសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ជំនួសគ្នាដើម្បីបកស្រាយពីគោលការណ៍នៃការរក្សាការសម្ងាត់ និងហេតុផលក្នុងការមិនផ្សព្វផ្សាយព័ត៌មានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ។ គោលបំណងទាំងពីរនេះទំនងជាធ្វើឡើងដើម្បីពន្លឿនដំណើរការនីតិវិធីស៊ើបអង្កេតដោយមិនលម្អៀង ប៉ុន្តែមានសាធារណជនជាច្រើនអាចនឹងមិនយល់ពីគោលបំណងនៃការរក្សាការសម្ងាត់នេះ ។

ប៉ុន្តែ ដោយការស៊ើបអង្កេតឲ្យមានប្រសិទ្ធិភាពនៅតែជាផ្នែកសំខាន់មួយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ពីសារសំខាន់នៃការផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ជាពិសេសនៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកកាសែតមួយចំនួនត្រូវបានអនុញ្ញាតិឲ្យដឹងពីដំណើរការនៃការស៊ើបអង្កេត ។ នៅក្នុងករណីខ្លះទៀត ការផ្តល់ព័ត៌មានដល់សាធារណជនប្រហែលជាមានសារសំខាន់ជាងយុត្តិសាស្ត្ររក្សាព័ត៌មានជាសម្ងាត់នេះទៅទៀត ។

ទីមួយ ដោយគិតពីលក្ខណៈស្មុគស្មាញនៃសំណុំរឿងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រយៈពេលដែលសាធារណជនត្រូវបានបិទបាំងមិនឲ្យដឹងពីព័ត៌មានមានរយៈពេលយូរជាងនៅក្នុងប្រព័ន្ធស៊ីវិលក្នុងស្រុកដែលប្រើប្រាស់ករណីមិនសូវស្មុគស្មាញ ។ អាស្រ័យហេតុនេះ តម្រូវការឲ្យមានការស៊ើបអង្កេតដ៏មានប្រសិទ្ធភាពប្រហែលជាមិនសូវជាចាំបាច់ទៀតទេនៅពេលដែលការស៊ើបអង្កេតត្រូវចំណាយជាច្រើនខែ ។ បន្ថែមពីលើនេះទៅទៀត យុត្តិសាស្ត្ររក្សាការសម្ងាត់ដើម្បីបង្កើតប្រសិទ្ធិភាពនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាត្រូវកាត់បន្ថយប្រសិនបើគិតទៅដល់ប្រយោជន៍របស់វិធាន២១ ទាក់ទងនឹងតម្លាភាព ។ ទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានគោលបំណងដើរតួនាទីជាតុលាការគំរូមួយសម្រាប់តុលាការកម្ពុជាដែលប្រើប្រាស់ការស៊ើបអង្កេតជាសម្ងាត់ សាធារណជនត្រូវតែមានការយល់ដឹងខ្លះដើម្បីជាមូលដ្ឋានយល់ដឹងពីដំណើរការនីតិវិធីរបស់តុលាការ ។ ដូច្នេះ ផលប្រយោជន៍សាធារណៈប្រហែលជាសំខាន់ជាងប្រសិទ្ធភាពនៃការស៊ើបអង្កេត ។

## ២) សវនាការដោយសម្ងាត់

ស្រដៀងនឹងការអនុវត្តទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានអង្គបុរេជំនុំជម្រះមិនទាន់បានបកស្រាយពីហេតុផលជាក់លាក់ចំពោះការសន្មតនូវការធ្វើសវនាការដោយសម្ងាត់ ហើយវិធានផ្ទៃក្នុងក៏មិនបានបង្កើតគោលបំណងអ្វីនៅពីក្រោយបទបញ្ញត្តិដែរ ។ ប៉ុន្តែ យ៉ាងហោចណាស់ គោលបំណងតែមួយសម្រាប់ការធ្វើសវនាការជាសម្ងាត់គឺដើម្បីរក្សាការស៊ើបអង្កេតដោយសម្ងាត់ដែលជាយុត្តិសាស្ត្រប្រើប្រាស់សម្រាប់ការពារជនរងគ្រោះនិងសាក្សី ។ ករណីលើកលែងដែលមិនមានការសន្មតការធ្វើសវនាការជាសម្ងាត់គឺនៅពេលដែលសំណុំរឿងនោះត្រូវបានបញ្ចប់បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច ។ វាមិនមានភាពច្បាស់លាស់ថានៅក្នុងករណីណាដែលអាចធ្វើឲ្យមានការបើកសវនាការសាធារណៈ ពីព្រោះរាល់សេចក្តីសម្រេចត្រូវធ្វើឡើងម្តងមួយករណី ។ ដោយរាល់សវនការទាក់ទងនឹងដីកាឃុំខ្លួនមុនពេលជំនុំជម្រះធ្វើឡើងមិនដូចគ្នា ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបង្កើតការធ្វើសវនាការជាសាធារណៈខ្លះនិងជាសម្ងាត់ខ្លះ ។ គោលការណ៍សមរម្យមួយសម្រាប់កំណត់ថាតើត្រូវបើកសវនាការជាសម្ងាត់ឬទេគឺអាស្រ័យទៅលើសំណើរបស់ភាគី ។ ដូចដែលមានចែងនៅក្នុងកតិកាអន្តរជាតិស្តីពីសិទ្ធិនយោបាយនិងជនស៊ីវិល ការដំណើរនីតិវិធីដោយបើកចំហគឺជាសិទ្ធិមូលដ្ឋានដែលធ្វើឲ្យមានសវនាការដ៏យុត្តិធម៌មួយ ។ ប៉ុន្តែ វាគឺជាការអនុវត្តទូទៅនៅក្នុងតុលាការអន្តរជាតិរួមទាំងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពីព្រោះសិទ្ធិដំណើរការនីតិវិធីដោយបើកចំហមិនត្រូវបានយកទៅប្រើប្រាស់នៅក្នុងដំណើរមុនពេលជំនុំជម្រះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានរៀបរាប់ដោយតុលាការសិទ្ធិមនុស្សនៅអឺរ៉ុប លក្ខណៈសាធារណៈនៃដំណើរការនីតិវិធី "បានការពារគូក្តីប្រឆាំងនឹងការស្វែងរកយុត្តិធម៌ជាសម្ងាត់ដោយមិនមានការអង្កេតពីសាធារណជន ។ វាក៏ជាមធ្យោបាយមួយដែលធ្វើឲ្យតុលាការអាចរក្សាការទទួលបានភាពជឿជាក់បាន ។ តាមរយៈការធ្វើឲ្យដំណើរការកាត់ទោសមានតម្លាភាពសាធារណជនអាចធ្វើឲ្យមានការកាត់ទោសដ៏យុត្តិធម៌" ។

ដោយអនុវត្តតាមវិធាន២១នៃវិធានផ្ទៃក្នុងដែលមានគោលបំណងការពារជនត្រូវចោទនិងរក្សាតម្លាភាព អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែពិចារណាយ៉ាងហ្មត់ចត់ទៅលើសវនការសាធារណៈនៅពេលដែលភាគីទាំងអស់ជាពិសេសភាគីការពារក្តីបង្កើនការអង្កេតជាសាធារណៈ ។ ជាងនេះទៅទៀត ការអនុញ្ញាតឲ្យមានការពិភាក្សាជាសាធារណៈទៅលើការគ្រប់គ្រងនៅអង្គជំនុំជម្រះ ខណៈពេលអង្គជំនុំជម្រះកំពុងរក្សាភាពឯកជនរបស់ជនសង្ស័យផ្សេងទៀតអាចរក្សានូវតម្លាភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយយោងទៅតាមវិធាន២១និងការពារសិទ្ធិរបស់ជនរងគ្រោះនិងសាក្សី ព្រមទាំងការព្រួយបារម្ភដែលមានចែងនៅក្នុងវិធាន២១ និងគោលបំណងនៃការសន្មតទុកមុននូវការរក្សាសម្ងាត់ ។

គោលការណ៍ទីពីរដែលធ្វើឲ្យមានការបើកសវនាការជាសាធារណៈនៅមុនពេលជំនុំជម្រះគឺនៅពេលដែលគោលបំណងនៃការរក្សាការសម្ងាត់លែងមានសារសំខាន់ ជាពិសេសគឺនៅពេលដែលត្រូវពិចារណាទៅលើវិធាន២១នៃវិធានផ្ទៃក្នុងក្នុងការផ្តល់តម្លាភាព ។ ខណៈពេលដែលក្រុមការពារក្តីបានគាំទ្រនឹងការបើកសវនាការជាសាធារណៈមុនពេលជំនុំជម្រះច្រើនជាងមុន ព្រះរាជអាជ្ញានិងក្រុមការពារក្តីក៏បានគាំទ្រឲ្យមានការដាក់កំហិតទៅលើការសន្មតការបើកសវនាការជាសម្ងាត់នៅមុនពេលជំនុំជម្រះ ។ ចំពោះការផ្តល់យោបល់ទៅលើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្រុមអង្កេតការណ៍នៅតុលាការក៏បានជំរុញឲ្យអង្គជំនុំជម្រះអនុម័តនីតិវិធីដែលតម្រូវឲ្យមានការបើកសវនាការជាសាធារណៈនៅអង្គបុរេជំនុំជម្រះដែរ ។

ទោះបីជាសវនការសាធារណៈប្រហែលជាអាចធ្វើឲ្យដំណើរការនីតិវិធីដែលមានលក្ខណៈស្មុគស្មាញនិងចំណាយពេលស្រាប់កាន់តែចំណាយពេលច្រើនជាងមុន ការផ្តល់ព័ត៌មានបន្ថែមដល់សាធារណៈជន មិនត្រឹមតែអាចផ្តល់ឱកាសដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចដំណើរការធ្វើជាតុលាការគំរូមួយទេ តែថែមទាំងធ្វើឲ្យសាធារណជនយល់ដឹងកាន់តែច្បាស់ពីសាលាក្តីខ្មែរក្រហម ។ ស្រដៀងគ្នានឹងការបង្កើតបទដ្ឋានសម្រាប់គ្រប់គ្រងទៅលើការផ្សព្វផ្សាយឯកសារ កត្តាជាក់លាក់ខ្លះសម្រាប់កំណត់ថាតើនៅពេលណាត្រូវបើកសវនាការជាសាធារណៈអាចធ្វើឲ្យសាធារណជនយល់ថារាល់សេចក្តីសម្រេចគឺធ្វើឡើងដោយមានសម្អាងច្បាស់លាស់ពីច្បាប់ ។

## ៦) សេចក្តីសន្និដ្ឋាន

ការវិភាគមួយទៅលើការផ្តល់ព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតដល់សាធារណជននិងការអនុញ្ញាតរបស់អង្គបុរេជំនុំជម្រះឲ្យបើកសវនាការសាធារណៈបង្ហាញថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានមូលដ្ឋានផ្តល់ព័ត៌មានដល់សាធារណជនដោយមិនមានសម្អាងច្បាស់លាស់ ។ អវត្តមាននៃវិធាននីតិវិធីដែលអាចបង្ហាញពីរូបភាពនៃគោលការណ៍រក្សាការសម្ងាត់និងការខ្វះខាតសេចក្តីសម្រេចដែលមិនមានហេតុផលសម្អាងច្បាស់លាស់បង្ហាញពីតម្រូវការឲ្យមានបទដ្ឋានសម្រាប់កំណត់ទំហំនៃការសន្មត ។ ទាក់ទងនឹងការផ្តល់ឯកសារ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែពិចារណាបន្ថយយុត្តិសាស្ត្ររក្សាការសម្ងាត់ដើម្បីការពារជនរងគ្រោះនិងសាក្សីនៅពេលដែលបុគ្គលនោះចង់បង្ហាញពីបទពិសោធន៍របស់ខ្លួន និងមិនស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគួរតែពិចារណាអនុញ្ញាតឲ្យចុងចោទបោះបង់សិទ្ធិរក្សាការសម្ងាត់ដែលបង្កើតឡើងដើម្បីការពារអ្នកទាំងនោះ ។ ដោយពិចារណាទៅលើតម្រូវការតម្លាភាពរបស់តុលាការដែលមានចែងនៅក្នុងវិធាន២១នៃវិធានផ្ទៃក្នុងឆន្ទានុសិទ្ធិក្នុងការរក្សាការសម្ងាត់ដើម្បីធ្វើឲ្យការស៊ើបអង្កេតមានប្រសិទ្ធភាពគួរតែត្រូវបានដាក់កំហិត ។

ជាងនេះទៅទៀត ដោយពិចារណាទៅលើលក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះគួរតែពិចារណាម្តងទៀតនិងផ្តល់ហេតុផលសម្អាងទៅលើសេចក្តីសម្រេចទាក់ទងនឹងសវនការសម្ងាត់ ។ ដោយគោរពតាមសំណើរបស់ភាគីនិងការបកស្រាយដ៏តឹងរ៉ឹងទៅលើការសន្មតពីការបើកសវនការសម្ងាត់មិនត្រឹមតែអាចការពារសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ប៉ុណ្ណោះ តែថែមទាំងអាចធានាថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់តម្លាភាពនៅគ្រប់កាលៈទេសៈ ។

**គ្រីស្តា នែលសុន**

# ការពិត និងការចងចាំ : ទស្សនៈរបស់លោក ចន ស៊ីវ្ល

ក្នុងនាមជាតារាសម្តែងម្នាក់កាលពីឆ្នាំ២០០៨ ខ្ញុំត្រូវបានផ្តល់ឱកាសមួយមិនដែលមានពីមុនមកដើម្បីចូលទៅមើលឯកសារមួយចំនួននៅក្នុងបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពេលនោះ ខ្ញុំបានធ្វើការស្រាវជ្រាវនៅប្រទេសកម្ពុជាដើម្បីផលិតកម្មវិធីសម្តែងមួយដែលមានចំនួន៧០នាទីមានឈ្មោះថា ឌី ជីមណាសត៍ «The Gymnast» ។ រឿងនេះត្រូវបានដាក់បញ្ចាំងលើកដំបូងនៅមហោស្រពសិល្បៈនៅទីក្រុងអេឌីនប៊ើកប្រទេសស្កុតលែនក្នុងឆ្នាំ២០០៨ ។ ខ្សែភាពយន្តនេះផលិតឡើងដោយទីភ្នាក់ងារផលិតកម្មវិធីសម្តែងមួយឈ្មោះ Empty Space ដោយសហការជាមួយរូបខ្ញុំផ្ទាល់ (ជេន អានហៀល) ដែលជាតារាសម្តែងនិងលោក នីហ្គេល ឆាណក ប្រធានខាងកាយវិការនិងចលនា លោក ចន អាលឌើ អ្នកនិពន្ធបទភ្លេង និងបច្ចេកទេសសំឡេង លោក នៀល មុយរ៉េ អ្នកតុបតែងឆាកនិងលោក ម៉ាល់ខូម រីពប៉េស អ្នកបច្ចេកទេសពន្លឺ ។

បុសគល់ដែលនាំខ្ញុំទៅជាអ្នកសម្តែងរឿងនេះកើតចេញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំទាក់ទងបញ្ហាជំងឺរបួសផ្លូវចិត្តនិងពីរបៀបថាតើមនុស្សម្នាក់ៗអាចដោះស្រាយពីរបួសផ្លូវចិត្តនោះដោយរបៀបណា និងការខិតខំស្វះស្វែងរបស់អ្នកទាំងនោះក្នុងការរកយុត្តិធម៌ពីផលប៉ះពាល់ទាំងអស់នោះ ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលកើតឡើងនូវចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ គឺជាប្រភពនិងស្នូលនៃរឿង ឌី ជីមណាសត៍ ។ ខ្ញុំបានប្រើប្រាស់ប្រភពនេះដើម្បីធ្វើឲ្យសកម្មផ្ទាល់ខ្លួនខ្ញុំកាន់តែពុះកញ្ជ្រោលឡើងដែលចាប់ផ្តើមឡើងខណៈពេលដែលខ្ញុំមើលទូរទស្សន៍កាលពីខ្ញុំនៅក្មេង ។ តាមរយៈកម្មវិធីទូរទស្សន៍ ប៊ីប៊ីស៊ី មួយមានឈ្មោះថា Blue Peter Appeal កាលពីចុងទសវត្សរ៍៧០ ខ្ញុំបានឃើញប្រជាជនកម្ពុជាកំពុងតែវារលូននិងមានរូបរាងកាយខ្សត់ខ្សោយនិងបាក់កម្លាំងខណៈពេលដែលឆ្លងកាត់ព្រំដែនចូលទៅជំរំជនភៀសខ្លួនក្នុងទឹកដីថៃ ។

រឿង ឌី ជីមណាសត៍ បានផ្តល់ដល់អ្នកទស្សនានូវឱកាសមួយដើម្បីមើលឲ្យឃើញអំពីការចងចាំរបស់យុវតីជនជាតិអង់គ្លេសអាយុ១៣ឆ្នាំម្នាក់ និងអំពីអាថ៌កំបាំងនៃការចងចាំនោះកាលពីចុងទសវត្ស៍៧០ នៅប្រទេសអង់គ្លេស និងដើម្បីឆ្លើយតបទៅនឹងដំណឹងនិងព័ត៌មានដែលទទួលបានទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

ចាប់តាំងពីឆ្នាំ២០០៨មក ខ្ញុំបានធ្វើការស៊ើបអង្កេតរុករក និងច្នៃប្រឌិតការរាំសម្តែងទោលដែលមានចំនួន១៥នាទីចំនួនដប់ភាគដោយដកស្រង់ចេញពីរឿង ឌី ជីមណាសត៍ មានចំណងជើងថា The Ten Abandonment's ។ រឿង Abandonment ភាគមួយមានចំណងជើងថា «អ្នកមិនគួរគោរពព្រះផ្សេងទៀតក្រៅតែពីខ្លួនឯងទេ» ។ តាមរយៈការសម្តែងភាគមួយដែលកើតចេញពីការរុករកចេញពីកម្មវិធីសម្តែងមួយដែលមានប្រវែង៧០នាទី ដើម្បីបំលែងទៅជារឿងភាគមួយអំពីការរាំចង្វាក់បុរាណគឺក្នុងគោលបំណងដើម្បីអង្កេតមើលផលប៉ះពាល់និងឥទ្ធិពលដែលទាក់ទងទៅនិងជំងឺផ្លូវចិត្ត ផលប៉ះពាល់នៃជំងឺ និងគំនិតយោបល់ដែលទាក់ទងនឹងសង្គមបច្ចុប្បន្ននិងអ្នកទស្សនា ។ តាមរយៈលទ្ធផលដែលបានមកពីការសម្តែងនិងការស្រាវជ្រាវនេះ ហើយនិងតាមរយៈទំនាក់ទំនងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំត្រូវបានអញ្ជើញដើម្បីទៅចូលរួមជាមួយក្រុមការងារដើម្បីថែរក្សានិងរំឭកដល់របបប្រល័យពូជសាសន៍ជ្វីហ្វដែលសម្របសម្រួលដោយលោក ជេមស៍ មីលណ៍ មកពីស្ថាប័នរំឭកដល់អំពើប្រល័យពូជសាសន៍ជនជាតិជ្វីហ្វ ។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំជារៀងរាល់ឆ្នាំក្នុងខែមករានៅទីក្រុងញូខាសល អាប់ផន ធីន ។

ក្នុងនាមជាប្រធានអ្នករចនាសិល្បៈនៅឯព្រឹត្តិការណ៍រំឭកដល់ប្រល័យពូជសាសន៍ជនជាតិជ្វីហ្វ កិច្ចការរបស់ខ្ញុំគឺដើម្បីរៀបចំប្រមូលបណ្តាអ្នកសិល្បៈឲ្យមកជួបជុំគ្នានិងរកគំនិតច្នៃប្រឌិតរួមគ្នាដើម្បីបង្កើតកម្មវិធីមួយដែលឆ្លុះបញ្ចាំងអំពីកេរដំណែលនិងការ

ចងចាំរបស់អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។ ខ្លឹមសារនៃការសម្តែងឆ្នាំនេះក្រោមប្រធានបទ «កេរដំណែលនៃក្តីសង្ឃឹម» គឺចំពេលខួបលើកទី៦៥ឆ្នាំ នៃការរំដោះជំរំឃុំខ្លួនអូស្វីច បើកេណូ ដោយកងទ័ពសូវៀត ។ ក្នុងទិវារំឭកខួបលើកទី១០ និងតាងនាមឲ្យក្រុមការងារដើម្បីថែរក្សានិងរំឭកដល់របបប្រល័យពូជសាសន៍ជ្វីហ្វនៅទីក្រុងញូវខាសល គោលបំណងនៃការសម្តែងនេះគឺដើម្បីលើកទឹកចិត្តមនុស្សគ្រប់វ័យទាំងអស់ដើម្បីចូលរួមទស្សនាប្រកបដោយគតិបណ្ឌិត អារម្មណ៍រំជើបរំជួល និងកាយវិការក្នុងគោលបំណងស្វែងរកការយល់ដឹងបន្ថែមអំពីភាពមហន្តរាយដែលញាំញីដោយអំពើប្រល័យពូជសាសន៍ ។ កម្មវិធីនៃការសម្តែងដែលទាក់ទងនិងជ្រៅជ្រែងដល់ព្រឹត្តិការណ៍រំឭកដល់របបប្រល័យពូជសាសន៍ជ្វីហ្វនៅទីក្រុងញូវខាសលបានប្រើប្រាស់ទម្រង់សិល្បៈនៃរោងសម្តែងជាកន្លែងសម្រាប់អ្នកសម្តែង វាគ្មិន និងទស្សនិកជនដើម្បីឲ្យអ្នកទាំងអស់នោះចូលរួមចែករំលែកការចងចាំនិងបទពិសោធន៍ដែលខ្លួនជួបប្រទះ ។

វេទិកានេះគឺដើម្បីផ្តល់ឱកាសដល់សាធារណជនទូទៅដើម្បីឲ្យយល់ពីសក្ខីកម្មផ្ទាល់ខ្លួន ដែលមនុស្សម្នាក់ៗមានការទទួលខុសត្រូវរួមមួយក្នុងនាមជាមនុស្សដើម្បីបញ្ចប់ទាំងស្រុងនូវអំពើប្រល័យពូជសាសន៍ ។ ទីជម្រកស្នាក់នៅ និងទីស្ថានដើម្បីរំឭកដល់ការចងចាំជាកន្លែងដែលយើងរីករាយដល់ការរស់នៅរបស់យើង យើងក៏ចងចាំដល់អ្នកដែលបានបាត់បង់និងកាន់ទុក្ខដល់អ្នកដែលបានស្លាប់ដែរ ។ ខ្ញុំមានជំនឿថា អ្នកទាំងអស់គ្នាគឺជាសាក្សី ជាបណ្ណារក្សដ៏ហ្មត់ចត់ម្នាក់ដែលកំពុងអានរឿងរ៉ាវអំពីភាពខ្មៅងងឹតនៃអតីតកាលរបស់មនុស្សជាតិកំពុងតែស្រាវជ្រាវរកកំណត់ហេតុអំឡុងបច្ចុប្បន្នកាល និងប្រមូលទុកឯកសារការពិតសម្រាប់អនាគត ។ ក្នុងនាមតួនាទីជាប្រធានផ្នែកសិល្បៈ ខ្ញុំអាចមានលទ្ធភាពជួបនិងសន្ទនាផ្ទាល់ជាមួយអ្នកនយោបាយនិងមនុស្សដែលមានកេរ្តិ៍ឈ្មោះនៅក្នុងជួរថ្នាក់ដឹកនាំរបស់ទីក្រុងញូវខាសល ។ មនុស្សម្នាក់ដែលខ្ញុំបានជួបជាមួយគឺលោក ចន ស៊ីប្លេ ដែលជាប្រធានក្រុមប្រឹក្សាក្រុងញូវខាសល ។ ខ្ញុំបានសួរសំនួរទៅកាន់លោក ស៊ីប្លេ ចំនួនប្រាំសំនួរដោយយោងតាមទស្សនកិច្ចខ្លីៗរបស់ខ្ញុំ ដើម្បីផ្ញើទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរួមចំណែកសរសេរសម្រាប់ទស្សនាវដ្តីស្វែងរកការពិត ។

**សូមលោករៀបរាប់ដោយសង្ខេបអំពីតួនាទីនិងមុខងាររបស់លោកក្នុងនាមជាប្រធានក្រុមប្រឹក្សាក្រុង ញូវខាសល?**

ខ្ញុំដឹកនាំទូទៅក្នុងជួរថ្នាក់ដឹកនាំនយោបាយនៅក្នុងក្រុមប្រឹក្សានិងទីក្រុងញូវខាសលទាំងមូល ដោយចេញជាគោលការណ៍នយោបាយនិងអនុវត្តនូវគោលនយោបាយទាំងនោះ ។ ខ្ញុំជាអ្នកតំណាងឲ្យក្រុមប្រឹក្សាទាំងមូលនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ។

**សូមលោករៀបរាប់អំពីដំណើរទស្សនកិច្ចរបស់លោកទៅកាន់ប្រទេសកម្ពុជា និងតើដំណើរទស្សនកិច្ចនោះបានប៉ះពាល់អ្វីខ្លះដល់រូបលោកផ្ទាល់និងភរិយារបស់លោក ។**

យើងបានចំណាយពេលជាច្រើនថ្ងៃនៅប្រទេសកម្ពុជាកាលពីខែមេសា ឆ្នាំ២០០៩ ដោយកាលនោះខ្ញុំបានទៅលេងប្រទេសវៀតណាម និងប្រទេសឡាវ ។ ដំណើរទស្សនកិច្ចនោះបានជះឥទ្ធិពលដល់យើងយ៉ាងខ្លាំង ។ យើងមានការស្ញប់ស្ញែងដល់ប្រវត្តិសាស្ត្រដ៏វែងឆ្ងាយរបស់ប្រទេសកម្ពុជា ជាពិសេសដល់កេរដំណែលដ៏គួរឲ្យសរសើរនៃប្រាសាទអង្គរវត្ត ។ យើងមានការស្ញប់ស្ញែងដល់ការគោរពដ៏កក់ក្តៅពីសំណាក់ប្រជាជនកម្ពុជាដែលកំពុងតែស្វះស្វែងរកអនាគតឲ្យប្រសើរជាងនេះសម្រាប់ខ្លួនគេផ្ទាល់ និងសម្រាប់គ្រួសារ ។ យើងមានការរំជួលចិត្តដោយសារតែយើងបានឃើញនូវអ្វីដែលបានកើតឡើងកាលពីសម័យ ប៉ុលពត ហើយយើងមានអារម្មណ៍ខ្មាស់ខ្លួនឯងដោយសារតែប្រទេសយើងខ្វះការធ្វើអន្តរាគមន៍ដើម្បីបញ្ឈប់របបប្រល័យពូជសាសន៍នោះបាន ។ យើងមានអារម្មណ៍អស់សង្ឃឹមដែលថា ហេតុអ្វីមនុស្សធ្វើបាបមនុស្សដូចគ្នាយ៉ាងនេះ ហើយអារម្មណ៍របស់យើងប៉ះពាល់យ៉ាងខ្លាំងដោយសារពេលដែលយើងទៅមើលសារមន្ទីរទួលស្លែងនិងវាលពិឃាតជើងឯក ។ មនុស្សម្នាក់ៗដែលយើងជួបសុទ្ធតែមានរឿងរ៉ាវផ្ទាល់ខ្លួនដើម្បីប្រាប់យើង ហើយរឿងរ៉ាវទាំងនោះសុទ្ធតែគួរឲ្យព្រឺខ្លាច ។ រឿងខ្លះគឺជារឿងបុគ្គលដែលធ្វើឲ្យប៉ះពាល់យ៉ាងធំសម្បើមដល់បុគ្គលនោះ ។ រូបថតជនរងគ្រោះជាច្រើនសន្លឹកដែលដាក់តាំងនៅទួលស្លែងធ្វើឲ្យភរិយារបស់ខ្ញុំមានចិត្តសង្វេគយ៉ាងខ្លាំង ដោយសារតែក្មេងទាំងនោះមានអាយុស្របាល

គ្នាជាមួយនឹងកូនរបស់យើងដែរឈ្មោះ ចូណាថាន់ កាលពីពេលនោះ ។ ភរិយារបស់ខ្ញុំកាន់តែសង្វេគថែមទៀតនៅពេលដែលខ្ញុំចង្អុលទៅរូបថតជនរងគ្រោះម្នាក់ដែលមានអាយុស្របាលគ្នាជាមួយនឹងចៅស្រីរបស់យើងដែរ ។ នេះជារឿងកំសត់ណាស់សម្រាប់យើងហើយ ពេលឥឡូវនេះយើងនូវតែមានអារម្មណ៍នេះដដែល ។

**សូមលោករៀបរាប់អំពីសារសំខាន់និងការពាក់ព័ន្ធចំពោះពាក្យ «ការពិត» ។ តើពាក្យនេះមានន័យយ៉ាងណាចំពោះខ្លួនលោកផ្ទាល់និងចំពោះតួនាទីរបស់លោកជាប្រធានក្រុមប្រឹក្សាក្រុងដែលត្រូវបានជ្រើសរើសដោយសំឡេងឆ្នោតនោះ?**

ការពិតគឺជាមូលដ្ឋានគ្រឹះចំពោះទំនាក់ទំនងទាំងឡាយរវាងបុគ្គលផ្ទាល់ខ្លួន ឬរវាងមនុស្សផ្សេងៗ និងរវាងមេដឹកនាំរបស់ខ្លួន ។ អស់ជាច្រើនសម័យកាលមកហើយ ការពិតគឺជាមូលដ្ឋានគ្រឹះនៃជីវិតគ្រួសារ តែមានការការពារនិងរដ្ឋាភិបាលល្អ ។ ការពិតជាភាពសុចរិត ការជឿជាក់ យុត្តិធម៌ សេរីភាព និងការគោរព ហើយការពិតក៏ជាមូលដ្ឋាននៃសង្គមស្ថិរភាពមួយ ។ ប៉ុន្តែពាក្យនេះត្រូវតែមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ លោក ហេនរី ដេវីដ ថូរ៉ូ ដែលជាអ្នកនិពន្ធនៅសហរដ្ឋអាមេរិក កាលពីសតវត្សរ៍ទី១៩ បាននិយាយថា «ត្រូវតែមានពីរដើម្បីនិយាយការពិតមួយគឺអ្នកនិយាយ និងមួយទៀតគឺអ្នកស្តាប់» ។

**សូមលោករៀបរាប់អំពីសារសំខាន់និងការពាក់ព័ន្ធចំពោះពាក្យ «ការចងចាំ» ។ តើពាក្យនេះមានន័យយ៉ាងណាចំពោះខ្លួនលោកផ្ទាល់និងចំពោះតួនាទីរបស់លោកជាប្រធានក្រុមប្រឹក្សាក្រុងដែលត្រូវបានជ្រើសរើសដោយសំឡេងឆ្នោតនោះ?**

ការចងចាំគឺប្រឈមមុខទៅនឹងអតីតកាលដោយការពិតដើម្បីតាមគន្លងនៃការបង្រួបបង្រួមដែលអាចនាំទៅរកការផ្លាស់ប្តូរនិងនាំទៅរកអនាគតដ៏ប្រសើរ ។ ពាក្យនេះគឺជាដំណាក់កាលនៃការវាយតម្លៃទង្វើពីអតីតកាលដោយប្រឈមមុខទៅនឹងកំហុសនិងការធ្វើល្អដើម្បីអនាគត ។

**សូមលោកផ្តល់ឃ្លាសំខាន់ណាមួយសំខាន់ឬឃ្លារបស់អ្នកផ្សេងដែលឆ្លុះបញ្ចាំងពីសារសំខាន់នៃការពិតនិងការចងចាំនៅក្នុងសង្គមនាពេលបច្ចុប្បន្ន ។**

ខ្ញុំពេញចិត្តឃ្លារបស់លោក ហ្វ្រង់ស្វ័រ វ៉ុលទែ ដែលរៀបរាប់ថា «មនុស្សម្នាក់ៗជំពាក់ការគោរពចំពោះអ្នកដែលនៅរស់ ប៉ុន្តែចំពោះអ្នកដែលបានស្លាប់ហើយ មនុស្សម្នាក់ៗមិនជំពាក់អ្វីទាំងអស់ តែត្រូវជំពាក់ការពិត» ។

**ចេន អានហ្វីល**

# ដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ទោសមេដឹកនាំខ្មែរក្រហម

មកទល់នឹងពេលបច្ចុប្បន្ន គម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញប្រជាជនមកចូលរួមស្វែងយល់ក្នុងដំណើរការស្វែងរកយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំនួនប្រមាណ៦៩០០នាក់រួចមកហើយ ។ នៅដើមឆ្នាំ២០០៩ គម្រោងឯកសាររស់បានឈានមួយជំហានទៀតក្នុងការផ្តល់ឱកាសឲ្យប្រជាជនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ នៅរៀងរាល់ការបើកសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងអញ្ជើញអ្នកតំណាងមកពីស្រុកភូមិនានាទូទាំងប្រទេសមកឃ្លាំមើលដំណើរការនេះ ។ បន្ថែមពីលើការចូលរួមស្តាប់សវនាការ អ្នកតំណាងទាំងនោះនឹងបានចូលរួមក្នុងវគ្គបំពាក់បំប៉នដើម្បីទទួលចំណេះដឹងផ្សេងៗទាក់ទងទៅនឹងទ្រង់ទ្រាយនៃតុលាការច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តួនាទីនៃសហព្រះរាជអាជ្ញា ចៅក្រម និងចៅក្រមស៊ើបអង្កេត ភាពខុសគ្នានៃទម្រង់សវនាការ ព្រមទាំងទស្សនាខ្សែភាពយន្តឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។

អាស្រ័យហេតុនេះ ប្រសិនបើអស់លោកអ្នកមានបំណងចូលរួមក្នុងកម្មវិធីអង្កេតមើលសវនាការឬដំណើរទស្សនកិច្ចដើម្បីស្វែងយល់ពីការកាត់ក្តីមេដឹកនាំខ្មែរក្រហមសូមទាក់ទង ស៊ុំ សាវីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១២ ៦៨៨ ០៤៦ ។

# ការអង្កេតនៅលើការប្រកាសសាលក្រម ឌុច

ខ្ញុំបានចូលរួមក្នុងសវនាការកាត់សេចក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរស-២១ដែលជាមន្ទីរឃុំឃាំង និងធ្វើទារុណកម្មរបស់ខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហមពីឆ្នាំ ១៩៧៥ដល់១៩៧៩ ប្រជាជនប្រមាណ១៦០០០នាក់ត្រូវបានបញ្ជូនទៅស-២១ (បច្ចុប្បន្នគឺជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង) មានតែអ្នកទោស១៧នាក់ប៉ុណ្ណោះត្រូវបានគេដឹងថានៅរស់ ។ នៅថ្ងៃទីមួយដែលខ្ញុំបានចូលរួមសវនាការ គឺថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ សាក្សី ហ៊ឹម ហ៊ុយ អតីតអ្នកយាមនិងអ្នកដែលត្រូវបានចោទប្រកាន់ថាជាអ្នកសម្លាប់ឡើងផ្តល់សក្ខីកម្ម ។ មានសំណួរសួរទៅគាត់ថាតើមានអ្នកណាម្នាក់ធ្លាប់ចេញពីស-២១ដែរឬទេ? ឬថាតើអ្នកទាំងនោះបានត្រឹមតែចូលទៅ? ហ៊ឹម ហ៊ុយ បាននិយាយតបថា មិនមាននរណាម្នាក់អាចចាកចេញមកក្រៅទេ អ្នកទាំងនោះបានត្រឹមតែចូល បន្ទាប់មកគឺចប់ ។

ក្រោយមក ក៏មានឮសំឡេងខ្សឹបគ្នាពីបណ្តាំកសិករចំនួន ៣៥០នាក់មកពីខេត្តកំពង់ធំដែលមកចូលរួមក្នុងសវនាការនៅថ្ងៃនោះ ។ អ្នកទាំងនោះមិនមានភាពភ្ញាក់ផ្អើលចំពោះការនិយាយសម្រាលនោះទេ ។ អ្នកទោសទាំងនោះមិនទាន់ចប់ទេ ។ អ្នកទាំងនោះត្រូវបានសម្លាប់ ឬ «កម្ទេច» បើប្រើតាមពាក្យរបស់ខ្មែរក្រហម ។

លើកទីពីរដែលខ្ញុំបានចូលរួមក្នុងសវនាការគឺថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ ឌុច ត្រូវបានសម្រេចឲ្យជាប់ទោសពីបទល្មើសប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្មសង្គ្រាមហើយត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ១៩ឆ្នាំទៀត (សរុប៣៥ឆ្នាំ) ។ ខ្ញុំធ្លាប់ជាអ្នកគាំទ្រនឹងទស្សនៈរបស់តុលាការដែលស្របនឹងការអះអាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលថា «ការស្វែងរកការពិត និងការបង្ហាញពីអ្វីដែលបានកើតឡើងគឺជាមធ្យោបាយដ៏ល្អបំផុតសម្រាប់ទប់ស្កាត់អំពើហិង្សាមិនឲ្យកើតមានម្តងទៀត ។ ប៉ុន្តែបន្ទាប់ពីថ្ងៃនោះខ្ញុំមានអារម្មណ៍ចម្រុះគ្នាទាក់ទងនឹងការកាត់សេចក្តី ។ ម្យ៉ាងខ្ញុំមានអារម្មណ៍មិនពេញចិត្តដែលថា ឌុច ស្ថិតនៅចំណុចកណ្តាលនៃការកសាងប្រវត្តិសាស្ត្រនៅពេលនោះ ។ ម្យ៉ាងទៀត ខ្ញុំមានអារម្មណ៍ពេញចិត្តនឹងសាលក្រមគឺថានៅទីបំផុតមានមនុស្សត្រូវបានរកឃើញថាមានទោស ហើយតុលាការបានសម្រេចថាអ្វីដែលបានកើតឡើងគឺជារឿងខុសច្បាប់ ជាក់ស្តែងសកម្មភាពនោះមិនត្រឹមតែប្រឆាំងនឹងប្រជាជនកម្ពុជាទេ តែថែមទាំងប្រឆាំងនឹងមនុស្សគ្រប់រូប ។

ខ្ញុំគិតថាសវនាការ ឌុច ពិតជាមានតម្លៃណាស់ ។ អ្នកដទៃទៀតដូចជា នួន ជា (បងធំទី២បន្ទាប់ពី ប៉ុល ពត) អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ប្រាកដជានឹងថាមិនមែនខ្លួនគេទេ តែគឺ ប៉ុល ពត ឬ សុន សេន ឬអ្នកផ្សេងទៀតដែលបានស្លាប់ និងមិនអាចនៅការពារខ្លួនបាន ។ នេះដោយសារតែមានតែ ឌុច បានសម្រេចសារភាពកំហុសនិងប្រាប់អ្វីដែលបានកើតឡើងនៅក្នុងសុបិនដ៏អាក្រក់កាលពី៣០ឆ្នាំមុន ។ ឌុច បានផ្លាស់ប្តូរទៅកាន់សាសនាគ្រិស្តវិញក្បែរព្រំដែនថៃ ។ នៅពេលដែលអ្នកសារព័ត៌មាន នីក ឌុន លុប បានជួប ឌុច គាត់បាននិយាយថា «ព្រះគឺជាអ្នករៀបចំឲ្យខ្ញុំមកទីនេះ ។ បច្ចុប្បន្ន អនាគតរបស់ខ្ញុំគឺស្ថិតនៅក្នុងដៃរបស់ព្រះ» ។ ឌុច បានសុំទោសជាសាធារណៈ ។ នៅឯរណ្តៅសពរបស់អ្នកទោសស-២១ដែលត្រូវបានសម្លាប់នៅជើងឯកដែល ឌុច បានទៅទីនោះមុនពេលសវនាការ គាត់បានយំ ។ នៅពេលដែលខ្ញុំបានឮគំនិតនេះ ខ្ញុំគិតថា តុលាការមានតម្លៃពីព្រោះនៅទីបញ្ចប់មានមនុស្សបង្ហាញពីភាពសោកស្តាយចំពោះការសម្លាប់ ។ ការផ្លាស់ប្តូរទៅជាអ្នកសាសនាគ្រិស្តពិតជាមានន័យ ។ នៅក្នុងព្រះពុទ្ធសាសនាមិនមានទស្សនៈអត់ឱនទោសទេគឺមានតែធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ហើយមិនមានព្រះអត់ឱនទោសទេ ។ មានតែការផ្លាស់ប្តូរទៅកាន់សាសនាគ្រិស្តទើបអាចធ្វើឲ្យ ឌុច អាចចៀសផុតនូវលទ្ធផលដែលខ្លួនបានធ្វើ ។ ឌុច ហាក់ដូចជាសហការជាមួយតុលាការ ។ សវនាការរបស់តុលាការធ្វើឡើងនៅក្រោយកញ្ចក់ ដូច្នេះអ្នកអង្កេតការត្រូវមើលទៅក្នុងជារៀងរាល់ថ្ងៃដូចជាមើលទៅអ្នកសម្តែងនៅឆាកឬកញ្ចក់បញ្ចាំងដូច្នោះដែរ ។ អ្នកអាចស្តាប់ឮនូវដំណើរការនីតិវិធីជាភាសាខ្មែរ ឬអង់គ្លេស ឬបារាំងតាមរយៈ

ប្រដាប់ស្តាប់សំឡេងដែលអាចផ្តល់ការបកប្រែនៅពេលតែមួយ ។ ឌុច ដែលជាជនត្រូវចោទអង្គុយនៅខាងស្តាំ ។ នៅលើស្បែករបស់ ឌុច មានចំណុចលឿង ប៉ុន្តែគាត់មាំ ។ ឌុច ហាក់ដូចជាមើលទៅដំណើរការនីតិវិធីដោយមិនសូវសកម្មគឺហើយក្រឡេកមើលសាក្សីដោយយកចិត្តទុកដាក់ ។ ឌុច បានញាក់ដៃដើងសន្តត់ចុងគុ ដែលជាសញ្ញាណបញ្ជាក់ថា គាត់ប្រហែលជាភ័យជាងមុន ។ ជារឿយៗ ឌុច បានក្រឡេកមើលទៅអ្នកចូលរួម សវនាការនៅខាងក្រោមមួយភ្លែត ។ ឌុច មានភ្នែកភ្លឺ ។ វ៉ាន់ ណាត អ្នកគូរគំនូរដ៏ល្បីល្បាញ និងអ្នកនៅរស់ពីស-២១បាននិយាយជាមួយខ្ញុំថា អ្នកដឹងទេ ឌុច គឺជាបញ្ញវន្តម្នាក់ហើយគាត់មានពេលជាច្រើន (ពីឆ្នាំ១៩៩៩ នៅពេលដែលគាត់ចាប់ផ្តើមជាប់ឃុំ) ដើម្បីត្រៀមថា តើគាត់នឹងត្រូវឆ្លើយតបនឹងគ្រប់ភ័ស្តុតាងដោយរបៀបណា ។ គាត់បានត្រៀមគ្រប់ចម្លើយ ។ ឌុច ស្ថិតនៅចំកណ្តាលនៃការសម្តែង ហើយនៅក្នុងករណីខ្លះគាត់ពេញចិត្តហើយបានសម្រេចដើរតួ ។ ដូច្នេះអ្វីទៅជាបញ្ហា? ហេតុអ្វីក៏ខ្ញុំយល់ថាវាវិខានម្ល៉េះ?

ទោសកំហុសរបស់ ឌុច គឺច្បាស់ណាស់ ។ ឌុច បានសារភាពថាគាត់ជាប្រធានមន្ទីរស-២១ ។ គាត់បាននិយាយថា «ខ្ញុំជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើទាំងឡាយដែលកើតឡើងនៅស-២១» ។ ហត្ថលេខានិងស្នាមម្រាមដៃរបស់ ឌុច មាននៅគ្រប់ឯកសារទាំងអស់ ។ ខ្ញុំបានធ្វើការប្រាំមួយខែនៅបណ្ណសារដ្ឋានទួលស្លែងនៅឆ្នាំ១៩៩០ដោយធ្វើកាតាឡុកឯកសារនិងថតជាម៉ៃក្រូហ្វីល ។ ខ្ញុំបានឃើញយោបល់របស់គាត់សរសេរនៅគែមថា «សួរពីនេះ» «ជននោះកំពុងតែកុហកទេ» ហើយអ្វីដែលអាក្រក់ជាងគេនោះគឺ «កម្ទេចចោលទាំងអស់» ។ ឌុច បានសារភាពថាគាត់មានទិសដៅតិចតួចប៉ុណ្ណោះក្នុងការបង្កើតនិងដំណើរការស-២១ ។ ឌុច គឺជាអ្នកនៅពីក្រោយការធ្វើទារុណកម្មនិងការសម្លាប់ ទោះបីជាគាត់បាននិយាយថាគាត់ដឹងថាព័ត៌មានដែលបានចេញពីការសួរចម្លើយដោយការធ្វើទារុណកម្មនៅពេលនោះមិនពិតក៏ដោយ ។ អ្នកទោសត្រូវបានវាយធ្វើបាប ឆក់ខ្សែភ្លើង ជ្រមុជទឹកនិងបង្អត់អាហាររហូតដល់សារភាពថាខ្លួនគឺជាភ្នាក់ងារសេ.អ៊ី.អា, កាហ្សេបេ ដែលមានផែនការផ្តួលរំលំបដិវត្តន៍ ។ បន្ទាប់មក អ្នកទាំងនោះត្រូវបានសម្លាប់ទាំងអស់ ។ យើងមានសៀវភៅដែលសរសេរដោយ ដេវីដ ឆេនដល័រ និងភាពយន្តដែលផលិតដោយ រិទ្ធី ប៉ាន់ ដែលស្តីអំពី «ស-២១» អាចធ្វើឲ្យយើងអាចស្រមើស្រមៃឃើញនូវអ្វីដែលបានកើតឡើង ។ ប៉ុន្តែតាមសក្ខីកម្មរបស់អ្នកផ្តល់សក្ខីកម្មម្នាក់ៗនៅឯតុលាការ ឌុច និងមេធាវីរបស់គាត់មានឱកាសសួរសំណួរសាក្សីនិងពិចារណាទៅលើគ្រប់ចំណុចនៃសក្ខីកម្ម ។ ដូច្នេះភាពជឿជាក់របស់សក្ខីកម្មនោះក្លាយទៅជាបាត់បង់តម្លៃ ។ បន្ទាប់ពី៣០ឆ្នាំ ការចងចាំបានថយចុះ ។ តើ ឌុច បានបញ្ជាឲ្យកម្ទេចបុរសស្ត្រីនិងក្មេងចំនួន ១៦,០០០នាក់ ឬត្រឹមតែ១២,០០០នាក់? តើ ឌុច ធ្លាប់ទៅវាលពិឃាតជើងឯកម្តងឬពីរដងឬច្រើនដង? តើ ឌុច ធ្លាប់ដែលសម្លាប់នរណាម្នាក់ដោយផ្ទាល់ ឬក៏គ្រាន់តែបញ្ជាឬគ្រប់គ្រងលើការសម្លាប់? ខណៈពេលដែល ឌុច បានឆ្លើយយល់ស្រប ឬបដិសេធសាក្សី វាហាក់ដូចជាថាគាត់គឺជាមនុស្សម្នាក់ដែលសម្រេចទៅលើប្រវត្តិនៅសម័យនោះ ។ ប្រសិនបើ ឌុច បញ្ជាក់ទៅលើសក្ខីកម្មមួយថាត្រឹមត្រូវទើបសក្ខីកម្មនោះត្រឹមត្រូវ ។

បន្ទាប់មកមានបញ្ហាទាក់ទងនឹងភាសា ។ សវនាការដែលឮតាមរយៈប្រដាប់ស្តាប់សំឡេងនិងសវនាការជាខ្មែរមិនដូចគ្នាទេ ។ ខ្ញុំបានតាមដានសវនាការតាមប្រព័ន្ធបណ្តាញអ៊ិនធឺណែតជាច្រើនខែតាមរយៈគេហទំព័រ www.cambodiatribunal.org ។ នៅពេលដែល ហ៊ឹម ហ៊ុយ និយាយអំពីមនុស្សដែលត្រូវបានឃុំឃាំងនៅស-២១ គាត់បានហៅអ្នកទាំងនោះថាអ្នកទោសឬអ្នកត្រូវបានកាត់ទោសដែលមានន័យថាអ្នកដែលត្រូវបានសម្រេចថាមានទោស ។ ប៉ុន្តែនៅពេលដែលបកប្រែជាភាសាអង់គ្លេស វាទៅជាអ្នកជាប់ឃុំឃាំងទៅវិញ ។ អត្ថន័យរបស់វាមិនដូចគ្នាទេ ។ ពាក្យទីមួយដែលមិនទាន់បកប្រែមានន័យថាមនុស្សដែលត្រូវឃុំឃាំងនិងសម្លាប់នៅស-២១ ទាំងអស់គឺមានទោសពីបទអ្វីមួយ ។ ប៉ុន្តែពាក្យទីពីរដែលត្រូវបានបកប្រែហើយមានន័យថាអ្នកដែលមិនទាន់ត្រូវបានសម្រេចថាមានទោសទេ ។ នៅពេលដែលអ្នកទោសត្រូវបានធ្វើទារុណកម្មអ្នកទាំងនោះត្រូវបានសួរថាតើអ្នកបានធ្វើអ្វីខ្លះក្បត់នឹងបដិវត្តន៍? អង្គការមិនដែលខុសទេ ដូច្នេះអ្នកឯងពិតជាមានទោស តើអ្នកឯងមានខុសអ្វី? ភាសារបស់អតីតអ្នកយាមនិងអ្នកសម្លាប់នៅតែមានទំនោរដដែលទោះបីជាវាត្រូវបានកែប្រែដោយការបកប្រែក៏ដោយ ។ ហើយនៅពេលដែល ឌុច និយាយពីសាក្សីគាត់

អាចរិះគន់អ្នកទាំងនោះ បដិសេធមិនទទួលស្គាល់អ្នកទាំងនោះ និងវាយប្រហារអ្នកទាំងនោះតាមរយៈការប្រើប្រាស់ភាសា ជាឧទាហរណ៍តាមរយៈបន្ថែមពាក្យ «អា» ពីមុខឈ្មោះរបស់អ្នកទាំងនោះ ។ វាមិនមានការបកប្រែជាពាក្យចំទៅជាភាសាអង់គ្លេសទេ ប៉ុន្តែអ្នកស្រាវជ្រាវតែងតែប្រើពាក្យម្យ៉ាង «The despicable» ដែលមានន័យថា «អា» ដូចជា «អាពត» ។ នៅអំឡុងពេលនិយាយគំរាមកំហែង ឌុច បានចង្អុលដៃនិងតម្លើងសំឡេង ។ នេះមិនមានជាឥរិយាបថរបស់បុរសដែលចង់សម្តែងការសុំទោសចំពោះបទល្មើសរបស់ខ្លួនទេ ។ នេះគឺជាបុរសម្នាក់មកពីទសវត្សរ៍៧០ គ្រូបង្រៀនគណិតវិទ្យា ដែលបានក្លាយទៅជាអ្នករៀបចំផែនការដឹកប្រុសគល់អ្នកដែលអាចជះឥទ្ធិពលដល់បដិវត្តន៍ពោលគឺជាអ្នកកម្ទេចអ្នកទាំងនោះ ។ វាក្លាយទៅជាការបកប្រែទៅជាភាសាអង់គ្លេសដែលគួរសមគឺ «Mr.» «លោកនេះ លោកនោះ» ។ យើងមានការភ័ន្តច្រឡំចំពោះការមិនគោរពរបស់ ឌុច ទៅលើអ្នកនៅក្រោមបង្គាប់របស់គាត់និងអតីតអ្នកទោស ។

អ្វីដែលរំខានខ្ញុំខ្លាំងជាងគេនោះគឺដូចនឹងអ្វីដែលស្ត្រីម្នាក់មកពីខេត្តកំពង់ធំចាប់អារម្មណ៍ដូច្នោះដែរ ។ នៅពេលសម្រាកបាយថ្ងៃត្រង់ ខ្ញុំបានដើរពីក្រោយស្ត្រីពីរនាក់ដែលធ្វើដំណើរដ៏វែងឆ្ងាយមកចូលរួមក្នុងសវនាការនោះ ។ មានស្ត្រីម្នាក់បែរទៅស្ត្រីម្នាក់ទៀតហើយនិយាយថា «អត់ចេះខ្មាស» ។ ប្រសិនបើ ឌុច ពិតជាបង្ហាញនូវភាពសោកស្តាយមែន តាមទំនៀមទម្លាប់ខ្មែរ គាត់គួរតែមើលចុះទៅក្រោមមិនប្រើក្រសែភ្នែកមើលអ្នកដទៃ ហើយបង្ហាញពីការសុំទោសរបស់គាត់ទេ ។ ឌុច គួរតែបង្ហាញថាគាត់មានភាពអៀនខ្មាសចំពោះអ្វីដែលគាត់បានធ្វើ ។ ប៉ុន្តែគាត់បែរជាត្រៀមខ្លួនតទល់និងវាយប្រហារអ្នកដែលផ្តល់សក្ខីកម្មប្រឆាំងនឹងគាត់ទៅវិញ ។

នៅពេលដែលខ្ញុំធ្វើដំណើរមកភ្នំពេញវិញជាមួយក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខ្ញុំបានសួរនារីម្នាក់ដែលមានអាយុប្រហែល២០ អំពីការយល់ឃើញរបស់គាត់ចំពោះដំណើរការនីតិវិធីនៅថ្ងៃនោះ ។ នារីម្នាក់នោះបាននិយាយថាគាត់មានអារម្មណ៍ភ្ញាក់ផ្អើលណាស់ ។ គាត់មានអារម្មណ៍រន្ធត់ចំពោះរឿងរ៉ាវដែលថាក្មេង៦០នាក់ត្រូវបាន «សម្លាប់» ដោយត្រូវបានបោកក្បាលនឹងដើមឈើ ។ នារីនោះបានយំហើយបានបែរមុខទៅបង្អួចដើម្បីរំងាប់ចិត្ត ។ សក្ខីកម្មនៅថ្ងៃនោះមិនបានធ្វើឲ្យខ្ញុំមានភាពភ្ញាក់ផ្អើលអ្វីទេ ។ ខ្ញុំធ្លាប់បានអានពីរឿងនេះរួចទៅហើយ ។ ហ៊ីម ហ៊ុយ បានរៀបរាប់នូវរាល់ដំណាក់កាលសម្លាប់ពីរបៀបចង់មុខដាក់ច្រវាក់និងដឹកតាមរថយន្ត របៀបវាយពីក្រោយក្បាល ដើម្បីឲ្យអ្នកទាំងនោះរមៀលធ្លាក់ចូលរណ្តៅ ប៉ុន្តែគាត់មិនបាននិយាយពីតួនាទីរបស់គាត់ជាពេជ្ឈឃាតទេ ។

វ៉ាន់ ណាត នៅក្នុងសៀវភៅរបស់គាត់ដែលរៀបរាប់ពីជីវិតនៅស-២១ បានបង្ហាញពីការប្រឈមមុខរបស់គាត់នឹង ហ៊ីម ហ៊ុយ នៅឆ្នាំ១៩៩៦ ។ ហ៊ីម ហ៊ុយ បានសារភាពថាបានសម្លាប់មនុស្សប្រួនប្រាំនាក់ ហើយនិយាយថាគាត់ធ្លាប់តែជាអ្នកយាមប៉ុណ្ណោះមិនមែនជាពេជ្ឈឃាតទេ ។ វ៉ាន់ ណាត បានចោទ ហ៊ីម ហ៊ុយ ថានិយាយកុហកហើយនិយាយថាមនុស្សចំនួន២០០០នាក់ដែលពីមុន ហ៊ីម ហ៊ុយ បានសារភាពថាបានសម្លាប់គឺនៅមិនទាន់ច្រើនល្មមទេ ។ បន្ទាប់មក វ៉ាន់ ណាត បានសួរ ហ៊ីម ហ៊ុយ ពីរូបភាពដែលបង្ហាញនៅក្នុងរូបគំនូររបស់ខ្លួនថាពិតឬទេ? ហ៊ីម ហ៊ុយ បានឆ្លើយតបថាឈុតឆាកដែលបង្ហាញនោះមិនមានភាពបំផ្លើសទេ ហើយនៅមានរឿងរ៉ាវខ្លះអាក្រក់ជាងនោះទៅទៀត ។ ក្រោយមក វ៉ាន់ ណាត បានសួរ ហ៊ីម ហ៊ុយ ពីទារកដែលគាត់បានកញ្ឆក់ពីដៃរបស់ម្តាយហើយថាតើអ្នកយកទារកនោះទៅណា? ហ៊ីម ហ៊ុយ ឆ្លើយថា យើងបានយកទារកទាំងនោះចេញនិងសម្លាប់ ។ វ៉ាន់ ណាត បានឆ្លើយតបថា «អ្នកបានសម្លាប់ទារកទាំងអស់នោះឬ? ម្ចាស់ថ្លៃអើយ» ។ បុរសម្នាក់ដែលបានចំណាយពេល១៧ឆ្នាំធ្វើជាសាក្សីជំនាញចំពោះរបបនោះនៅតែមានភាពរន្ធត់ចំពោះភាពព្រៃផ្សៃនៃការសម្លាប់ទារកដូចនារីវ័យក្មេងម្នាក់នៅក្នុងរថយន្តក្រុងដូច្នោះដែរ ។ វាពិតជាអាក្រក់ពេកហើយ ។ វ៉ាន់ ណាត តែងតែគិតថា ពេលខ្លះទារកនោះអាចនៅរស់ ។

ខ្ញុំគិតថាប្រតិកម្មរបស់ខ្ញុំនៅថ្ងៃទីមួយគឺមានភាពជាខ្មែរជាជាងអាមេរិក ។ យើងដែលជាអ្នកទទួលការចិញ្ចឹមបីបាច់នៅបស្ចិមប្រទេសចូលចិត្តមើលរូបភាពដែលចុងចោទនិយាយប្រឆាំងដោយចង្អុលម្រាមដៃទៅសាក្សី ។ យើងចូលចិត្តរូបភាព «ភើរីមែសុន (Perry Mason)» និង «ច្បាប់និងបញ្ញា» (Law and Order)

នៅក្នុងទូរទស្សន៍របស់អាមេរិកអំពីតុលាការ) ។ ជនជាតិអាមេរិក បាននិយាយប្រឆាំងគ្នាទៅវិញទៅមកនៅក្នុងតុលាការ ។ ប៉ុន្តែ ចំពោះការយល់ឃើញរបស់ខ្មែរ ឌុច គួរតែបង្ហាញថាគាត់មានការ សោកស្តាយដោយបង្ហាញការគោរពចំពោះអតីតជនរងគ្រោះមិន មែនដូចជាចង់តែប្រឆាំងទេ ។ តាមរយៈកាយវិការនិងពាក្យសម្តី ឌុច គួរតែបន្ទាបខ្លួននៅចំពោះមុខអ្នកទាំងនោះ ។ ឌុច នៅតែគិត ថាគាត់ប្រសើរជាងអ្នកទាំងនោះ ។ ចំពោះខ្មែរ វាហាក់ដូចជាថា ឌុច មិនបានបង្ហាញពីភាពសោកស្តាយដោយស្មោះទេ ។ នៅថ្ងៃ នោះ ខ្ញុំគិតថា ឌុច គឺជាបិសាច ។

នៅសវនាការថ្ងៃចុងក្រោយ ឌុច អង្គុយយ៉ាងស្ងៀមស្ងាត់ កាន់គម្ពីរមួយក្បាលខណៈពេលដែលចៅក្រមកំពុងអានសាលក្រម ថាគាត់មានទោសពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងឧក្រិដ្ឋកម្ម សង្គ្រាម ។ អ្វីដែលសំខាន់ជាងគេទៅទៀតនោះគឺនៅពេលដែល ចៅក្រមអានឈ្មោះ «ជនរងគ្រោះ»៖ ប៊ូ ម៉េង, ជុំ ម៉ី, និង ជិន ម៉េត ថាជាអ្នកនៅរស់ពីស-២១ប្តូស-២៤ ។ ឈិន ណាវី បាន បាត់បង់ប្តីឈ្មោះ ទា ហាវតឹក ។ ហាវ សោភា បានបាត់បង់ ឪពុកឈ្មោះ ជិន សៀ ។ ភីងហ៊ុត ស៊ុនថារី និង អ៊ឹម ស៊ុន្ទី បានបាត់បង់ឪពុកនិងប្តីឈ្មោះ ភីង តុន» និងផ្សេងទៀត ។ បន្ទាប់មក ឌុច បានបញ្ឈប់ជំហរស្ងៀមស្ងាត់របស់គាត់ដោយ ដឹកទឹកនិងមើលចុះទៅក្រោម ។ ឈ្មោះដែលចៅក្រមបានអាន មិនមែនគ្រាន់តែជាស្ថិតិទេ វាគឺជាឈ្មោះរបស់ប្តីឪពុកនិងម្តាយ ។

តុលាការបានរកឃើញថា ឌុច ត្រូវទទួលខុសត្រូវលើបទ ល្មើសជាបុគ្គលនៅស-២១គឺគាត់បានរៀបចំផែនការផ្ដួចផ្ដើមគំនិតនិង បញ្ជាលើឧក្រិដ្ឋកម្ម ។ សាលក្រមបានជំទាស់នឹងមេធាវីការពារក្តី ដែលថា ឌុច គ្រាន់តែធ្វើតាមបញ្ជាឬស្ថិតនៅក្រោមការគំរាមកំហែង ពីព្រោះថាការអះអាងទាំងនេះមិនគ្រប់គ្រាន់សម្រាប់ជំទាស់នឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ។

ប្រតិកម្មរបស់ខ្ញុំចំពោះសាលក្រមគឺថាការកាត់ទោសឲ្យ ជាប់ពន្ធនាគារចំនួន១៩ឆ្នាំគឺស្រដៀងនឹងមួយជីវិតដែរ ។ ឌុច នឹងស្លាប់នៅក្នុងគុក ។ ហើយករណីទីពីរប្រឆាំងនឹងអ្នកដទៃនឹង មិនអាចដំណើរការទៅមុខបានប្រសិនបើគ្មានកិច្ចសហការរបស់ ឌុច ។ គាត់គឺជាមនុស្សតែម្នាក់ដែលនិយាយពីការពិតដោយសារ ភាពថាគាត់ទទួលខុសត្រូវចំពោះការស្លាប់នៅស-២១និងនិយាយ ពីមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតនៅក្នុងករណី០០២ ។ ដូច្នេះ ខណៈ ពេលដែលខ្ញុំមិនពេញចិត្តថាយើងត្រូវតែផ្អែកលើអ្នកសម្លាប់ មនុស្សជាច្រើនដើម្បីប្រាប់ពីរឿងរ៉ាវ ខ្ញុំត្រូវតែសារភាពថាខ្ញុំ អរគុណដែល ឌុច ធ្វើដូចនេះ ។

**ថុង ឡេងខុង**



# បិសាចមនុស្សជាតិ ៖ តើមេដឹកនាំខ្មែរក្រហមអាចទទួលបានការអត់ឱនទោសដែរឬទេ?

ខ្ញុំមានសេចក្ដីសប្បាយរីករាយដែលកាលពីខែកញ្ញា ឆ្នាំ២០១០កន្លងទៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសថាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់នឹងត្រូវបានឃុំឃាំងរួមមាន នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍នៅក្នុងចំណោមបទល្មើសផ្សេងទៀត ។ ខ្ញុំសង្ឃឹមថា អ្នកទាំងនោះនឹងទទួលបានការកាត់ទោសដ៏យុត្តិធម៌និងការផ្ដន្ទាទោសដ៏ត្រឹមត្រូវតាមផ្លូវច្បាប់ ។ អ្វីដែលមេដឹកនាំទាំងនោះបានធ្វើមកលើប្រជាជនកម្ពុជាគឺហួសពីនរកទៅទៀត ។ អ្នកទាំងនោះគឺជាបិសាចមនុស្សជាតិ ។ ដូច្នេះតើអ្នកទាំងនោះអាចទទួលបានការអត់ឱនទោសពីប្រជាជនដែរឬទេ? ជនត្រូវចោទទាំងបួនរូបបាននិមន្តព្រះសង្ឃឲ្យមកមន្ទីរឃុំឃាំងដើម្បីធ្វើពិធីបង្សុកូលនៅក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ ។ នេះគឺជាការបញ្ជាក់មួយថាអ្នកទាំងនោះប្រហែលជាកំពុងតែចង់បានការអត់ឱនទោសសម្រាប់ជាតិក្រោយ ឬចង់បានអ្នកថែទាំនៅពេលដែលខ្លួនស្លាប់ ។ នៅថ្ងៃភ្ជុំបិណ្ឌ ប្រជាជនបានឧទ្ទិសអាហារឲ្យ «ប្រេត» (វិញ្ញាណឬខ្មោចអនាថា) ដែលប្រព្រឹត្តបាបដ៏ធ្ងន់ធ្ងរកាលនៅរស់ដែលបណ្ដាលឲ្យមិនអាចទៅចាប់ជាតិ ។ ភាពសាហាវឃោរឃៅនៃឧក្រិដ្ឋកម្មរបស់មេដឹកនាំខ្មែរក្រហមអាចធ្វើឲ្យអ្នកទាំងនោះក្លាយជា «ប្រេត» វេទនាជាងគេក្នុងចំណោមប្រេតអត់ឃ្លានដែលដើរតែលតោលគ្មានទិសដៅ ។ ប្រសិនបើមេដឹកនាំទាំងនោះអាចទទួលបានការអត់ឱនទោសពីអ្នកដែលនៅរស់ វាអាចកាត់បន្ថយបាបរបស់អ្នកទាំងនោះបន្ទាប់ពីស្លាប់ ។

ការអត់ឱនទោសមិនមែនជាការស្នើឲ្យមានការដោះលែងឬបញ្ឈប់ការកាត់ទោសពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ។ ការអត់ឱនទោសគឺជាបញ្ហាមួយដែលងាយនឹងរងឥទ្ធិពល ។ វាស្ទើតែមិនអាចជាពាក្យដែលអាចស្នើឲ្យជនរងគ្រោះឬសាធារណជនពិចារណាបាន ។ ប៉ុន្តែខ្ញុំចង់ឲ្យអ្នកទាំងនោះព្យាយាមធ្វើបែបនេះ ។ វានឹងមិនអាចផ្ដល់យុត្តិធម៌បន្ទាប់ពីអំពើប្រល័យពូជសាសន៍កើតឡើងទេ ។ ដោយមិនមានភាពយុត្តិធម៌បែបនេះប្រជាជនត្រូវរស់នៅក្នុងភាពអយុត្តិធម៌ ការចងគំនុំ កំហឹង និងភាពមិនសប្បាយចិត្ត ។ បញ្ហាផ្លូវចិត្តទាំងនេះបានជះឥទ្ធិពលអាក្រក់ដែលមិនអាចរកវិធីដោះស្រាយបានដល់អ្នកនៅរស់ គឺអាចបំផ្លាញអ្នកទាំងនោះពីខាងក្នុង ។ ស្រដៀងនឹងពាក្យស្លោកដែលខ្មែរក្រហមតែងតែនិយាយថា សត្រូវដែលអាក្រក់ជាងគេគឺជាជនបង្កប់ «ស៊ីរូងផ្ទៃក្នុង» ដែលខ្មែរក្រហមត្រូវតែកម្ទេច ។ ភាពសាហាវឃោរឃៅនៃអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហមបានបង្កើតជាបញ្ហាផ្លូវចិត្តដែលកើតនៅក្នុងចិត្តរបស់អ្នកដែលនៅរស់ ហើយដែលអាចបង្កឲ្យមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ។ ទោះបីជាអ្នកខ្លះមិនបានសារភាព ប្រជាជនខ្លះបានអត់ឱនទោសឲ្យជនដៃដល់រួចទៅហើយ ។

នៅពេលប្រកាសសាលក្រម ឌុច ខ្ញុំបានធ្វើដំណើរទៅខេត្តកំពង់ធំ ។ នៅទីនោះ ពីន គឺជាអតីតកម្មាភិបាលខ្មែរក្រហមនិងជាជនដៃដល់ ចំណែក ប៉ៃ គឺជាជនរងគ្រោះ ។ អ្នកទាំងពីរបានរស់នៅក្នុងភូមិជាមួយគ្នាអស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ ពីន មានជាប់ពាក់ព័ន្ធនឹងការសម្លាប់ប្ដីរបស់ ប៉ៃ ដែលជាជនពិការជើងម្ខាងនៅឆ្នាំ១៩៧៧ ។ ទោះបីជា ពីន មិនដែលសារភាពថាគាត់បានសម្លាប់ប្ដីរបស់ ប៉ៃ បទសម្ភាសន៍ដែលបានធ្វើជាមួយអ្នកទាំងពីរបានបង្ហាញពីរឿងរ៉ាវដ៏ឈឺចាប់ទាក់ទងនឹងការស្លាប់ប្ដីរបស់ ប៉ៃ ។ នៅខេត្តកំពង់ធំនៅពេលរសៀលមួយពេលមេឃស្រទុំ ពីន និងកម្មាភិបាលខ្មែរក្រហមផ្សេងទៀតបានដើរទៅផ្ទះរបស់ ប៉ៃ ចងដៃប្ដីរបស់គាត់និងសួរចម្លើយមួយភ្លែត បន្ទាប់មកនាំគាត់ទៅព្រៃដែលនៅមិនឆ្ងាយប៉ុន្មានពីភូមិ ។ ពីន បាននិយាយថា ប្ដីរបស់ ប៉ៃ

មិនបានរត់គេចទេ ។ គាត់និងកម្មាភិបាលផ្សេងទៀតបានបណ្តើរប្តីរបស់ ប៉ៃ ទៅព្រៃជាមួយនឹងចបកាប់មួយហើយ ពិន ដឹងច្បាស់ថាចបនោះនឹងត្រូវយកប្រើជាឧបករណ៍សម្លាប់ ។ ពីន បាននិយាយថាដៃរបស់ ប៉ៃ ត្រូវបានគេចងយ៉ាងធូរប៉ុន្តែគាត់មិនបានរត់ទេ ។ ពេលទៅដល់ព្រៃប្តីរបស់ ប៉ៃ ត្រូវបង្ខំឲ្យអង្គុយព្រមទាំងវាយនឹងចបកាប់ពីក្រោយ ។ ពីន មិនបានរៀបរាប់ឲ្យច្បាស់ពីរបៀបនៃការសម្លាប់ប្តីរបស់ ប៉ៃ ទេ គាត់គ្រាន់តែនិយាយថា «កម្មាភិបាលដែលទៅជាមួយគាត់ជាអ្នកធ្វើការទាំងនោះ» ។ នៅដើមទសវត្សរ៍ ៨០ ប៉ៃ បានដឹក រណ្តៅឃើញឆ្អឹងសាកសពដែលមានជើងតែម្ខាង បាក់ដៃនិងប្រេះលលាដ៍ក្បាល ។ ពីន មិនដែលនិយាយពីស្ថានភាពនៃការស្លាប់របស់ប្តីរបស់ ប៉ៃ ទេ ប៉ុន្តែបានសន្និដ្ឋានពីស្នាមរបួសនៃសាកសពនោះ ។ ប្តីរបស់ ប៉ៃ បានស្លាប់ដោយវេទនា ។ កម្មាភិបាលដែលធ្វើការជាមួយ ពីន ត្រូវបានគេគិតថាស្លាប់ជាច្រើនឆ្នាំមកហើយ ។ ប៉ៃ បានឃើញ ពីន សម្លាប់មនុស្សម្នាក់ផ្សេងទៀតនៅក្នុងភូមិ ។ ប៉ៃ បានឃើញការសម្លាប់ដ៏ព្រៃផ្សៃរបស់ ពីន ដោយកាន់កាំភ្លើងបាញ់ជនម្នាក់នោះដូចជា «សម្លាប់ឆ្កែនៅកណ្តាលថ្ងៃត្រង់» ។

បច្ចុប្បន្ន ពីន រស់នៅជាមួយប្រពន្ធនិងកូនពីរនាក់ ។ ជារៀងរាល់ថ្ងៃ គាត់ធ្វើការនៅក្នុងវត្តដើម្បីបម្រើព្រះសង្ឃ ។ គាត់មានវ័យចំណាស់និងទន់ខ្សោយ ។ រីឯកូនទាំងបួនរបស់ ប៉ៃ បានលូតលាស់ធំទៅហើយ ។ កូនពីរនាក់របស់ ប៉ៃ គឺជាមនុស្សមាំមួន ។ ស្ថានភាពគ្រួសាររបស់ ប៉ៃ មានសភាពល្អជាងគ្រួសាររបស់ ពីន ច្រើន ។ នេះមានន័យថា ប៉ៃ អាចសងសឹក ពីន ឬអាចប្រើប្រាស់លក្ខខណ្ឌសង្គមទៅធ្វើបាបជីវិតរបស់ ពីន ឲ្យលំបាកជាងនេះ ។ ប៉ុន្តែ ប៉ៃ បាននិយាយថា «ខ្ញុំមិនចង់សម្លាប់ ពីន ទេ ហើយខ្ញុំក៏បានហាមមិនឲ្យកូនរបស់ខ្ញុំធ្វើបែបនោះដែរ ។ ខ្ញុំចង់ឲ្យ ពីន នៅរស់ដូច្នេះ ពីន អាចមើលថែទាំប្រពន្ធកូនរបស់គាត់បាន» ។ ប៉ៃ បាននិយាយថា ពីន កំពុងតែត្រូវព្រះពុទ្ធដាក់ទណ្ឌកម្មចំពោះអ្វីដែលគាត់បានប្រព្រឹត្ត ។ សុខភាពផ្លូវចិត្តរបស់គាត់មានសភាពខ្សោយ ហើយគាត់ស្ទើតែជាមនុស្សម្នាក់ដែលអ្នកភូមិមិនសូវរាប់រក ។ មានតែវត្តអារាមទេដែលអាចផ្តល់សេចក្តីសុខឲ្យគាត់បាន ។

ទោះបីជា ប៉ៃ មិនដែលនិយាយអំពីការអត់ឱនទោសក៏ដោយ ចំពោះទស្សនៈជាច្រើនបានបង្ហាញថាគាត់បានអត់ឱនឲ្យ ពីន ហើយបានបន្តដំណើរជីវិតទៅមុខរួចទៅហើយ ។ ប៉ៃ មិនចាំបាច់ត្រូវតែអត់ឱនឲ្យ ពីន ទេ ។ ប៉ៃ មិនចាំបាច់ធ្វើការប្រាស្រ័យទាក់ទងជាមួយ ពីន ដើម្បីអត់ឱនគាត់ទេ ។ ប៉ៃ យល់ឃើញថា ពីន កំពុងតែទទួលកម្មពៀរពីបាបកម្មរបស់គាត់ផ្លូវពុទ្ធសាសនាគឺថាគាត់មិនត្រូវបានទទួលស្គាល់ដោយអ្នកនៅរស់សង្គមនិងខ្លួនគាត់ផ្ទាល់ ។ អ្នកទាំងឡាយណាដែលស្ថិតនៅក្នុងស្ថានភាពនេះពិតជាគួរឲ្យអាណិតណាស់ ។

ប្រហែលជានៅថ្ងៃមួយ ពីន នឹងយល់ថាមធ្យោបាយតែមួយគត់ដើម្បីលាងបាបរបស់គាត់គឺបន្តធ្វើអំពើល្អនៅក្នុងវត្តនិងសង ប៉ៃ តាមដែលអាចធ្វើទៅរួច ។ នៅពេលដែលរឿងនេះកើតឡើង ការអត់ឱនទោសនិងការផ្សះផ្សាដ៏ពេញលេញមួយនឹងអាចកើតមាន ។ ប្រសិនបើ ពីន បដិសេធនូវឧក្រិដ្ឋកម្មរបស់ខ្លួនដែលជាមធ្យោបាយដ៏ងាយស្រួលនោះ នោះក៏នឹងមិនមានការអត់ឱនទោសដ៏ពេញលេញមួយដែរ ។ ចំពោះ ប៉ៃ, ពីន មិនអាចមានឥទ្ធិពលអ្វីទៅលើគាត់បានឡើយ ប៉ុន្តែការសារភាពអាចធ្វើឲ្យ ប៉ៃ អស់ចិត្ត ។

ខ្ញុំជឿថាឧទាហរណ៍នេះបានកើតឡើងនៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា ។ ជនរងគ្រោះមិនចង់សារភាពថាខ្លួនកំពុងឈឺចាប់ទេព្រោះការធ្វើបែបនេះមើលទៅហាក់បីដូចជាចុះចាញ់ចំពោះជនដៃដល់ ។ វាអាស្រ័យទៅលើថា តើជនរងគ្រោះទទួលរង ការឈឺចាប់ប៉ុណ្ណោះ ហើយថាតើអត្តចរិតរបស់ជនដៃដល់មានសភាពយ៉ាងណា ។ មនុស្សម្នាក់អាចអត់ឱនឲ្យមនុស្សម្នាក់ទៀតដោយមិនចាំបាច់ធ្វើការប្រាស្រ័យទាក់ទងគ្នាក៏បាន ។ ការអត់ឱនទោសមិនមែនជាការបោះបង់នូវការដាក់ឲ្យមានការទទួលខុសត្រូវតាមច្បាប់ទេ ។ ការអត់ឱនទោសអាចត្រូវបានយកមកបង្រៀនប្រសិនបើយើងមានឧទាហរណ៍ដ៏ជោគជ័យមួយ ។

ទោះបីជាយ៉ាងណាក៏ដោយ ការអត់ឱនទោសឲ្យមេដឹកនាំខ្មែរក្រហមគឺជារឿងខុសគ្នា ។ តើបិសាចមនុស្សជាតិទាំងនេះនឹងអាចទទួលបានការអត់ឱនទោសដែរឬទេ? តើករណី០០២នឹងអាចធ្វើឲ្យប្រជាជនកម្ពុជាទូទៅមិនមានការគុំកួនទៀតដែរឬទេ? វាគឺជាការលំបាកមួយក្នុងការអត់ឱនទោសនិងផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ **អេង កុកថាយ**

# ថ្ងៃ៧មករាជាថ្ងៃរំដោះ

នៅក្នុងចំណោមសិស្សនិស្សិត នយោជិកឯកជន នយោជិករដ្ឋ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនិងប្រជាជនមួយចំនួនមានការពិភាក្សាយ៉ាងផុសផុលអំពីអត្ថន័យនិងខ្លឹមសារនៃថ្ងៃ៧មករា ១៩៧៩ ។ ក្នុងទសវត្សរ៍៨០ ថ្ងៃនេះត្រូវបានប្រារព្ធនិងចងចាំយ៉ាងជ្រាលជ្រៅដោយប្រជាជនទូទាំងប្រទេស ។ ហើយនៅពេលនោះមនុស្សភាគច្រើនមានគំនិតដូចៗគ្នាថាថ្ងៃ៧មករាជាថ្ងៃវិសេសវិសាលបំផុត ។ ប៉ុន្តែសម្រាប់ពេលបច្ចុប្បន្នមានមតិរបស់អ្នកវិភាគមួយចំនួននិយាយថាថ្ងៃ៧មករាមិនមែនជាថ្ងៃរំដោះទេ ប៉ុន្តែជាថ្ងៃដែលកងទ័ពវៀតណាមបានឈ្លានពានទឹកដីប្រទេសកម្ពុជាហើយកាន់កាប់ប្រទេសរយៈពេលដប់ឆ្នាំពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ ។

ខ្ញុំគិតថាថ្ងៃ៧មករាគឺជាថ្ងៃរំដោះដ៏ពិតប្រាកដមែន ។ នៅថ្ងៃនោះប្រជាជនកម្ពុជាទាំងអស់ត្រូវបានរំដោះចេញពីសេចក្តីស្លាប់នៅក្រោមការដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យដែលរដ្ឋាភិបាលនេះបានធ្វើឲ្យជីវិតមនុស្សស្លាប់ពាសពេញប្រទេសកម្ពុជាមិនថាអ្នកនោះជាខ្មែរ ចិន ចាម វៀតណាម ខ្មែរក្រោម ជនជាតិដើម ជនជាតិភាគតិច ថៃ និងឡាវទេ ។ សេចក្តីស្លាប់ទាំងនេះបង្កឡើងដោយមូលហេតុបីធំៗគឺ ការប្រហារជីវិតដោយខ្មែរក្រហម ការធ្វើការបាក់កម្លាំង និងជំងឺរាតត្បាត ។ ក៏ប៉ុន្តែសេចក្តីស្លាប់ទាំងអស់មានហេតុជារួមមួយដែលបង្កដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យគឺការបង្កើតលក្ខខណ្ឌផ្សេងដែលបង្កឲ្យមានការស្លាប់បាត់ជីវិតមនុស្សជាបន្តបន្ទាប់ ។ លក្ខខណ្ឌទាំងនេះរួមមាន ការបណ្តេញមនុស្សចេញពីទីក្រុងនានា ការលុបបំបាត់ចោលនូវធនធានជាតិដែលមានលក្ខណៈទំនើបដូចជាថ្នាំពេទ្យ បរិកាពេទ្យប្រើប្រាស់ទំនើបៗ គ្រឿងចក្រទំនើបៗ លុយ និងស្ថាប័នរដ្ឋដែលមានដំណើរការល្អ ។ លើសពីនេះខ្មែរក្រហមបានបង្កើតជាលក្ខខណ្ឌនៃការសម្លាប់ជារួមមួយដែលពេលខ្លះកម្មាភិបាលថ្នាក់ក្រោមក៏មានលទ្ធភាពក្នុងការសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោសដែរ ។ នៅពេលណាដែលមនុស្សអត់ឃ្លាននិងត្រូវបានបង្ខំឲ្យធ្វើការដោយដៃទទេជាច្រើនម៉ោងក្នុងមួយថ្ងៃ មនុស្សទាំងនេះច្រើនតែមានទំនោរទៅរកការលួចអាហារនិងធ្វើនូវកំហុសផ្សេងៗ ។ ការលួចលាក់និងកំហុសទាំងនេះជាទូទៅត្រូវខ្មែរក្រហមយកជាទោសនិងដាក់ទណ្ឌកម្មប្រហារជីវិត ។ ក្រៅពីនេះ របបខ្មែរក្រហមគឺពោរពេញទៅដោយភាពសង្ស័យនិងការមិនទុកចិត្តគ្នាទៅវិញទៅមក ។ សូម្បីតែខ្មែរក្រហមគ្នាឯងក៏កាប់សម្លាប់គ្នាដែរជាក់ស្តែងកម្មាភិបាលភូមិនិរតីទៅសម្លាប់កម្មាភិបាលភូមិភាគបូព៌ា និងភូមិភាគកណ្តាល ។ កម្មាភិបាលធំៗមួយចំនួនដូចជា កុយ ធួន, វ៉ន វ៉េត, ហ៊ូ នឹម និង ណៃ សារ៉ាន់ សុទ្ធតែត្រូវបានសម្លាប់ទាំងអស់ ។ ថ្ងៃ៧មករា បានបញ្ឈប់នូវការសម្លាប់ទាំងអស់ភ្លាមមួយរំពេច ។


ប្រជាជននាំគ្នាត្រឡប់ទៅស្រុកកំណើត

ពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៧ មករា ១៩៧៩ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានមនុស្សស្លាប់រហូតដល់ពីរលាននាក់ ។ តួលេខមួយចំនួនបានបញ្ជាក់ថាមានមនុស្សស្លាប់ដល់ទៅបីលាននាក់ ។ អ្នកខ្លះទៀតថាមានមនុស្សស្លាប់មួយលាននាក់ ។ ប៉ុន្តែជាទូទៅតួលេខដែលគេ

ប្រើប្រាស់ជាញឹកញាប់គឺពី១.៧លានទៅ២លាននាក់ ។ ប្រសិនបើយើងយកចំនួនមនុស្សស្លាប់ពីរលាននាក់នៅក្នុងរយៈពេលបីឆ្នាំប្រាំបីខែនិងម្ភៃថ្ងៃ យើងសង្កេតឃើញថា នៅក្នុងរបបខ្មែរក្រហមមានមនុស្សស្លាប់ជាមធ្យម១៨៧៦នាក់ក្នុងមួយថ្ងៃ ។ សោកនាដកម្មនេះគឺមានន័យថាក្នុងមួយថ្ងៃមានមនុស្សស្លាប់ច្រើនជាងព្រឹត្តិការណ៍នៅកោះពេជ្រចំនួនបួនដង ហើយវាកើតឡើងជារាល់ថ្ងៃ ។ តាមការស្រាវជ្រាវមួយចំនួនបានបង្ហាញថាការសម្លាប់រង្គាលរបស់ខ្មែរក្រហមមានសន្ទុះកើនឡើងនៅឆ្នាំ១៩៧៨ ដែលលើសពីឆ្នាំ១៩៧៥, ១៩៧៦ និង១៩៧៧ ។ បានសេចក្តីថានៅចុងឆ្នាំ១៩៧៨ចំនួនមនុស្សស្លាប់ក្នុងមួយថ្ងៃ អាចលើសពី១៨៧៦នាក់ ។ ហេតុនេះ រាល់ការពន្យារពេលមិនរំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីរបបខ្មែរក្រហមក្នុងមួយថ្ងៃមានមនុស្សជាច្រើននាក់ស្លាប់បាត់បង់ជីវិត ។ កងទ័ពវៀតណាមដែលសហការជាមួយកងទ័ពកម្ពុជាគឺជាកម្លាំងយោធាដែលអាចបញ្ឈប់របបខ្មែរក្រហមបានភ្លាមៗនៅពេលនោះ ។ ចំណែកឯកងទ័ពមនុស្សធម៌របស់អង្គការសហប្រជាជាតិពុំអាចធ្វើសកម្មភាពបានភ្លាមៗនោះឡើយ ។ មនុស្សមួយចំនួនដែលគិតថា ថ្ងៃ៧មករា ជាថ្ងៃឈ្លានពាន គឺពឹងផ្អែកទៅលើការវិភាគរបស់ខ្លួនទៅលើច្បាប់អន្តរជាតិនិងអត្ថន័យប្រវត្តិសាស្ត្រដែលបង្ហាញថាប្រទេសវៀតណាមនិងថៃមានបំណងលេបទឹកដីកម្ពុជា ។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិបានចែងថា គ្មានប្រទេសណាមួយអាចប្រើប្រាស់កម្លាំងយោធារបស់ខ្លួនទៅលើប្រទេសមួយទៀតបានឡើយនៅពេលដែលគ្មានការគាំទ្រពីក្រុមប្រឹក្សាសន្តិសុខ ។ ការប្រើប្រាស់កម្លាំងយោធាគឺជាមធ្យោបាយដែលធ្វើឡើងក្នុងគោលបំណងមនុស្សធម៌មួយមុខគត់ ហើយវាជាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ។ ក៏ប៉ុន្តែក្រុមប្រឹក្សាសន្តិសុខគឺជាអង្គភាពមួយដែលមិនសូវដើរតាមទ្រឹស្តីខាងលើឡើយពីព្រោះសមាជិកអចិន្ត្រៃយ៍ទាំងប្រាំនិងសមាជិកបណ្តោះអាសន្នទាំងប្រាំបួនមានរបៀបវារៈនយោបាយរៀងៗខ្លួន ។ ប្រការសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខគឺជាសេចក្តីសម្រេចដែលមានលក្ខណៈនយោបាយ ។ ពីឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៩ មជ្ឈដ្ឋានអន្តរជាតិចាប់ផ្តើមដឹងឮពីការសម្លាប់មនុស្សនៅប្រទេសកម្ពុជាក្រោយពីជនភៀសខ្លួននៅក្នុងជំរំតាមព្រំដែនថៃបានរៀបរាប់អំពីទុក្ខវេទនារបស់ខ្លួន ។ ក៏ប៉ុន្តែរបបខ្មែរក្រហមកើតឡើងនៅក្នុងបរិបទសង្គ្រាមត្រជាក់រវាងប្រទេសសេរីនិងប្រទេសកុម្មុយនីស្ត ។ ហេតុនេះក្រុមប្រឹក្សាសន្តិសុខដែលមានចិន សូវៀត និងអាមេរិក ជាសមាជិកពុំអាចសម្រេចអ្វីបានឡើយពីព្រោះសមាជិកទាំងអស់មានមតិផ្សេងៗគ្នា ។ អ្នកខ្លះគិតថា ការរាយការណ៍របស់ជនភៀសខ្លួនមិនពិតដូចអ្វីដែលបានកើតឡើងឡើយ ។ អ្នកខ្លះគិតថា ការវាយលុកចូលទៅលើកម្ពុជាខ្លាចប៉ះពាល់ទៅដល់គោលនយោបាយរបស់ចិនឬសូវៀត ។ អ្នកខ្លះលើកឡើងថា បូរណភាពទឹកដីនិងអធិបតេយ្យភាពកម្ពុជាត្រូវតែគោរព ។ សហរដ្ឋអាមេរិកក្រោយពីទទួលបរាជ័យនៅក្នុងសង្គ្រាមវៀតណាម ហើយបានដកទ័ពនៅឆ្នាំ១៩៧៣ មិនចង់វិលត្រឡប់មកតណ្ហូចិនសាជាថ្មីនិងមិនចង់ឲ្យប៉ះពាល់ដល់ប្រទេសចិនដែលអាមេរិកកំពុងចាប់ផ្តើមស្តារទំនាក់ទំនងល្អឡើងវិញឡើយ ។ បញ្ហាទាំងអស់នេះធ្វើឲ្យមានការយឺតយ៉ាវនិងអសកម្មដោយអង្គការសហប្រជាជាតិក្នុងការរំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ខ្មែរក្រហម ។ បើគ្មានថ្ងៃ៧មករាប្រហែលជាគ្មានស្ថាប័នណាមួយមករំដោះឡើយ ។

ការរៀបរាប់ខាងលើមិនមែនមានន័យថាច្បាប់អន្តរជាតិគ្មានប្រយោជន៍នោះឡើយ ។ ការបែងចែកពិភពលោកជាប្រទេសនិងរដ្ឋដែលមានអធិបតេយ្យភាពនិងបូរណភាពទឹកដីជាក់លាក់គឺធ្វើឡើងដើម្បីរក្សាសន្តិភាពរវាងរដ្ឋនិងរដ្ឋ ។ បូរណភាពទឹកដីមានន័យថារដ្ឋនីមួយៗមានទឹកដីជាក់លាក់របស់ខ្លួនដែលទទួលស្គាល់ដោយមជ្ឈដ្ឋានអន្តរជាតិហើយគ្មានប្រទេសណាមួយអាចចូលមកប្រើប្រាស់ធនធានរស់នៅ កាន់កាប់និងដាក់កងទ័ពរបស់ខ្លួននៅលើទឹកដីនេះដោយគ្មានការអនុញ្ញាតពីប្រទេសជាម្ចាស់ផ្ទះបានឡើយ ។

អធិបតេយ្យភាពមានន័យថាគ្មានប្រទេសណាមួយឬអង្គភាពណាមួយដែលមានសិទ្ធិសម្រេចដឹកនាំឬកំណត់លើវាសនារបស់ប្រទេសនោះបានឡើយ ។ ការបង្កើតពិភពលោកជារដ្ឋត្រូវបានធ្វើឡើងនៅឆ្នាំ១៦៤៨នៅវើសហ្វាលៀដែលជាទីក្រុងមួយនៅអឺរ៉ុប ។ មុនឆ្នាំនេះ ប្រទេសនិងអាណាចក្រមានសង្គ្រាមរវាងគ្នាមិនឈប់ឈរដែលមានមនុស្សស្លាប់ជាបន្តបន្ទាប់ ។ អាណាចក្រដែលមានកម្លាំងយោធាធំច្រើនឈ្លានពាននិងកាន់កាប់អាណាចក្រទន់ខ្សោយ ។ អង្គការសហប្រជាជាតិត្រូវបានបង្កើត

ឡើងដោយផ្អែកលើទ្រឹស្តីនេះនិងដើម្បីរក្សាសន្តិភាព ។

អ្នកវិភាគមួយចំនួនដែលគិតថាថ្ងៃ៧មករាជាថ្ងៃឈ្នានពាន គឺផ្អែកទៅលើច្បាប់អន្តរជាតិនេះឯង ហើយព្រួយបារម្ភខ្លាចរដ្ឋទាំងឡាយមិនគោរពគ្នាទៅវិញទៅមកដែលបង្កឲ្យមានសង្រ្គាមពិភពលោក ។ ទោះជាយ៉ាងនេះក្តី ច្បាប់អន្តរជាតិត្រូវបានធ្វើឡើងដើម្បីបម្រើដល់សេចក្តីសុខនិងភាពសុខសាន្តរបស់ប្រជាជនទាំងអស់នៅក្នុងពិភពលោក ។ អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតលើសឧក្រិដ្ឋកម្មជាតិនិងអន្តរជាតិណាៗទាំងអស់ ។ នៅពេលដែលមានអំពើនេះកើតឡើង ជនរងគ្រោះត្រូវតែរំដោះឲ្យរួចផុតពីសោកនាដកម្មឲ្យបានទាន់ពេលវេលាទោះបីជាមធ្យោបាយនោះវាមិនសូវល្អក៏ដោយ ។

ដោយផ្អែកលើឧទាហរណ៍ជាប្រវត្តិសាស្រ្តសម័យអង្គរចាប់ពីសតវត្សទី១៤ដល់១៥ អ្នកខ្លះអះអាងថាអាណាចក្រខ្មែរបានធ្លាក់ចុះដោយសារមានការពង្រីកទឹកដីពីខាងលិចដោយប្រទេសថៃនិងខាងកើតដោយប្រទេសវៀតណាម ។ ក្រោយសម័យអង្គរ ប្រទេសកម្ពុជាបានបាត់បង់ទឹកដីបន្តិចម្តងៗ ហើយទឹកដីដែលបាត់បង់គឺបានទៅលើប្រទេសថៃនៅភាគខាងលិចនិងប្រទេសវៀតណាមនៅភាគខាងកើត ។ ដោយសារការបាត់បង់ទឹកដីនេះ ហើយដែលវាធ្វើឲ្យអ្នកជាតិនិយមមួយចំនួនមានការសង្ស័យចំពោះគោលបំណងពិតប្រាកដរបស់វៀតណាមក្នុងការនាំទ័ពចូលមកប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨និងដើមឆ្នាំ១៩៧៩ ។ អ្នកវិភាគទាំងនោះព្រួយបារម្ភថាវៀតណាមនឹងមិនដកទ័ពទៅត្រឡប់ទៅវិញហើយកាន់កាប់ប្រទេសកម្ពុជាជារៀងរហូត ។ អ្នកខ្លះគិតថាវៀតណាមនឹងប្រមូលធនធានសេដ្ឋកិច្ចនិងវប្បធម៌ត្រឡប់ទៅកាន់ប្រទេសខ្លួន ហើយកែប្រែប្រទេសកម្ពុជាទៅបរិវាររបស់ខ្លួន ។ ក៏ប៉ុន្តែវៀតណាមបានដកទ័ពចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ ហើយនៅក្នុងអំឡុងទសវត្សរ៍៨០ បានទប់ស្កាត់ខ្មែរក្រហមមិនឲ្យវិលត្រឡប់មកកាន់អំណាចវិញដែលគ្មានប្រជាជនកម្ពុជាណាម្នាក់គាំទ្រការវិលត្រឡប់នេះឡើយ ។

ជារួមខ្ញុំគិតថាថ្ងៃ៧មករាជាថ្ងៃដ៏វិសេសវិសាលមួយ ហើយគ្មានអ្វីដែលអវិជ្ជមានចំពោះថ្ងៃនេះឡើយ ។ បញ្ហាគឺស្ថិតនៅត្រង់ថាថ្ងៃនេះត្រូវបានប្រើប្រាស់មិនត្រឹមតែដើម្បីការចងចាំអំពើប្រល័យពូជសាសន៍ប៉ុណ្ណោះទេ ប៉ុន្តែវាត្រូវបានប្រើប្រាស់ជាលក្ខណៈនយោបាយ ។ ក៏ប៉ុន្តែការមិនទទួលស្គាល់ថ្ងៃ៧មករាគឺជាការខុសឆ្គង ។

**អេង កុកថាយ**



ក្រោយថ្ងៃ៧មករា ប្រជាជននាំគ្នាវិលត្រឡប់មកស្រុកកំណើតរៀងៗខ្លួន

# រឿងរ៉ាវជីវិតរបស់ម្ដាយខ្ញុំ

ខ្ញុំកើតនៅប្រទេសកម្ពុជាដែលមានផ្ទៃដីធំជាងរដ្ឋអ៊ីឌីយ៉ាណាពីរដង ។ ប្រជាជនកម្ពុជាភាគច្រើនគឺជាពុទ្ធសាសនិក ។ នៅទីនោះ ក៏មានគ្រិស្តសាសនិកដែរ ប៉ុន្តែខ្ញុំមិនស្គាល់អ្នកទាំងនោះទេ ។ នៅប្រទេសកម្ពុជា ខ្ញុំមិនដែលបានប្រារព្ធពិធីបុណ្យខួបកំណើត ឬពីធីរំពុកអ្វីមួយឡើយ ។ ប៉ុន្តែខ្ញុំមានថ្ងៃឈប់សម្រាកនៅពេលដែលពុទ្ធសាសនិកប្រារព្ធពិធីអ្វីមួយ ។ យើងមានជីវភាពក្រីក្រ ប៉ុន្តែយើងមានអ្វីដែលយើងត្រូវការ ។ ឪពុករបស់ខ្ញុំមិនសូវនៅជាមួយគ្រួសារទេហើយដោយខ្ញុំនៅក្មេងខ្ញុំ ក៏មិនដែលមានការព្រួយបារម្ភដូចឪពុកម្ដាយរបស់ខ្ញុំដែរ ។

ខ្ញុំចាំបានថានៅល្ងាចមួយ បុរសម្នាក់បានមកដល់មាត់ទ្វារ ។ បន្ទាប់មក ម្ដាយខ្ញុំក៏សួរថា «អ្នកណា» ហើយជននោះបានឆ្លើយថា «ខ្ញុំ» ។ យើងបានសួរម្ដងទៀត ហើយបុរសនោះនៅតែនិយាយថាគឺ«ខ្ញុំ» ។ នៅពេលនោះយើងកំពុងតែអង្គុយហូបបាយរង់ចាំម្ដាយយើងនៅពេលដែលគាត់ទៅបើកទ្វារ ។ ម្ដាយខ្ញុំបានបើកទ្វារបន្ទាប់មកគាត់ក៏ឃើញបុរសម្នាក់ឈរនៅពីមុខបុរសដទៃទៀត ។ បុរសឈរនៅពីមុខនោះបានយកចំពុះទង់ភ្ជង់ម្ដាយខ្ញុំ ហើយអ្នកផ្សេងទៀតបានហៅឲ្យជីតានិងឪពុកខ្ញុំឲ្យក្រោកឡើង ។ នៅពេលមេឃងងឹតខ្លាំង អ្នកទាំងនោះក៏ចាកចេញបាត់ទៅ ។ បន្ទាប់មក ម្ដាយខ្ញុំក៏ដើរទៅដើរមក ហើយនិយាយថា គាត់ស្គាល់បុរសម្នាក់ក្នុងចំណោមនោះ គាត់គឺបងប្អូនសាច់ឆ្ងាយរបស់ឪពុកខ្ញុំ ។

ចាប់ពីឆ្នាំ១៩៧០រហូតមកដល់ឆ្នាំ១៩៧៥ជនកុម្មុយនីស្តតែងតែមកឡោមព័ទ្ធផ្ទះរបស់ខ្ញុំ ។ បុរសដែលមកផ្ទះរបស់ខ្ញុំគឺជាជនកុម្មុយនីស្តពាក់ឯកសណ្ឋានអាវពណ៌ខ្មៅ ។ យើងរស់នៅកន្លែងផ្សេងៗគ្នាជាច្រើន ។ ហើយយើងតែងតែសែនបន្តិចបន្តួចឲ្យម្ចាស់ទឹកម្ចាស់ដី ហើយពេលខ្លះម្ដាយខ្ញុំក៏បានដុតធូបនិងបួងសួងខ្លះដែរ ។ នៅពេលដែលខ្ញុំនៅតូច យើងទាំងអស់គ្នាគេងនៅខាងក្រៅផ្ទះ ។ ពេលខ្លះម្ដាយខ្ញុំបានមើលទៅលើមេឃ ហើយបានប្រាប់យើងថា នៅទីនោះមានព្រះដែលជាអ្នកបង្កើតយើង ។ ម្ដាយខ្ញុំមានការឈឺចាប់ខ្លាំងណាស់ ហើយខ្ញុំក៏ដឹងថាគាត់ឆ្ងល់ថា ហេតុអ្វីព្រះមិនមកជួយគាត់ ។ ឪពុកខ្ញុំមិនស្មោះនឹងម្ដាយខ្ញុំទេ ពីព្រោះគាត់មិនដែលមករកយើងទាំងអស់គ្នាឡើយ ។ ខ្ញុំសង្ឃឹមថាម្ដាយខ្ញុំដឹងថាព្រះធ្លាប់បានមកដល់ ហើយក៏សង្ឃឹមថាគាត់នឹងស្គាល់ព្រះ ។ ជីតារបស់ខ្ញុំបានត្រឡប់មកវិញនៅពេលយប់ ។ ប៉ុន្តែជនកុម្មុយនីស្តបានយកពូរបស់ខ្ញុំទៅវិញ ។ ជនកុម្មុយនីស្តនោះបានលែងជីតារបស់ខ្ញុំពីព្រោះគាត់ធ្វើការឃើតពេក ។

យើងបានប្ដូរទៅកន្លែងផ្សេងទៀត ។ យើងមានផ្ទះមួយសម្រាប់រស់នៅ ។ ក្រោយមក ម្ដាយខ្ញុំឮដំណឹងថាពូរបស់ខ្ញុំនៅរស់ដូច្នេះគាត់ក៏ទៅនិយាយជាមួយពូរបស់ខ្ញុំ ។ ពូរបស់ខ្ញុំក៏បានប្រាប់គាត់ថាបន្ទាប់ពីជនកុម្មុយនីស្តចាប់គាត់ អ្នកទាំងនោះបានចងគាត់និងអ្នកដទៃទៀតបោះទៅក្នុងទូក ។ ពូរបស់ខ្ញុំបានរួចរស់ជីវិត ប៉ុន្តែគាត់មិនអាចជួយឪពុកខ្ញុំបានទេ ។ ឪពុករបស់ខ្ញុំបានលង់ទឹកស្លាប់ ។ នៅពេលនោះសហរដ្ឋអាមេរិកបានចាប់ផ្ដើមទម្លាក់គ្រាប់បែកដោយខុសច្បាប់មកលើប្រទេសកម្ពុជា ។ គ្រាប់បែកខ្លះគឺជាគ្រាប់បែករបស់សហរដ្ឋអាមេរិក ខ្លះទៀតជារបស់សង្គ្រាមស៊ីវិល ។ នៅអំឡុងពេលនោះ អ្នកណាក៏រត់ទៅរកគ្រួសាររបស់ខ្លួនដែរ ។ ខាងក្រោយផ្ទះយើងមានលេណដ្ឋានម្រាប់គេចពីគ្រាប់បែក ។ លេណដ្ឋាននោះមានទំហំធំល្មមសម្រាប់គ្រួសារប្រាំនាក់របស់យើង ។ យើងមានអាហារក្រៀមសម្រាប់ហូបប៉ុន្តែវាមិនសូវជាក្រៀមណាស់ណាទេ ។ យើងដឹងថាមុនពេលដែលអាមេរិកទម្លាក់គ្រាប់បែកយើងអាចឮសំឡេងយន្តហោះ ដូច្នេះយើងអាចរត់ទៅពួនក្នុងលេណដ្ឋានមុន ។ ដំបូងយើងមិនសាំនឹងការរស់នៅជិតលេណដ្ឋានទេ ។ ប៉ុន្តែក្រោយមកយើងអាចទម្លាប់ខ្លួនបាន ។ បន្ទាប់ពីការទម្លាក់គ្រាប់បែក ម្ដាយខ្ញុំបានប្រាប់ខ្ញុំថាកុំឲ្យរើសអំបែងនោះ ។ ប៉ុន្តែដោយការងឿងឆ្ងល់ខ្ញុំតែងតែទៅរកមើលអំបែងគ្រាប់បែក ។ ថ្ងៃមួយខ្ញុំបានឃើញអំបែងគ្រាប់បែកនៅជាប់ដើមឈើ ប៉ុន្តែខ្ញុំមិនបានយកវាចេញមកទេ ពីព្រោះខ្ញុំដឹងថាប្រសិនបើអំបែងនោះមុតនឹងកើតមានរឿងធំជាមិនខាន ។

ថ្ងៃមួយពេលដែលខ្ញុំត្រឡប់មកពីយកទឹកកក ខ្ញុំបានឃើញ

ក្រដាសតាមផ្លូវដែលសរសេរថាព្រះយេស៊ូនៅទីនេះ ។ ខ្ញុំបានសួរម្តាយខ្ញុំថា «នេះជាអ្វី» ម្តាយខ្ញុំក៏ប្រាប់ថានោះគឺជាព្រះដែលប្រជាជនគោរព ។ នៅពេលនោះ ខ្ញុំពិតជាមានការងឿងឆ្ងល់ជាខ្លាំងថាព្រះយេស៊ូគឺជាអ្នកណា ។ យើងបានទៅធ្វើបុណ្យនៅវត្តបងស្រីរបស់ខ្ញុំក៏ត្រូវភ្លើងធូបឆេះត្រូវនៅចន្លោះភ្នែករបស់គាត់ ចំណែកខ្ញុំទៅជាមួយគាត់ដោយសារតែខ្ញុំចង់ទៅដើរលេង ខ្ញុំមិនចាប់អារម្មណ៍នឹងសាសនាអ្វីទេ ។

នៅឆ្នាំ១៩៧៥ម្តាយរបស់ខ្ញុំបានទៅជួបបងប្អូនជីដូនមួយសាច់ឆ្ងាយរបស់គាត់ដោយចៃដន្យ ។ អ្នកទាំងនោះមានជីវភាពធូរធារល្អម ។ ម្តាយរបស់ខ្ញុំគឺជាកូនកាត់ចិន ដូច្នេះបងប្អូនរបស់គាត់ក៏ជាចិនដែរ ។ បងប្អូនជីដូនមួយម្តាយខ្ញុំបានប្រាប់ម្តាយខ្ញុំថាគ្រួសាររបស់គាត់និងគ្រួសារប្រពន្ធគាត់ត្រៀមនឹងរត់ទៅប្រទេសថៃពីព្រោះគាត់ដឹងថាកុម្មុយនីស្តនឹងទទួលបានជ័យជម្នះ ។ មានគ្រួសារជាច្រើនបានចាកចេញជាបណ្តើរៗ ។ ខ្ញុំបានឮគេថាប្រសិនបើកុម្មុយនីស្តទទួលបានជ័យជម្នះ នោះនឹងមានចលាចលមិនខាន ។ គ្មានអ្នកណាដឹងថាជនកុម្មុយនីស្តនឹងធ្វើអ្វីទៀតទេ ។

បងប្អូនជីដូនមួយរបស់ម្តាយខ្ញុំបានសួរម្តាយខ្ញុំថាចង់ឲ្យបងស្រីខ្ញុំនិងខ្ញុំទៅរស់នៅជាមួយគាត់ដើម្បីជួយមើលកូនៗរបស់គាត់ទេ ។ បងស្រីរបស់ខ្ញុំមិនចង់ទៅទេ ពីព្រោះគាត់គឺជាអ្នកថែទាំម្តាយខ្ញុំ ។ ម្តាយខ្ញុំបានសួរខ្ញុំ ហើយខ្ញុំក៏ឆ្លើយយល់ព្រម ។ ហេតុផលដែលខ្ញុំយល់ព្រមគឺខ្ញុំគឺជាកូនកណ្តាល បងប្រុសរបស់ខ្ញុំរវល់នឹងការរៀនសូត្ររបស់គាត់នៅឯទីក្រុង ។ ដោយសារសង្គ្រាម ខ្ញុំមិនដែលបានទៅរៀនទេ ។ បងស្រីនិងបងប្រុសរបស់ខ្ញុំមានភាពជិតស្និទ្ធនឹងគ្នាណាស់ ហើយម្តាយរបស់ខ្ញុំស្រឡាញ់ថ្នាក់ថ្នមប្អូនស្រីរបស់ខ្ញុំណាស់ ។ ខ្ញុំយល់ថាខ្ញុំមិនសក្តិសមនឹងគ្រួសារខ្ញុំទេ ។ នៅពេលដែលឪពុកខ្ញុំទៅបាត់ ខ្ញុំកាន់តែមានសេរីភាពជាងមុន ។ ខ្ញុំមិនដូចបងប្អូនទាំងបីទេ ។ ខ្ញុំនៅចាំបានថា ម្តាយខ្ញុំបានឲ្យពូដែលជាបងប្អូនឪពុកខ្ញុំមកនិយាយជាមួយខ្ញុំដើម្បីកុំឲ្យខ្ញុំរឹងពេក ។ ភាគច្រើនម្តាយខ្ញុំតែងតែបណ្តោយឲ្យខ្ញុំធ្វើតាមចិត្តពីព្រោះគាត់មិនអាចគ្រប់គ្រងខ្ញុំបាន ។ ខ្ញុំធ្វើខ្លួនដូចជាខ្ញុំជាមនុស្សចាស់ជាងវ័យ ។ ខ្ញុំបានសម្តែងហាក់ដូចជាថាខ្ញុំមិនត្រូវការគាត់ទេ ។ ខ្ញុំចង់ធ្វើអ្វីដែលខ្ញុំចង់ ។ ខ្ញុំពិតថាមានការលំបាកណាស់ ។ ខ្ញុំគិតថា ការចាកចេញពីគាត់ក៏ល្អសម្រាប់ខ្ញុំដែរ ។ ប៉ុន្តែខ្ញុំពិតជាមិនដឹងថាខ្ញុំត្រូវចាកចេញពីគាត់ដល់ពេលណាទេ ។ ប៉ុន្មានថ្ងៃចុងក្រោយដែលខ្ញុំរស់នៅជាមួយគាត់ ខ្ញុំពិតជានឹកផ្ទះណាស់ ។ ខ្ញុំពិតជាគិតស្មានមិនដល់ថាខ្ញុំអាចមានអារម្មណ៍បែបនេះទេ ។ ដោយសារតែខ្ញុំគិតតែពីខ្លួនឯងពេក ដូច្នេះខ្ញុំមិនត្រូវការអ្នកណាម្នាក់ទេ ។

ម្តាយខ្ញុំបានជួបខ្ញុំមុនពេលយើងចាកចេញទៅប្រទេសថៃ ។ នៅពេលនោះ ខ្ញុំពិតជាចង់ប្រាប់គាត់ ខ្ញុំបានកែប្រែការ


រូបទីពីររាប់ពីឆ្វេង ៖ ម្តាយរបស់ ចេស៊ីកា កៀសាន់

សម្រេចចិត្តរបស់ខ្ញុំថាមិនទៅទេ ប៉ុន្តែខ្ញុំនិយាយមិនរួច ។ ខ្ញុំបានឃើញម្តាយខ្ញុំដកប្រាក់ឲ្យពូរបស់ខ្ញុំ ហើយខ្ញុំក៏យល់ពីអត្ថន័យនេះដែរ ។ នៅប្រទេសកម្ពុជា វាគឺជារឿងធម្មតាដែលគ្រួសារមួយឲ្យប្រាក់ទៅគ្រួសារមួយទៀតដើម្បីស្នើឲ្យគ្រួសារនោះមើលថែសមាជិកគ្រួសាររបស់ខ្លួន ។ ម្តាយខ្ញុំបានប្រគល់ប្រាក់ឲ្យពូរបស់ខ្ញុំហើយក៏សម្លឹងជុំវិញផ្ទះ បន្ទាប់មកក៏ចាកចេញទៅ ។

ខ្ញុំមិនបាននិយាយអ្វីទាំងអស់ ខ្ញុំមិនយល់ស្របនឹងអ្វីដែល

គាត់បានធ្វើទេ ។ នៅថ្ងៃដែលចាកចេញ ខ្ញុំបានឮអ្នកបើកយន្តហោះនិយាយប្រាប់មីង គីម និងប្តីរបស់គាត់ថាលើសមនុស្សម្នាក់ ។ ខ្ញុំយល់ថា មនុស្សម្នាក់ដែលលើសនោះគឺខ្ញុំ ។ ដោយហេតុនេះអ្នកបើកយន្តហោះនោះបានប្រាប់ប្តីរបស់មីង គីម ថាគាត់មិនចេញដំណើរទេ (នោះគឺជាយន្តហោះដើងក្រោយគេបង្អស់) ។ នៅពេលនោះ យន្តហោះក៏នៅតែទម្លាក់គ្រាប់បែកតាមពិតអ្នកបើកយន្តហោះនោះចង់នៅគ្រប់គ្រងជំនួញរបស់គាត់ ។ ក្រោយពីអ្នកបើកចុះចេញពីយន្តហោះនោះ មីង គីម បានស្តីបន្ទោសខ្ញុំ ។ ខ្ញុំពិតជាមិនចង់នៅទ្រាំទៀតទេ ប៉ុន្តែខ្ញុំក៏មិនអាចត្រឡប់ទៅផ្ទះវិញបានដែរ ។ ខ្ញុំចាប់ផ្តើមខ្លាចអ្នកទាំងនោះហើយ ។ យើងទាំងអស់គ្នានៅចាំប្តីរបស់មីង គីម នៅក្នុងទីក្រុង ។


ចេស៊ីកា ភៀសាន់

នៅពេលនោះ ជនកុម្មុយនីស្តបានកាន់កាប់ដល់ទីក្រុង ។ ជនកុម្មុយនីស្តទាំងនោះបានឲ្យប្រជាជនដែលមានកាំភ្លើងបោះកាំភ្លើងចោលយកប្រាក់ចេញពីធនាគារ និងដេញប្រជាជនចេញពីផ្សារទាំងអស់ ហើយបានបោះប្រាក់ចោលនៅតាមផ្លូវ និងនិយាយថាវាគ្មានតម្លៃទេ ។ ខ្ញុំបានឃើញលុយជាច្រើននៅលើផ្លូវ ។ ប៉ុន្មានសប្តាហ៍មុន យើងមិនមានប្រាក់សម្រាប់ទិញរបស់របរ ប៉ុន្តែឥឡូវប្រាក់ដែលយើងត្រូវការប្រែក្លាយជាគ្មានតម្លៃទៅវិញ ។ ជនកុម្មុយនីស្តនោះបានទៅដល់គ្រប់ផ្ទះ ហើយនិយាយថា អ្នកឯងមើលទៅដូចជាមនុស្សមានចំណេះដឹងតើធ្លាប់មានការសិក្សាដល់កម្រិតណា?

ជនកុម្មុយនីស្តបានធ្វើការស្រាវជ្រាវរកអ្នកចេះដឹង ។ ពេលនោះសមាជិកគ្រួសាររបស់មីង គីម ជាអ្នកមានចំណេះដឹងនិងស្លៀកពាក់ស្អាតបាត ប៉ុន្តែគ្រួសាររបស់គាត់បានធ្វើដូចជាមនុស្សល្ងង់ដែលមិនដឹងអ្វីទាំងអស់ ហើយជនកុម្មុយនីស្តនោះក៏មិនសួរដេញដោលដែរ ។ បន្ទាប់ពីអ្នកដែលអួតអាងពីប្រវត្តិខ្លួនត្រូវបាននាំចេញទៅក្រៅ ជនកុម្មុយនីស្តនោះបានបិទផ្លូវនិងសម្លាប់មនុស្សមួយចំនួន ។ ខ្ញុំបានឮថា មានអ្នកខ្លះនិយាយថាប្រជាជនជាច្រើនបានបាត់ខ្លួនដែលធ្វើឲ្យមានការភ្ញើងឆ្ងល់ជាខ្លាំង ។ នៅលើផ្លូវមានសុទ្ធតែឈាម ។ នៅពេលដែលខ្ញុំនៅម្នាក់ឯង ខ្ញុំមានអារម្មណ៍ភ័យខ្លាចណាស់ហើយខ្ញុំយំរកម្តាយខ្ញុំ ។ ខ្ញុំបានឃើញយុវជនជាច្រើនសម្លាប់មនុស្ស ។ យុវជនទាំងនោះប្រហែលជាត្រូវជនកុម្មុយនីស្តលាងខួរក្បាលឲ្យក្លាយជាឃាតករ ។ យុវជននោះមិនមានភាពភ័យខ្លាចចំពោះការអនុវត្តន៍ការងារបន្ទាប់ដែលជាការសម្លាប់អ្នកមានចំណេះដឹងឲ្យអស់ពីផ្លូវ ។

ក្រោយមក មីង គីម បាននិយាយថា មានអ្នកខ្លះបានរត់ទៅប្រទេសថៃដោយស្លៀកពាក់សម្លៀកបំពាក់ស្អាតនៅពីក្នុងនិងស្លៀកសម្លៀកបំពាក់រហែករយីរយៃនៅទីក្រៅ ។ អ្នកទាំងនោះបានយកដងសន្ទូចនិងកញ្ច្រែងដាក់ត្រីដើរធ្វើជាទៅរកត្រីហើយប្រសិនបើគេចាប់បានអ្នកទាំងនោះនឹងនិយាយថាវង្វេងផ្លូវ ។ យើងមិនដឹងថាអ្នកទាំងនោះអាចធ្វើបែបនោះបានទេ ។ គោលបំណងរបស់អ្នកទាំងនោះគឺរត់ទៅប្រទេសថៃ ។

ក្រោយមក ប្រជាជនត្រូវបានជម្លៀសចេញពីផ្ទះ ។ យើងមិនដឹងថាវាល្អឬមិនល្អក្នុងការចេញទៅនេះទេ ។ យើងបានយកអ្វីដែលយើងអាចយកបានទៅតាមខ្លួន ។ នៅថ្ងៃទីមួយយើងបានទៅដល់ស្រុកស្រែ ។ នៅថ្ងៃទីពីរអាហារចាប់ផ្តើមខ្វះខាត ពីព្រោះ

យើងមិនបានយកអាហារមកច្រើនទេ ។ មីង គីម មិត្តភក្តិរបស់មីង គីម និងខ្ញុំបានត្រឡប់ទៅផ្ទះរបស់ គីម វិញដើម្បីយកអាហារ ។ ប៉ុន្តែជនកុម្មុយនីស្តបានឃើញយើងទាំងអស់គ្នា ។ យើងទាំងអស់គ្នាខ្លាចជាខ្លាំងពីព្រោះជនកុម្មុយនីស្តនោះអាចវាយនិងសម្លាប់យើងដោយមិនមានភាពភ័យខ្លាចឡើយ ។

ជនកុម្មុយនីស្តនោះបានប្រែក្លាយសណ្ឋាគារទៅជាកន្លែងសម្លាប់មនុស្ស ។ អ្នកទាំងនោះបានចាប់យើងដាក់នៅក្នុងបន្ទប់មួយដោយចងស្លាបសេក ។ យើងបានអង្គុយនៅក្នុងបន្ទប់ដែលមានសុទ្ធតែឈាមនៅលើគ្រែ នៅជញ្ជាំង នៅលើដីគឺគ្រប់ទីកន្លែង ។ បុរសម្នាក់ដែលនៅជិតយើងត្រូវគេវាយនិងរំពាត់ពេញមួយយប់ ។ ដំបូងយើងឮសំឡេងស្រែកខ្លាំងណាស់ ប៉ុន្តែដល់ពេលព្រឹកឡើងយើងមិនបានឮសំឡេងស្រែកទៀតទេ ។ យើងមានភាពភ័យខ្លាចហើយមិនហ៊ាននិយាយរកគ្នាទេគឺបានត្រឹមតែសម្លឹងមើលគ្នាទៅវិញទៅមកប៉ុណ្ណោះ ។ យើងទាំងអស់គ្នាបានព្យាយាមស្វែងយល់នូវអ្វីកើតឡើងចំពោះបុរសម្នាក់នោះពីព្រោះយើងមិនបានឮសំឡេងគាត់ទៀតទេ ។ យើងទាំងអស់គ្នាឆ្ងល់ថាបុរសម្នាក់នោះបានធ្វើអ្វីទើបគាត់ត្រូវគេវាយដូចនោះ ។ យើងបានសម្លឹងទៅក្រៅបង្អួចឃើញពន្លឺចាំងចូលមកក្នុងបន្ទប់ពីអគារ ។

នៅព្រឹកនោះ មានគេសួរយើងពីអាហារពេលព្រឹក ។ ប៉ុន្តែយើងមិនចង់ហូបទេ ។ នៅពេលអាហារថ្ងៃត្រង់ គេបានយកបាយនិងការីសាច់មាន់ឲ្យយើង ប៉ុន្តែយើគ្រាន់តែសម្លឹងមើលប៉ុណ្ណោះ ។ ក្មេងប្រុសម្នាក់នោះបានប្រាប់ឲ្យយើងហូប ។ នៅពេលនោះខ្ញុំក៏សង្ស័យថាគេឲ្យយើងហូបដើម្បីឲ្យយើងមានកម្លាំងសម្រាប់ឲ្យអ្នកទាំងនោះវាយប៉ុយ៉ាងណា ។ គីម ពិតជាឆ្លាតណាស់ គាត់បានស្នើសុំជួបបុរសម្នាក់ដែលគាត់បានស្គាល់ ។ គេក៏អនុញ្ញាតឲ្យយើងទៅជួបបុរស ។ មេបញ្ជាការទីពីរក៏នៅទីនោះដែរ ដូច្នេះ មីង គីម បានអង្វរនិងនិយាយបញ្ឆោរអ្នកទាំងនោះ ដោយនិយាយថាយើងមិនមានអ្វីៗដូចអ្នកទាំងនោះឡើយ ។ អ្នកទាំងនោះចង់ដឹងថាតើយើងស្គាល់កន្លែងដែលយើងរស់ឬក៏អត់ ហើយក៏បញ្ជាឲ្យអ្នកនៅក្រោមបង្គាប់រៀបចំអង្ករឲ្យយើងជញ្ជូន ។ យើងបានដើរយ៉ាងលឿនគឺដើម្បីឲ្យកុំឲ្យអ្នកទាំងនោះប្តូរចិត្តទាន់ ។

ខ្ញុំបានដើរជាមួយក្មេងម្នាក់ ហើយយើងបានឃើញសាកសពស្ត្រីដែលមានសក់វែងហើយខ្មៅនៅតាមផ្លូវ ។ ឃើញដូច្នេះយើងក៏មិនសូវហ៊ានដើរទៅដើរមកដែរ ។ នៅថ្ងៃបន្ទាប់យើងបានរៀបចំអ៊ីវ៉ាន់និងចាកចេញទៅប្រទេសថៃ ។ ជនកុម្មុយនីស្តមិនសូវចាប់អារម្មណ៍អ្នកភ្នំទេគឺគេផ្តោតទៅលើការតែការបំផ្លិចបំផ្លាញក្រុងប៉ុណ្ណោះ ។

មានម្នាក់នៅក្នុងក្រុមស្គាល់ផ្លូវទៅប្រទេសថៃ ។ យើងបានដោះដូរសម្លៀកបំពាក់ជាមួយនឹងអាហារនិងគ្រាប់ពូជសម្រាប់ដាំដុះនៅក្នុងចម្ការ ។ ប្រសិនបើយើងមានចម្ការ យើងអាចបង្ហាញជនកុម្មុយនីស្តថាយើងមានឆន្ទៈចង់រស់នៅទីនោះ ។ យើងបានស្នាក់នៅទីនោះបានមួយខែ ។ នៅពេលជាមួយគ្នា យើងក៏កំពុងរង់ចាំគ្រួសារផ្សេងមកជួយយើងនិងនាំយើងចេញពីប្រទេសនេះ ។

យើងបានបន្តផ្លាស់ប្តូរទីលំនៅពីកន្លែងមួយទៅកន្លែងមួយទៀត ។ ដូច្នេះតើអ្នកដែលចង់រកយើងអាចរកយើងដោយរបៀបណា? តើអ្នកទាំងនោះដឹងថាយើងរស់នៅកន្លែងណាដោយរបៀបណា? ក្រោយមកមានអ្នកខ្លះបានសួរអ្នកជិតខាងថា គីម នៅទីណា ។ អ្នកជិតខាងនោះក៏ សួរនាំ គីម ពីរឿងរ៉ាវទាំងអស់ ។ បន្ទាប់មកក៏និយាយថាប្រសិនបើ គីម មិនឲ្យទៅជាមួយទេ គេនឹងប្រាប់ជនកុម្មុយនីស្តពី គីម ។

អ្នកទាំងនោះគឺជាអ្នកប្រមាញ់សត្វ ។ ព្រះបាននាំផ្លូវឲ្យគ្រួសាររបស់ គីម ជួបជាមួយអ្នកដែលស្គាល់ផ្លូវ ។ មានមនុស្សទាំងអស់៧២នាក់នៅកន្លែងនោះ ។ យើងដឹងថាយើងត្រូវតែចាកចេញនៅថ្ងៃបន្ទាប់ពីព្រោះយប់មុនយើងបានបានឮការជីករណ្តៅហើយយើងដឹងថារណ្តៅនោះគឺសម្រាប់យើង ។ យើងរស់នៅដោយភាពភ័យខ្លាចរាល់ថ្ងៃ ។

មានទារកម្នាក់នៅក្នុងក្រុមយំរាល់យប់ ។ ក្រោយមកមានគេឲ្យថ្នាំងងុយគេងទៅម្តាយទារកនោះ ប៉ុន្តែម្តាយនោះមិនហ៊ានឲ្យកូនរបស់ខ្លួនឡើយ ។

មានខ្ទមមួយនៅក្នុងព្រៃ ហើយមានពន្លឺនៅរានហាល ។ ប៉ុន្តែមិនមាននរណាម្នាក់នៅក្នុងឡើយ អ្នកដែលធ្វើដំណើរជាមួយយើងមានពន្លឺចង្កៀងដូច្នេះយើងអាចមើលឃើញខ្សែលួស ។ អ្នកទាំងនោះបានប្រាប់យើងប្រយ័ត្នរអិលបើមិនដូច្នេះទេយើងនឹងមានគ្រោះថ្នាក់ ។ មិនយូរប៉ុន្មានយើងបានឆ្លងកាត់ព្រំដែន

ហើយរដ្ឋាភិបាលថៃមានឡានទៅរង់ចាំយើងរាល់ថ្ងៃ ។ ឡាននោះបានដឹកយើងទៅជំរំ ។

បន្ទាប់មកយើងបានធ្វើដំណើរមកកាន់សហរដ្ឋអាមេរិក ។ បន្ទាប់ពីរៀនចប់ថ្នាក់វិទ្យាល័យ ខ្ញុំត្រូវតែចាកចេញពីគ្រួសារ (រស់នៅជាមួយគ្រួសាររបស់ គីម) ។ គ្រួសាររបស់មីង គីម បាននិយាយថា ខ្ញុំអាចរស់នៅជាមួយគាត់រហូតដល់ខ្ញុំរកបានផ្ទះសម្រាប់ស្នាក់នៅ ។ អ្នកទាំងនោះកំពុងតែនៅឆ្ងាយខ្វល់ពីរឿងនេះ ដូច្នេះពីរសប្តាហ៍ក្រោយខ្ញុំត្រូវតែចាកចេញ ។

ខ្ញុំបានទៅរស់នៅជាមួយ អានីតា និង ម៉ាចរី ។ អានីតាគឺជាមនុស្សដែលនាំខ្ញុំចូលវិហារ ។ នៅពេលនោះ ខ្ញុំនៅតែមិនទាន់យល់ ។ នៅវិហារមានគេច្រៀងចម្រៀងអំពីបទព្រះ ហើយនៅពេលនោះវាបានធ្វើឲ្យខ្ញុំគិតដល់អ្វីមួយ ។ ខ្ញុំមានអារម្មណ៍ពេញចិត្តជាខ្លាំងណាស់ ។ ផ្ទះដែលខ្ញុំស្នាក់នៅមានទីតាំងស្ថិតនៅផ្នែកម្ខាងទៀតនៃផ្លូវដី ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាដូចជាបានដើរទៅផ្ទះ ។ អានីតា បានអានគម្ពីរឲ្យខ្ញុំស្តាប់រាល់យប់ ។ ក្រោយមកឪពុកម្តាយរបស់ អានីតា ក៏បានឲ្យគម្ពីរមួយក្បាលឲ្យខ្ញុំដែរ ។ ខ្ញុំមានសភាពទទេស្អាត ប៉ុន្តែពាក្យសម្តីរបស់ព្រះមានជាតិសំណើមនិងធ្វើឲ្យខ្ញុំមិនអាចបោះបង់បាន ។ អានីតា ធ្លាប់ជាបុគ្គលិកស្ម័គ្រចិត្ត ក្រោយមកនៅពេលដែល អានីតា បញ្ចប់ការសិក្សានោះ នាងក៏មករស់នៅកាលីហ្វ័រញ៉ា ។

នៅពេលដែលខ្ញុំជាក្មេងស្រីម្នាក់ ឪពុករបស់ខ្ញុំមិនសូវមកទេ ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាឪពុករបស់ខ្ញុំនៅជាមួយខ្ញុំរាល់ពេល ។ ខ្ញុំមានគ្រួសារមួយដែលខ្ញុំតែងតែនឹកជានិច្ច ប៉ុន្តែបច្ចុប្បន្នខ្ញុំមានគ្រួសារមួយផ្សេងទៀតដែលជាគ្រួសាររបស់ព្រះ ។ ព្រះបានបន្តបង្ហាញសេចក្តីស្រឡាញ់ដល់ខ្ញុំ ។ ព្រះយេស៊ូគឺជាអ្នកគង្វាលចៀមដ៏ល្អម្នាក់ គាត់បានធ្វើដំណើរពីចម្ងាយដើម្បីរកចៀម ។ ខ្ញុំពិតជាមានអារម្មណ៍នឹកផ្ទះណាស់ ។ ព្រះយេស៊ូបានអប់រំខ្ញុំពីការពិតនិងផ្តល់ជីវិតដល់ខ្ញុំ ។ **ចេស៊ីកា គៀសាន់**

# ស្វែងរកសាច់ញាតិនៅក្នុងរូបថត

នាងខ្ញុំឈ្មោះ ចេស៊ីកា គៀសាន់ ។ ម្តាយរបស់ខ្ញុំឈ្មោះ ចក់ ប៉ូលីន មានស្រុកកំណើតនៅក្នុងខេត្តព្រៃវែង និងឪពុកខ្ញុំវិញប្រហែលនៅព្រែកពោធិ៍ ។ ម្តាយរបស់ខ្ញុំបានមកកាន់សហរដ្ឋអាមេរិកក្នុងនាមជាជនភៀសខ្លួនម្នាក់ដូចជាជនរងគ្រោះនៃរបបខ្មែរក្រហមដទៃទៀតដែរ ។ ម្តាយរបស់ខ្ញុំបានទៅលេងស្រុកខ្មែរម្តងក្នុងឆ្នាំ១៩៩៧ ហើយពេលនោះគាត់បានជួបជាមួយប្អូនស្រីរបស់គាត់ ។ ដោយសារតែស្ថានភាពសន្តិសុខមិនសូវល្អ ម្តាយរបស់ខ្ញុំមិនបានទៅលេងស្រុកកំណើតទេ ពីព្រោះមានគ្រាប់មីនបង្កប់នៅក្នុងដី ។ ក្រោយមកម្តាយរបស់ខ្ញុំបានត្រឡប់មកសហរដ្ឋអាមេរិកវិញ ។ ចាប់តាំងពីពេលនោះមកម្តាយរបស់ខ្ញុំមិនបានទំនាក់ទំនងជាមួយសាច់ញាតិនៅស្រុកខ្មែរទេ ដោយគ្មានវិធីទាក់ទង ហើយម្តាយរបស់ខ្ញុំក៏មិនដែលបានទៅលេងស្រុកខ្មែរទៀតដែរ ។

ម្តាយរបស់ខ្ញុំមានចិត្តសង្វែកយ៉ាងខ្លាំង ពេលដែលគាត់មិនដឹងពីដំណឹងពីសាច់ញាតិរបស់គាត់ ។ ដូច្នេះខ្ញុំមានរូបថតមួយសន្លឹករបស់ប្អូនស្រីម្តាយខ្ញុំដែលបានថតកាលពីឆ្នាំ១៩៩៧ នៅមុខព្រះបរមរាជវាំង ។ បើសិនជាលោកអ្នកស្គាល់អ្នកនៅក្នុងរូបថតនេះ ឬបើសិនជាអ្នកដែលមាននៅក្នុងរូបថតបានជ្រាបពីព័ត៌មាននេះ សូមទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។ ខ្ញុំនិងម្តាយរបស់ខ្ញុំចង់ដឹងពីសុខទុក្ខរបស់សាច់ញាតិរបស់យើងយ៉ាងខ្លាំង ។ **សូមអរគុណ**



រូបទីពីរ រាប់ពីឆ្វេងគឺ មីងរបស់ ចេស៊ីកា គៀសាន់ ដែលកំពុងស្វែងរក

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០ ១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 135, March 2011 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.